# ក្រសួងអប់រំ យុវជន និងកីឡា

# ការិកបត្រ អប់រំ កម្ពុជា

វ៉ុល ៤ លេខ ១

មិថុនា ២០២១

# កាលិកបត្រ

# អប់រំ

# កម្ពុជា

## វ៉ុល ៤ លេខ ១

**រក្សាសិទ្ធិ © កាលិកបត្រអប់រំកម្ពុជា**

ការបោះពុម្ពនេះ គាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា(អយក) និងកម្ចីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី លេខ ៣៤២៧ CAM(COL)

គ្មានផ្នែកណាមួយនៃការបោះពុម្ពនេះ អាចត្រូវបានយកទៅផលិតឡើងវិញ រក្សាទុក ឬបញ្ជូនតាមទម្រង់ឧបករណ៍ ឬដោយមធ្យោបាយណាមួយ រួមទាំងអេឡិចត្រូនិក មេកានិច ការថតចម្លង ការថតសំឡេង ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអ្នកបោះពុម្ពផ្សាយឡើយ។

បោះពុម្ព និងវាយអក្សរ នៅប្រទេសកម្ពុជា ដោយកាលិកបត្រអប់រំកម្ពុជា

**កាលិកបត្រ**

**អប់រំ**

**កម្ពុជា**

**ក្រុមប្រឹក្សានិពន្ធ**

**ក្រុមប្រឹក្សាវិចារណកថា**

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន *រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន *រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តម លីម សុធា *ក្រសួងអប់រំ យុវជន និងកីឡា*

លោកបណ្ឌិត ឌី សមស៊ីដេត *ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តម អ៊ុង បូរាត *ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តមបណ្ឌិត ឌី ខាំបូលី *ក្រសួងអប់រំ យុវជន និងកីឡា*

លោកបណ្ឌិត ហេង គ្រេង *ក្រសួងអប់រំ យុវជន និងកីឡា*

លោកបណ្ឌិត អ៊ុន លាង *ក្រសួងអប់រំ យុវជន និងកីឡា*

លោកបណ្ឌិត សុខ សូត្រ *ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តមបណ្ឌិត យ៉ាស៊ូស៊ី ហ៊ីរ៉ូសាតុ *សាកលវិទ្យាល័យសុភា ប្រទេសជប៉ុន*

**និពន្ធនាយក**

លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា *នាយកដ្ឋានគោលនយោបាយ នៃក្រសួងអប់រំ យុវជន និងកីឡា*

**និពន្ធនាយករង**

លោកបណ្ឌិត ងិន ច័ន្ទរិទ្ធ *សាកលវិទ្យាល័យអុកឡែន ប្រទេសនូវែលសេឡង់*

លោកបណ្ឌិត សុខ សិរី *សាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

លោក ពៅ សុគុណរិទ្ធ *នាយកដ្ឋានគោលនយោបាយ នៃក្រសួងអប់រំ យុវជន និងកីឡា*

# មាតិកា


វិចារណកថារបស់និពន្ធនាយក i

មាតិកា ii

ទំនាក់ទំនងរវាងការបែងចែកធនធាន និងលទ្ធផលការសិក្សារបស់សិស្ស នៅសាលាមធ្យមសិក្សាធនធានក្នុងប្រទេសកម្ពុជា ១-១៤

កែវ រតនៈ ឈិញ ស៊ីថា និង កង សុផាន់ណា

ការសិក្សាពីឥរិយាបថនៃចំណេះដឹង និងការប្រើប្រាស់កុំព្យូទ័របន្ទះសម្រាប់ការរៀន និងបង្រៀននៅសាលាមធ្យមសិក្សាធនធាន ១៥-៤១

ឈិញ នីដា អ៊ីវ ចាន់ណារ៉ា និង ឈឹម ឫទ្ធិវង្ស

បទពិសោធល្អ និងឧត្តមានុវត្តន៍នៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្ពុជា ៤២-៥៩

ឡាយ សុវិជ្ជា សុក សុផល និង ស៊ិន ណារី

ការលើកកម្ពស់នូវការអប់រំ STEM នៅក្នុងប្រទេសកម្ពុជា តាមរយៈការវិភាគលំហនៃសាលាមធ្យមសិក្សាធនធាន ៦០-៩៥

អ៊ុន ស្រីណែត ស៊ិន ណារី និង ឈឹម ឫទ្ធិវង្ស

**ក្រសួងអប់រំ យុវជន និងកីឡា**

**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវ

# ទំនាក់ទំនងរវាងការបែងចែកធនធាន និងលទ្ធផលការសិក្សារបស់សិស្ស នៅសាលាមធ្យមសិក្សាធនធានក្នុងប្រទេសកម្ពុជា

កែវ រតនៈ[*១] ឈិញ ស៊ីថា[២] កង សុផាន់ណា[៣]

[*១ ៣] នាយកដ្ឋានគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា ប្រទេសកម្ពុជា

អ៊ីមែលរបស់អ្នកនិពន្ធ៖ ratanakkeo119@gmail.com

[២] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រទេសកម្ពុជា

បានទទួល៖ មេសា ២០២១ សម្រេចយក៖ មិថុនា ២០២១

## សង្ខិត្តន័យ

ការស្រាវជ្រាវនេះ មានគោលបំណងសិក្សាពីទំនាក់ទំនងរវាងការបែងចែងធនធាន និងលទ្ធផលការសិក្សារបស់សិស្ស នៅគ្រប់សាលាមធ្យមសិក្សាធនធាន ក្នុងអំឡុងពេលប្រាំឆ្នាំសិក្សាចុងក្រោយ គិតចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៩។ រហូតមកដល់ពេលនេះ ពុំទាន់មានការស្រាវជ្រាវណាមួយដែលសិក្សាអំពីទំនាក់ទំនង ឬផលជះនៃការបែងចែកការប្រើប្រាស់ថវិកា ហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស ទៅលើលទ្ធផលសិក្សារបស់សិស្ស នៅសាលាមធ្យមសិក្សាធនធានក្នុងប្រទេសកម្ពុជានៅឡើយ។ សាលាមធ្យមសិក្សាទាំងអស់ នៅកម្ពុជាមានចំនួន ១៧៨៨ សាលា ដែលត្រូវបានចូលរួមក្នុងការសិក្សានេះ។ ទិន្នន័យចម្រុះនៃសាលាមធ្យមសិក្សាទាំង ១៧៨៨ សាលា ក្នុងរយៈពេលប្រាំឆ្នាំ ត្រូវបានដកស្រង់ចេញពីមូលដ្ឋានផ្ទុកទិន្នន័យរបស់នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ធ្វើការវិភាគ។ វិធីសាស្ត្រស្ថិតិវិទ្យាបែបពិពណ៌នា និងទំនាក់ទំនងត្រូវបានយកមកប្រើនៅក្នុងការវិភាគ។ ការវិភាគរួមមាន ៣២ អថេរ ដែលពាក់ព័ន្ធទៅនឹងការចាត់ចែងថវិកា ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងលទ្ធផលសិក្សារបស់សិស្ស នៅសាលាមធ្យមសិក្សាធនធាន។ របកគំហើញបានបង្ហាញថា ការពង្រីកសាលារៀនដោយមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលស្ថាបនាពីបេតុង និងឈើ មួយអន្លើដោយបន្ទប់ទីចាត់ការដាច់ដោយឡែកមានទំនាក់ទំនងវិជ្ជមានខ្លាំងទៅលើការកើនឡើងនៃលទ្ធផល

សិក្សា។ លើសពីនេះទៀត ការបង្កើនចំនួនគ្រូបង្រៀនដែលមានគុណវុឌ្ឍិមធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ សញ្ញាបត្របរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដែលមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងលទ្ធផលការសិក្សារបស់សិស្ស ក្នុងរយៈពេល ៥ ឆ្នាំ។ លទ្ធផលសិក្សានេះ បានគាំទ្រដល់ការអះអាងថា ការចាត់ចែងធនធាន នៅសាលាមធ្យមសិក្សាធនធានពិតជាមានប្រសិទ្ធភាពក្នុងបរិបទនៃសាលាមធ្យមសិក្សាធនធាន នៅប្រទេសកម្ពុជា។

**ពាក្យគន្លឹះ៖** ការចាត់ចែងធនធាន លទ្ធផលការសិក្សារបស់សិស្ស សាលាមធ្យមសិក្សាធនធាន កម្ពុជា។

**អាគតដ្ឋាន៖** កែវ, រ., ឈិញ, ស., & កង, ស. (២០២១), ទំនាក់ទំនងរវាងការចាត់ចែងធនធាន និងលទ្ធផលការសិក្សារបស់សិស្ស នៅសាលាមធ្យមសិក្សាធនធានក្នុងប្រទេសកម្ពុជា,*កាលិកបត្រអប់រំកម្ពុជា,៤(១)*, ១-១៤។

## ១. សេចក្តីផ្តើម

សាលាមធ្យមសិក្សាធនធានត្រូវបានផ្តល់ក្តីរំពឹងយ៉ាងមុតមាំពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍ សហគមន៍ និងសិស្សានុសិស្សថាជាគ្រឹះស្ថានដែលនឹងបំពេញតួនាទីបានយ៉ាងប្រសើរ និងជាសាលាគំរូដែលកសាងធនធានមនុស្សឱ្យមានចំណេះដឹង ជំនាញ និងអាកប្បកិរិយាល្អ។ គុណភាពនៃការអប់រំមានសារៈសំខាន់ណាស់ក្នុងការជំរុញឱ្យប្រទេសកម្ពុជា អាចចាកចេញពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០។ សាលាមធ្យមសិក្សាធនធានគឺជាធាតុផ្សំជាយុទ្ធសាស្ត្រមួយដ៏សំខាន់របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់គុណភាពអប់រំ កម្រិតមធ្យមសិក្សានៅប្រទេសកម្ពុជា។ ក្រសួងអប់រំ យុវជន និងកីឡា (2008, p.2) បានឱ្យនិយមន័យថា «សាលាមធ្យមសិក្សាធនធានគឺជាសាលារៀនដែលត្រូវបំពាក់ ឬផ្តល់ឱ្យហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈដូចជា អគារ សាលប្រជុំ មន្ទីរពិសោធន៍ បណ្ណាល័យ សាលកុំព្យូទ័រ សាលសោតទស្សន៍ ប្រភពផ្គត់ផ្គង់អគ្គិសនី ប្រភពផ្គត់ផ្គង់ទឹកស្អាត។ល។ ជាពិសេស ការទទួលបាននូវការបណ្តុះបណ្តាលបុគ្គលិកអប់រំពីវិធីប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈដែលបានផ្តល់ជូន» (p.2)។ យោងតាមគោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន ដែលបានបង្កើតឡើងក្នុងឆ្នាំ ២០០៨ និងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃសាលាមធ្យមសិក្សាធនធាន (MoEYS, 2018a) គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្សនៃសាលាមធ្យមសិក្សាធនធាននឹងត្រូវដើរតួនាទីជាគំរូសម្រាប់សហគមន៍ និងតំបន់នៅជុំវិញនោះរបស់ពួកគេ។ សាលាមធ្យមសិក្សាធនធានត្រូវដើរតួនាទីជាមជ្ឈមណ្ឌលបណ្តាញ ក្នុងការកសាងកិច្ចសហប្រតិបត្តិការ ចែករំលែកបទពិសោធ និងការជំរុញឱ្យមានសាមគ្គីភាព ក្នុងបណ្តាសាលារៀននានាក្នុងសហគមន៍ទាំងមូល។ ការបង្កើតសាលាមធ្យមសិក្សាធនធានបានជួយលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន ការចែករំលែកការអនុវត្ត និងបទពិសោធល្អៗក្នុងការបង្រៀន ការរៀន និងការគ្រប់គ្រងសាលាបណ្តាញដូចជា ការ

បង្រៀនពីផែនការប្រតិបត្តិ និងលើកកម្ពស់សាលារៀន ហើយនិងលើកកម្ពស់សមត្ថភាពគ្រូបង្រៀនតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈ និងការបង្ហឹកណែនាំ (MoEYS, 2008)។ តាមរយៈការបង្កើតសាលាមធ្យមសិក្សាធនធាន វាគ្រាន់តែជាជំហានបឋមមួយប៉ុណ្ណោះ ក្នុងការសម្រេចឱ្យបាននូវលទ្ធផលដែលរំពឹងទុកជាក់ស្តែង ពោលគឺការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅកម្រិតមធ្យមសិក្សា។ កិច្ចខិតខំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរ វាគឺជាធនធានមនុស្សដ៏សំខាន់ និងបន្ថែម ដើម្បីឱ្យប្រទេសកម្ពុជាអាចសម្រេចបាននូវគោលដៅអភិវឌ្ឍជាតិនៅឆ្នាំ ២០៣០ និង២០៥០។

ក្នុងកិច្ចគាំទ្រដល់សាលាមធ្យមសិក្សាធនធាននៅកម្ពុជា ការវិនិយោគក្នុងការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុបានប្រព្រឹត្តទៅអស់រយៈពេលមួយទសវត្សរ៍មកហើយ។ រហូតមកដល់ពេលនេះ សាលាមធ្យមសិក្សាធនធានជាច្រើនត្រូវបានគេទទួលស្គាល់ថា មានការរីកចម្រើនលឿនក្នុងការអភិវឌ្ឍការបង្រៀន និងរៀន ជាពិសេសទាក់ទងទៅនឹងលទ្ធផលសិក្សារបស់សិស្ស ដែលគេសង្កេតឃើញមានភាពខុសគ្នាយ៉ាងច្បាស់លាស់រវាងសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាដទៃទៀត នៅទូទាំងប្រទេស។ សមិទ្ធផលដែលសាលាមធ្យមសិក្សាធនធានសម្រេចបាន ត្រូវបានគេសង្កេតឃើញថាជាការឆ្លុះបញ្ចាំងនៃកិច្ចប្រឹងប្រែងក្នុងការកៀរគរហេដ្ឋារចនាសម្ព័ន្ធ ថវិកា និងធនធានមនុស្ស ដើម្បីលើកកម្ពស់គុណភាពសិក្សារបស់សិស្ស។ បើទោះបី កិច្ចខិតខំប្រឹងប្រែងនេះត្រូវបានអនុវត្តអស់រយៈពេលមួយទសវត្សរ៍មកហើយក្តី ក៏មិនទាន់មានការសិក្សាស្រាវជ្រាវណាមួយស្តីពីផលជះនៃការកៀរគរធនធានទៅលើគុណភាពនៃការអនុវត្តរបស់សាលារៀន និងប្រសិទ្ធភាពនៃការចាត់ចែងប្រើប្រាស់ធនធានក្នុងការលើកកម្ពស់គុណភាពសិក្សារបស់សិស្ស លទ្ធផលសិក្សារបស់សិស្ស ឬឥទ្ធិពលនៃការចាត់ចែងប្រើប្រាស់ធនធានទៅលើទិដ្ឋភាពដទៃទៀតនៃការលើកកម្ពស់គុណភាពដែលពាក់ព័ន្ធនឹងសាលារៀននៅឡើយ។

ដូច្នេះ ការសិក្សានេះមានគោលបំណងសិក្សាស្រាវជ្រាវទៅលើទំនាក់ទំនង រវាងការចាត់ចែងលើការប្រើប្រាស់ធនធាន ធៀបជាមួយនឹងគុណភាពសិក្សារបស់សិស្សក្នុងរយៈពេល ៥ ឆ្នាំកន្លងមក។ ការស្រាវជ្រាវនេះស្វែងរកការពន្យល់មួយថា តើធនធាន (រួមមានការអភិវឌ្ឍនៃហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងថវិកា) ជាប់ទាក់ទងវិជ្ជមាន និងចាំបាច់ទៅនឹងគុណភាពសិក្សារបស់សិស្សយ៉ាងដូចម្តេច? ការស្រាវជ្រាវនេះ ត្រូវបានលើកឡើងជាសំណួរស្រាវជ្រាវថា៖ «តើអ្វីទៅជាទំនាក់ទំនងរវាងធនធាន រួមមាន ហេដ្ឋារចនាសម្ព័ន្ធ ថវិកា ធនធានមនុស្ស និងគុណភាពសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាធនធានក្នុងប្រទេសកម្ពុជា អស់រយៈពេល៥ឆ្នាំសិក្សាចុងក្រោយនេះ?»

លទ្ធផលនៃការស្រាវជ្រាវនេះអាចនឹងដើរតួនាទីជួយផ្តល់ព័ត៌មានជាក់ស្តែងដល់ក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធដទៃទៀតឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីផលជះនៃកិច្ចប្រឹងប្រែងរបស់ពួកគេក្នុងការគាំទ្រដល់សាលាមធ្យមសិក្សាធនធាន ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ វាក៏អាចផ្តល់ឱ្យក្រសួងអប់រំ យុវជន និងកីឡា រកឃើញនូវបទអន្តរាគមន៍សមស្របទាន់ពេល និងដើម្បីធានាឱ្យបាននូវការអភិវឌ្ឍ និងការលើកកម្ពស់សាលាមធ្យមសិក្សាធនធាន ដ៏ត្រឹមត្រូវ នាពេលអនាគត។ របកគំហើញនេះ នឹងលាតត្រដាងយ៉ាងច្បាស់លាស់នូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការប្រើប្រាស់ធនធាននៅសាលាមធ្យមសិក្សាធនធាន ដូច្នេះ

សាលាបណ្ដាញ និងសាលាមធ្យមសិក្សាដទៃទៀតអាចនឹងធ្វើការរៀនសូត្រពីបទពិសោធល្អៗ និងឧត្ដមានុវត្តន៍ដែលបានរកឃើញ។

## ២. រំឭកទ្រឹស្ដី

ទោះបីជាកន្លងមក មានការសិក្សាស្រាវជ្រាវដាច់ដោយឡែក ដោយផ្ដោតលើទិដ្ឋភាពទាក់ទងទៅនឹងគុណភាពសិក្សារបស់សិស្សមានផ្សេងៗគ្នា ក៏មានការសិក្សាជាច្រើន បានផ្ដោតទៅលើទំនាក់ទំនង ឬឥទ្ធិពលនៃធនធានសាលារៀនទៅលើគុណភាពសិក្សារបស់សិស្ស (សូមមើល Akey, 2006b; MacNeil, Prater, & Busch, 2009; Mortimore, 2001; Pov, Kawai, & Matsumiya, 2020; Uline & Tschannen-Moran, 2008) និងអត្រាបោះបង់ការសិក្សា (សូមមើល Aaronson, Barrow, & Sander, 2007; Christle, Jolivette, Nelson, & education, 2007; Quinn, 2013; World Bank, 2005)។ បន្ថែមលើនេះ ការសិក្សាជាច្រើនបានបង្ហាញថាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ រវាងបរិយាកាសសាលារៀនជាមួយនឹងលទ្ធផលសិក្សារបស់សិស្ស (សូមមើល Hoy & Sabo, 1998; Uline & Tschannen-Moran, 2008)។ បរិយាកាសសាលារៀនវិជ្ជមានគឺជាកត្តាដែលមានសារៈសំខាន់ក្នុងការលើកកម្ពស់អាកប្បកិរិយានិងលទ្ធផលសិក្សារបស់សិស្ស។ ការសិក្សារបស់ Uline and Tschannen-Moran's (2008) ផ្ដោតលើផលជះនៃគុណភាពសម្ភារបរិក្ខារ និងបរិយាកាសសាលាទៅលើលទ្ធផលសិក្សារបស់សិស្ស។ ទាំងនេះបានបង្ហាញថា សន្ទស្សន៍នៃបរិយាកាសសាលារៀនមានភាពទាក់ទងយ៉ាងជ្រាលជ្រៅជាមួយនឹងលទ្ធផលសិក្សារបស់សិស្ស។ ការស្រាវជ្រាវនេះក៏បានរកឃើញថា សម្ភារបរិក្ខារសាលារៀនមានទំនាក់ទំនងជាវិជ្ជមាន និងជ្រាលជ្រៅជាមួយនឹងលទ្ធផលសិក្សារបស់សិស្ស ជាមួយគ្នានេះដែរ បរិយាកាសសាលារៀន ក៏មានជាប់ទាក់ទងទៅនឹងគុណភាពនៃសម្ភារបរិក្ខារសាលារៀន។ ជាពិសេស បរិស្ថានរៀនសូត្រប្រកបដោយផាសុកភាពគឺជាធាតុមួយនៃបរិយាកាសសាលារៀន ហើយបរិយាកាសសាលារៀន ក៏ជាអថេរដ៏សំខាន់ដែលកំណត់នូវបរិស្ថានរៀនសូត្រប្រកបដោយផាសុកភាព។ MacNeil, Prater and Busch (2009) បានលើកឡើងថា សិស្សានុសិស្សនឹងទទួលបានលទ្ធផលខ្ពស់លើតេស្តស្តង់ដា នៅពេលដែលសាលារៀនមានបរិស្ថានសិក្សាប្រកបដោយផាសុកភាព។ វិធីសាស្ត្របង្រៀន និងបរិយាកាសសាលារៀន ដែលសំដៅទៅលើភាពឆ្លើយតបរបស់សាលារៀន និងបរិស្ថានគាំទ្រគឺជាកត្តារំពឹងទុកដ៏សំខាន់ក្នុងការសម្រេចបានលទ្ធផលសិក្សារបស់សិស្ស។

ម្យ៉ាងវិញទៀត ធនធានរបស់សាលារៀនដូចជា សម្ភារបរិក្ខារ និងសៀវភៅ មានតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់សិស្សក្នុងការរៀនសូត្រ ហើយការសិក្សាស្រាវជ្រាវនាប៉ុន្មានទសវត្សរ៍កន្លងមក បានរកឃើញថា ធនធានមានទំនាក់ទំនងគ្នាជាមួយនឹងលទ្ធផលសិក្សារបស់សិស្សនៅសាលារៀន (សូមមើល Coleman, 1966; Hanushek, 1981, 1986, 1989, 1991; Pov et al., 2020)។ ការសិក្សាតាមឯកសារ និងស្នាដៃស្រាវជ្រាវជាច្រើនបានផ្ដល់នូវភស្តុតាងដ៏រឹងមាំដែលបញ្ជាក់ថា តើអថេរនៃបរិយាកាសសាលារៀនដ៏សម្បូរបែបជះឥទ្ធិពលយ៉ាងណាទៅលើលទ្ធផលសិក្សារបស់សិស្ស (សូមមើល Leithwood, Louis, Anderson, & Wahlstrom, 2004; Mortimore,

2001)។ ការសិក្សាស្រាវជ្រាវផ្សេងទៀតបានរកឃើញថា មានទំនាក់ទំនងរវាងលទ្ធផលសិក្សារបស់សិស្សជាមួយនឹងអថេរផ្សេងៗទៀតដែលទាក់ទងនឹងសាលារៀនដូចជា គ្រូបង្រៀន បរិបទសាលារៀន ធនធានសាលារៀន និងភាពជាអ្នកដឹកនាំរបស់នាយកសាលា (សូមមើល Akey, 2006b; Ma & Klinger, 2000; Schreiber, 2002; Stewart, 2007)។ ទោះបីជាយ៉ាងណា បើយោងទៅលើការសិក្សាមួយក្នុងប្រទេសកម្ពុជាទៅលើផលជះនៃកត្តាដែលពាក់ព័ន្ធនឹងសិស្ស គ្រួសារសិស្ស និងសាលារៀន Pov et al. (2020) បានរកឃើញថា កត្តាដែលពាក់ព័ន្ធនឹងសាលារៀនមិនមានឥទ្ធិពលគួរឱ្យកត់សម្គាល់ទៅលើលទ្ធផលសិក្សារបស់សិស្សនោះទេ ក្នុងការសិក្សាបែបម៉ូដែលកម្រិតពីរ Hierarchical Linear Model (HLM)។

# ៣. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ បានធ្វើការស្រាវជ្រាវទៅលើសាលាមធ្យមសិក្សាទាំងអស់នៅកម្ពុជា ដែលមានចំនួនសរុប ១៧៨៨ សាលា។ ទិន្នន័យចម្រុះរយៈពេលប្រាំឆ្នាំនៃសាលាមធ្យមសិក្សាធនធានត្រូវបានទាញយកចេញពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ(EMIS)ដោយគិតពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០។ នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំទទួលខុសត្រូវក្នុងការប្រមូលទិន្នន័យស្ថិតិ ដែលពាក់ព័ន្ធទៅនឹងសូចនាករអប់រំ នៅទូទាំងប្រទេស ដើម្បីចងក្រងជាឯកសារបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យរបស់ខ្លួនជាប្រចាំឆ្នាំ។ របាយការណ៍ស្ដីពីស្ថិតិ និងសូចនាករត្រូវបានបោះពុម្ពជារៀងរាល់ឆ្នាំ ដោយរួមបញ្ចូលទាំងប្រភពទិន្នន័យមិនទាន់វិភាគរបស់ក្រសួងអប់រំ យុវជន និងកីឡាផងដែរ។ ក្រុមការងារស្រាវជ្រាវបានសម្រេចចិត្តស្នើសុំទៅនាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ដើម្បីឱ្យផ្ដល់នូវទិន្នន័យ ដែលរួមមាន៣២ សូចនាករ ឬអថេរ ដែលពាក់ព័ន្ធនឹងកត្តាផ្សំទាំងបួននៃដំណើរការសាលារៀន និងគុណភាពសិក្សារបស់សិស្សទាំងនេះ រួមមាន ថវិកា ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស (ការអប់រំ ឬការបណ្ដុះបណ្ដាលគ្រូបង្រៀន) និងគុណភាពសិក្សារបស់សិស្ស។ អថេរទាំងអស់គឺត្រូវបានសរសេរជាលេខ និងអត្រាជាភាគរយ។ ដោយសារតែទិន្នន័យក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានប្រមូលពីទិន្នន័យចម្រុះ ដែលមិនមានតុល្យភាពរយៈពេលប្រាំឆ្នាំ មធ្យមភាគនៃអថេរនីមួយៗនៃឆ្នាំនីមួយៗត្រូវបានគណនា ដើម្បីឱ្យវាអាចតំណាងឱ្យអថេរនីមួយៗនៃឆ្នាំនីមួយៗសម្រាប់រយៈពេលប្រាំឆ្នាំ។

ការសិក្សានេះក៏ប្រើប្រាស់ផងដែរនូវវិធីសាស្ត្រ Pearson’s Correlation ដើម្បីវិភាគទិន្នន័យ សម្រាប់ពិនិត្យមើលនូវទំនាក់ទំនងរវាងថវិកា ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងគុណភាពសិក្សារបស់សិស្ស។ ម្យ៉ាងវិញទៀតវិធីសាស្ត្រ Pearson’s Correlation coefficient (*r*) ក៏ត្រូវបានប្រើប្រាស់ផងដែរ ដើម្បីវាស់ស្ទង់ និងពន្យល់អំពីភាពរឹងមាំនៃការរួមបញ្ចូលគ្នារវាងអថេរទាំងអស់ ហើយ P-value (*p*) នឹងត្រូវតំណាង ដើម្បីបង្ហាញពីកម្រិតសំខាន់នៃមេគុណ។ ទិន្នន័យត្រូវបានបែងចែកជាបួនកត្តាផ្សំគឺ៖ ថវិកា ហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស និងគុណភាពសិក្សារបស់សិស្ស។

មានអថេរចំនួនប្រាំស្ថិតនៅក្នុងកត្តាថវិកា ដែលផ្តោតទៅលើប្រភពថវិកាដែលចាត់ចែងប្រើប្រាស់សម្រាប់សាលាមធ្យមសិក្សាធនធានរួមមាន៖ សាលារៀនដែលទទួលបានថវិកាពីសាលារៀន សាលាដែលទទួលបានថវិកាពីសហគមន៍ សាលាដែលទទួលថវិកាពីរាជរដ្ឋាភិបាល សាលាដែលទទួលថវិកាពីក្រៅប្រទេស និងសាលាដែលទទួលថវិកាពីអង្គការមិនមែនរដ្ឋាភិបាល។ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ មានអថេរចំនួនប្រាំបួនដែលប្រើគំរូទំនាក់ទំនង ដូចជា៖ សាលារៀនដែលមានសំណង់ពីបេតុង សាលាដែលមានសំណង់ពីឈើ សាលាដែលគ្មានទឹក សាលាដែលមានបង្គន់សាធារណៈ សាលាដែលមិនមានកម្រាលល្អ សាលាដែលមិនមានដំបូលល្អ សាលាដែលមិនមានជញ្ជាំងល្អ សាលាដែលមានទីចាត់ការដាច់ដោយឡែក និងសាលាដែលមានបណ្ណាល័យដាច់ដោយឡែក។ សម្រាប់កត្តាធនធានមនុស្ស អថេរបានផ្តោតទៅលើគុណវុឌ្ឍិគ្រូបង្រៀនដែលបម្រើការងារនៅសាលាមធ្យមសិក្សាធនធាន។ អថេរទាំងនោះរួមមាន៖ គ្រូដែលទទួលបានការអប់រំកម្រិតបឋមសិក្សា គ្រូដែលទទួលបានការអប់រំមធ្យមសិក្សាបឋមភូមិ គ្រូដែលទទួលបានការអប់រំមធ្យមសិក្សាទុតិយភូមិ គ្រូដែលទទួលបានអប់រំក្រោយកម្រិតឧត្តម គ្រូដែលមានសញ្ញាបត្របណ្ឌិត និងគ្រូដែលទទួលបានការបណ្តុះបណ្តាលគរុកោសល្យ។ ជាចុងក្រោយ កត្តាគុណភាពសិក្សារបស់សិស្ស រួមមាន ១២ អថេរ៖ ចំនួនសិស្ស អត្រាត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាបឋមភូមិ អត្រាត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាទុតិយភូមិ អត្រាឆ្លងភូមិសិក្សានៅមធ្យមសិក្សាទុតិយភូមិ អត្រាចុះឈ្មោះចូលរៀននៅមធ្យមសិក្សាបឋមភូមិ អត្រាចុះឈ្មោះចូលរៀននៅមធ្យមសិក្សាទុតិយភូមិ អត្រាបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ អត្រាបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ភាពជោគជ័យនៃបេក្ខជននៅថ្នាក់ទី៩ ភាពជោគជ័យនៃបេក្ខជននៅថ្នាក់ទី១២ សិស្សដែលបានបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងសិស្សដែលបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ។ ដោយឡែក អថេរពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ ថវិកា និងធនធានមនុស្សត្រូវបានប្រើប្រាស់ជាអថេរឯករាជ្យ (Independent Variables) ចំពោះអថេរពាក់ព័ន្ធនឹងគុណភាពសិក្សារបស់សិស្សត្រូវបានប្រើជាអថេរមិនឯករាជ្យ (Dependent Variables) សម្រាប់ការវិភាគ និងការបកស្រាយ។

## ៤. លទ្ធផលស្រាវជ្រាវ

របកគំហើញពីការប្រើប្រាស់វិធី Pearson's Correlation បានបង្ហាញថា មានទំនាក់ទំនងយ៉ាងជ្រាលជ្រៅរវាងគុណភាពសិក្សារបស់សិស្ស និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សដូចដែលមានបង្ហាញក្នុងតារាង ១។

ការវិភាគលើទំនាក់ទំនង (Correlation Analysis) បានរកឃើញថា ចំនួនសិស្សសរុបដែលកើនឡើង មានទំនាក់ទំនងជាវិជ្ជមានខ្លាំងបំផុត ដែលអាចចាត់ទុកថា មានឥទ្ធិពលយ៉ាងខ្លាំង (សូមមើល Abrami, Cohen, & d'Apollonia, 1988) ជាមួយនឹងកំណើនសាលារៀនដែលមានសំណង់បេតុង ($r$ =91, $p$ <0.05) មានគ្រូបង្រៀនដែលមានកម្រិតអប់រំមធ្យមសិក្សាបឋមភូមិ ($r$ =99, $p$ <0.01) និង គ្រូបង្រៀនដែលទទួលបានការអប់រំ

កម្រិតបរិញ្ញាបត្រក្រោយឧត្តម($r$ =92, $p$<0.05)។ នេះមានន័យថា ចំនួនសិស្សមាននិន្នាការកើនឡើងក្នុងសាលារៀនដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ និងគ្រូបង្រៀនដែលបានបញ្ចប់ការអប់រំយ៉ាងទាប ត្រឹមមធ្យមសិក្សាបឋមភូមិ។ ទោះជាយ៉ាងណាក៏ដោយ សាលារៀនដែលមានសំណង់សាងពីឈើ ($r$ =-97, $p$<0.01) និងមានគ្រូបង្រៀនដែលបញ្ចប់ការអប់រំកម្រិតវិទ្យាល័យ ($r$ =-96, $p$<0.01) មានទំនាក់ទំនងជាអវិជ្ជមានយ៉ាងខ្លាំងជាមួយនឹងកំណើននៃចំនួនសិស្សសរុប។ នេះមានន័យថា គុណភាពសិក្សារបស់សិស្សហាក់ដូចជាមានការធ្លាក់ចុះក្នុងសាលារៀនដែលមានហេដ្ឋារចនាសម្ព័ន្ធមិនល្អ ទោះបីជាគ្រូបង្រៀនភាគច្រើនបានបញ្ចប់ការអប់រំ កម្រិតមធ្យមសិក្សាវិទ្យាល័យក៏ដោយ។ ចំពោះអត្រាត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាបឋមភូមិវិញ ត្រូវបានរកឃើញថាមានទំនាក់ទំនងវិជ្ជមានយ៉ាងខ្លាំង ជាមួយនឹងគ្រូបង្រៀនដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ($r$ =92, $p$<0.05)។ ម្យ៉ាងវិញទៀត អត្រាត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាទុតិយភូមិត្រូវបានរកឃើញថា មានទំនាក់ទំនងជាវិជ្ជមានយ៉ាងខ្លាំងជាមួយនឹងសាលារៀនដែលមានសំណង់ធ្វើពីឈើ ($r$ =96, $p$<0.01) និងគ្រូបង្រៀនដែលបានបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ ($r$ =95, $p$<0.05)។ ហើយវាមានទំនាក់ទំនងជាអវិជ្ជមានយ៉ាងខ្លាំងជាមួយនឹងសាលារៀនដែលមានសំណង់ពីបេតុង ($r$ =-95, $p$<0.05) គ្រូបង្រៀនទទួលការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ($r$ =-91, $p$<0.05) និងគ្រូបង្រៀនដែលទទួលការអប់រំកម្រិតក្រោយឧត្តម ($r$ =-99, $p$<0.01)។ នេះអាចឱ្យយើងសន្និដ្ឋានបានថា កំណើនក្នុងសាលារៀនដែលមានសំណង់ពីឈើ និងគ្រូបង្រៀនដែលមានការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិអាចទំនងជាធ្វើឱ្យមានកំណើនអត្រាត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

លើសពីនេះទៀត កំណើនក្នុងសាលារៀនដែលមានសំណង់ពីបេតុង គ្រូបង្រៀនដែលទទួលការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ និងគ្រូបង្រៀនដែលទទួលការអប់រំកម្រិតក្រោយឧត្តម នឹងទំនងជាធ្វើឱ្យមានការធ្លាក់ចុះនូវអត្រាត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ជាងនេះទៅទៀត អត្រាចុះឈ្មោះចូលរៀនសរុបនៅកម្រិតមធ្យមសិក្សាបឋមភូមិមានទំនាក់ទំនងជាវិជ្ជមានយ៉ាងខ្លាំងជាមួយនឹងសាលារៀន ដែលមានទីចាត់ការដាច់ដោយឡែក ($r$ =88, $p$<0.05) និងមានគ្រូបង្រៀនដែលទទួលការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ($r$ =99, $p$<0.01)។ ជាមួយគ្នានេះដែរ ទំនាក់ទំនងអវិជ្ជមានខ្លាំងត្រូវបានរកឃើញរវាងអត្រាចុះឈ្មោះចូលរៀនសរុបជាមួយនឹងសាលារៀនដែលមានសំណង់សង់ពីឈើ($r$ =-91, $p$<0.05) និងគ្រូបង្រៀនដែលមានការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ($r$ =-92, $p$<0.05)។ នេះមានន័យថា កំណើនក្នុងសាលារៀនដែលមានទីចាត់ការដាច់ដោយឡែក និងគ្រូបង្រៀនដែលមានការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ហាក់ដូចជាបានជំរុញកំណើនយ៉ាងលឿននៃអត្រាចុះឈ្មោះចូលរៀនសរុបនៅកម្រិតមធ្យមសិក្សាបឋមភូមិ ប៉ុន្តែថា ការថយចុះនៃសាលារៀនដែលមានសំណង់អំពីឈើ និងគ្រូបង្រៀនដែលទទួលការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ហាក់បីដូចជា ជួយបង្កើននូវអត្រាចុះឈ្មោះចូលរៀនសរុបយ៉ាងខ្លាំង។ ស្រដៀងគ្នានេះដែរ អត្រាចុះឈ្មោះចូលរៀនសរុបនៅកម្រិតមធ្យម

សិក្សាទុតិយភូមិមានទំនាក់ទំនងវិជ្ជមានយ៉ាងខ្លាំងជាមួយនឹងសាលារៀន ដែលមានសំណង់ពីបេតុង ($r$ =93, $p$<0.05) សាលារៀនដែលមានទីចាត់ការដាច់ដោយឡែក ($r$ =90, $p$<0.05) និងគ្រូបង្រៀនដែលបានបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ($r$ =94, $p$<0.01)។ ទំនាក់ទំនងអវិជ្ជមាន ក៏ត្រូវបានរកឃើញរវាងអត្រាចុះឈ្មោះចូលរៀនជាមួយនឹងសាលារៀនដែលមានសំណង់អំពីឈើ ($r$ =-98, $p$<0.01) គ្រូបង្រៀនដែលទទួលការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ($r$ =-97,$p$<0.01) និងគ្រូបង្រៀនដែលមានកម្រិតអប់រំក្រោយឧត្តម។ បន្ថែមលើសពីនេះ អត្រាបោះបង់នៅកម្រិតធម្យមសិក្សាបឋមភូមិ មិនត្រូវបានរកឃើញថា មានទំនាក់ទំនងគួរឱ្យកត់សម្គាល់ទៅនឹងអថេរ ថវិកា ហេដ្ឋារចនាសម្ព័ន្ធ ឬធនធានមនុស្សឡើយ ប៉ុន្តែ អត្រាបោះបង់នៅកម្រិតធម្យមសិក្សាទុតិយភូមិ ត្រូវបានរកឃើញថា មានទំនាក់ទំនងយ៉ាងអវិជ្ជមានជាមួយគ្រូដែលទទួលបានការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ។

នេះមានន័យថា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ អត្រាបោះបង់ការសិក្សាមានទំនោរកើនឡើងក្នុងកម្រិតមួយដោយសារតែសាលារៀនមានគ្រូបង្រៀនភាគច្រើន មានកម្រិតអប់រំត្រឹមមធ្យមសិក្សាបឋមភូមិតែប៉ុណ្ណោះ។ ភាពជោគជ័យរបស់បេក្ខជនថ្នាក់ទី៩ មានទំនាក់ទំនងវិជ្ជមានយ៉ាងខ្លាំងជាមួយសាលារៀនដែលមានសំណង់អគារថ្ម (($r$ =99, $p$<0.01) ជាមួយគ្រូបង្រៀនដែលបានបញ្ចប់ថ្នាក់ក្រោយឧត្តម ( $r$ =96, $p$<0.05)។ ភាពជោគជ័យរបស់បេក្ខជនថ្នាក់ទី៩ ត្រូវបានគេរកឃើញថាមានទំនាក់ទំនងអវិជ្ជមានជាមួយសាលារៀនដែលមានសំណង់អគារឈើ ($r$ =-96, $p$<0.01) និងជាមួយគ្រូបង្រៀនដែលមានកម្រិតវប្បធម៌ត្រឹមមធ្យមសិក្សាទុតិយភូមិ ($r$ =-91, $p$<0.05)។ នេះបានន័យថា ចំនួនសិស្សកាន់តែច្រើន ហាក់បីដូចជាប្រឡងជាប់កម្រិតថ្នាក់ទី៩បានច្រើន នៅពេលដែលសាលារៀនរបស់ពួកគេមានសំណង់អគារថ្ម និងគ្រូបង្រៀនរបស់ពួកគេច្រើនបានបញ្ចប់ថ្នាក់ក្រោយឧត្តម បើធៀបនឹងសាលារៀនដទៃទៀត។ ក្នុងស្ថានភាពស្រដៀងគ្នានេះដែរ អត្រាបញ្ចប់ការសិក្សានៅសាលាមធ្យមសិក្សាបឋមភូមិមានទំនាក់ទំនងវិជ្ជមានជាមួយសាលារៀន ដែលមានសំណង់អគារថ្ម ($r$ =99, $p$<0.01) ហើយមានគ្រូបង្រៀនដែលបានបញ្ចប់ថ្នាក់ក្រោយឧត្តម ($r$ =95, $p$<0.05) ខណៈពេលដែលអត្រាបញ្ចប់ការសិក្សានេះមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងសាលារៀន ដែលមានសំណង់អគារឈើ ($r$ =-95, $p$<0.05) ហើយនិងគ្រូបង្រៀនដែលបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ ($r$ =-90, $p$<0.05)។ អត្រាបញ្ចប់ការសិក្សាមានកម្រិតខ្ពស់សម្រាប់សាលារៀនដែលមានសំណង់អគារថ្ម និងមានគ្រូបង្រៀនច្រើននាក់ដែលបានបញ្ចប់ថ្នាក់ក្រោយឧត្តម ប៉ុន្តែអត្រានេះបែរជាទាបសម្រាប់សាលារៀនដែលមានសំណង់អគារឈើ និងមានចំនួនគ្រូបង្រៀនជាច្រើនមានការអប់រំត្រឹមមធ្យមសិក្សាទុតិយភូមិ។ ជាចុងក្រោយ លទ្ធផលស្រាវជ្រាវនេះបង្ហាញថា អត្រាបញ្ចប់ការសិក្សាក្នុងសាលារៀនមធ្យមសិក្សាទុតិយភូមិមានទំនាក់ទំនងវិជ្ជមានខ្លាំងជាមួយគ្រូបង្រៀនដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ ($r$ =95, $p$<0.05) ស្របពេលគ្នា មានទំនាក់ទំនង

អវិជ្ជមានជាមួយសាលារៀនដែលមានសំណង់ឈើ ($r$ =-94, $p$<0.05) និងគ្រូបង្រៀនដែលបានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ ($r$ =-91, $p$<0.05)។

**តារាង ១**

សម្ព័ន្ធទំនាក់ទំនងនៃអថេរទៅនឹងលទ្ធផលការសិក្សារបស់សិស្ស ជាមួយនឹងអថេរទាក់ទងនឹងការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស រយៈពេលប្រាំឆ្នាំចុងក្រោយ។

| ល.រ | អថេរ | សាលារៀនដែលមានសំណង់អគារថ្ម | សាលារៀនដែលមានសំណង់អគារឈើ | សាលារៀនដែលមានការិយាល័យជាច់ដោយឡែក | គ្រូបង្រៀនដែលបានបញ្ចប់មធ្យមសិក្សាបឋមភូមិ | គ្រូបង្រៀនដែលបានបញ្ចប់មធ្យមសិក្សាទុតិយភូមិ | គ្រូបង្រៀនបានបញ្ចប់កម្រិតក្រោយឧត្តម |
|---|---|---|---|---|---|---|---|
| ១ | ចំនួនសិស្ស | **.91*** | **-.97**** | 0.83 | **.99**** | **-.96**** | **.92*** |
| ២ | អត្រាសិស្សត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាបឋមភូមិ | 0.73 | -0.80 | 0.75 | **.92*** | -0.81 | 0.87 |
| ៣ | អត្រាសិស្សត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាទុតិយភូមិ | **-.95*** | **.96**** | -0.72 | **-.91*** | **.95*** | **-.99**** |
| ៤ | អត្រាសិស្សចុះឈ្មោះចូលរៀនក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ | 0.81 | **-.91*** | **.88*** | **.99**** | **-.92*** | 0.83 |
| ៥ | អត្រាសិស្សចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ | **.93*** | **-.98**** | 0.80 | **.97**** | **-.97**** | **.94*** |
| ៦ | អត្រាសិស្សបោះបង់ការសិក្សាចោលនៅកម្រិតមធ្យមសិក្សាទុតិយភូមិ | -0.85 | 0.84 | -0.49 | **-.92*** | 0.73 | -0.83 |
| ៧ | ការជោគជ័យរបស់សិស្សថ្នាក់ទី៩ | **.99**** | **-.96**** | 0.58 | 0.81 | **-.91*** | **.96*** |
| ៨ | អត្រាបញ្ចប់នៅកម្រិតមធ្យមសិក្សាបឋមភូមិ | **.99**** | **-.95*** | 0.56 | 0.78 | **-.90*** | **.95*** |
| ៩ | អត្រាបញ្ចប់នៅកម្រិតមធ្យមសិក្សាទុតិយភូមិ | 0.87 | **-.94*** | 0.80 | **.95*** | **-.91*** | 0.79 |

* $p$ < 0.05; ** $p$ < 0.01

# ៥.ការពិភាក្សា

លទ្ធផលស្រាវជ្រាវ ផ្តល់ឱ្យនូវការយល់ដឹងយ៉ាងស៊ីជម្រៅលើដំណើរការរីកចម្រើននៃលទ្ធផលសិក្សារបស់សិស្សដែលមានភាពស៊ីចង្វាក់ទៅនឹងដំណើរការនៃការបណ្តាក់ទុនលើធនធាននៅសាលាមធ្យមសិក្សាធនធាន

ក្នុងប្រទេសកម្ពុជា។ វាបានបង្ហាញឱ្យឃើញថា លទ្ធផលការសិក្សារបស់សិស្សមានទំនាក់ទំនងខ្លាំងជាមួយនឹងសម្ភារបរិក្ខារ និងគុណវុឌ្ឍិគ្រូបង្រៀននៅសាលាមធ្យមសិក្សាធនធាន ក្នុងអំឡុងពេលប្រាំឆ្នាំសិក្សាចុងក្រោយនេះ។ ការពង្រឹង និងការអភិវឌ្ឍនូវធនធានមានផលជះខ្លាំងទៅលើលទ្ធផលសិក្សាសិស្សជាច្រើននៅសាលាមធ្យមសិក្សាធនធាន។ ពេលដែលសាលារៀនមានអគារសិក្សាល្អៗ និងមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិ អត្រាសិស្សត្រួតថ្នាក់មានទាបជាងមុន ឯអត្រាចុះឈ្មោះចូលរៀនកើនខ្ពស់ អត្រាបោះបង់ការសិក្សាមានទាបជាងមុន ចំនួនបេក្ខជនថ្នាក់ទី៩ បញ្ចប់ដោយជោគជ័យច្រើនជាងមុន និងអត្រាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាក៏ខ្ពស់ជាងមុនដែរ។ លទ្ធផលនៃការសិក្សាពេលនេះ មានភាពស៊ីគ្នាទៅនឹងការសិក្សាមុនៗមួយចំនួនដែរ (សូមមើល Akey, 2006b; MacNeil et al., 2009; Mortimore, 2001; Uline & Tschannen-Moran, 2008)។ ប៉ុន្តែ លទ្ធផលនៃការស្រាវជ្រាវនេះ ក៏មានលក្ខណៈផ្ទុយពីការសិក្សាស្រាវជ្រាវមួយចំនួន ដែលទាក់ទងទៅនឹងផលជះនៃធនធានទៅលើសមិទ្ធផលនៃការសិក្សារបស់សិស្ស (សូមមើល Coleman, 1966; Hanushek, 1981; Hanushek, 1986, 1989, 1991; Pov et al., 2020)។ នេះមានន័យថា ការអនុវត្ត និងការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាភាគីពាក់ព័ន្ធនឹងសាលាមធ្យមសិក្សាធនធានដទៃទៀត មានប្រសិទ្ធភាព និងផលិតភាពខ្ពស់ក្នុងការធានាឱ្យបានថា សាលាមធ្យមសិក្សាធនធានក្លាយជាសាលាមធ្យមសិក្សាគំរូសម្រាប់សាលាបណ្តាញ សាលារៀនក្នុងសហគមន៍ និងសាលាមធ្យមសិក្សាដទៃទៀតទូទាំងប្រទេស។ លទ្ធផលដ៏គួរឱ្យស្ងើចសរសើរទាំងនេះ មិនអាចចេញជារូបរាងបានទេ ប្រសិនបើគ្មានការចាត់ការ និងការយកចិត្តទុកដាក់យ៉ាងខ្លាំងពីក្រសួងអប់រំ យុវជន និងកីឡា សាលាមធ្យមសិក្សាធនធាន និងភាគីពាក់ពន្ធ័ដទៃទៀតក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក។

ការអង្កេតជាច្រើនបានបង្ហាញថា លទ្ធផលវិជ្ជមានសម្រាប់ការសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាធនធាន អាចមកពីការខិតខំប្រឹងប្រែង និងការធ្វើកំណែទម្រង់ផ្សេងៗជាច្រើន ក្នុងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដូចជា៖

១/ កំណែទម្រង់ការប្រឡងថ្នាក់ជាតិក្នុងឆ្នាំសិក្សា ២០១៣-២០១៤៖ កំណែទម្រង់ការប្រឡងថ្នាក់ទី ១២ មានផលជះយ៉ាងខ្លាំងទៅលើលទ្ធផលសិក្សារបស់សិស្ស តាមរយៈពាក្យស្លោកថា «ចេះគឺជាប់»។ របៀបវារៈនៃកំណែទម្រង់ការប្រឡងបានបង្កើតជាមូលដ្ឋានគ្រឹះនៃបទបញ្ញត្តិតឹងរឹង យុត្តិធម៌ និងមានតម្លាភាព ដែលជម្រុញឱ្យសិស្សខិតខំរៀនសូត្រ ដោយមិនគិតថា ការប្រឡងជាប់ និងភាពជោគជ័យចេញមកពីការលួចមើល ឬចម្លងនោះទេ។

២/ ការទទួលយកការពិត៖ លទ្ធផលនៃការប្រឡងថ្នាក់ជាតិក្នុងឆ្នាំ ២០១៣ និងតេស្ត PISA-D (សូមមើល MoEYS, 2018a) ក្នុងឆ្នាំ ២០១៧ បានបង្ហាញយ៉ាងច្បាស់ថា អន្តរាគមន៍ដ៏ចាំបាច់នេះដើម្បីពង្រឹងលទ្ធផលសិក្សារបស់សិស្ស បានក្លាយជាផ្នែកមួយយ៉ាងសំខាន់នៃយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាភាគីពាក់ព័ន្ធ។ កត្តាប្រចក្សនៃការខិតខំប្រឹងប្រែងទាំងនេះ បង្កើតបាននូវសាលាមធ្យមសិក្សាធនធាន ពីព្រោះ យោងតាមលទ្ធផលស្រាវជ្រាវបានចូលរួមចំណែកយ៉ាងចាំបាច់ក្នុងការពង្រឹងលទ្ធផលសិក្សារបស់សិស្ស។

៣/ ក្របខ័ណ្ឌតាមដាននិងវាយតម្លៃសាលាមធ្យមសិក្សាធនធាននិងប្រព័ន្ធតេស្តស្តង់ដា៖ ក្របខ័ណ្ឌតាមដាន និងប្រព័ន្ធតេស្តស្តង់ដានេះ គឺជាសសរស្តម្ភដ៏សំខាន់ ដើម្បីធានានូវតម្លាភាពក្នុងកម្រិតសាលារៀន។ ក្របខ័ណ្ឌ និងប្រព័ន្ធទាំងនេះជួយបង្ហាញនូវគុណភាពនៃការអប់រំយ៉ាងពិតប្រាកដ ទៅកាន់ភាគីពាក់ព័ន្ធក្នុងវិស័យអប់រំ ជាពិសេស ទៅកាន់សហគមន៍ និងអាណាព្យាបាល ដែលកសាងទំនុកចិត្តរវាងគ្រូបង្រៀន អាណាព្យាបាល ភាគីពាក់ព័ន្ធ ក្នុងការតាមដានលទ្ធផលសិក្សារបស់សិស្ស និងចូលរួមធនធាន។

ម៉្យាងវិញទៀត ការសិក្សាស្រាវជ្រាវបានបង្ហាញអំពីតម្រូវការសម្រាប់ការពង្រឹង និងការវិនិយោគបន្ថែមទៀត ដើម្បីធានានូវការអភិវឌ្ឍប្រកបដោយចីរភាពទៅលើសាលាមធ្យមសិក្សាធនធាន ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យ និងមហិច្ឆតារបស់ក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ឆ្នាំ ២០៣០ និង ២០៥០។ បើទោះបី លទ្ធផលស្រាវជ្រាវបានបង្ហាញថា សម្ភារបរិក្ខារ និងគុណវុឌ្ឍិគ្រូបង្រៀនមានការផ្សារភ្ជាប់ទៅនឹងលទ្ធផលការសិក្សារបស់សិស្សក៏ដោយ ប្រទេសកម្ពុជានៅតែប្រឈមដើម្បីផ្តល់ការគាំទ្រ និងពង្រឹងសាលាមធ្យមសិក្សាធនធាន និងគ្រប់សាលារៀនផ្សេងៗទៀត នៅគ្រប់កម្រិតទូទាំងប្រទេស។ ការខិតខំប្រឹងប្រែង និងឆន្ទៈដ៏មុតមាំ របស់ក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់នូវសម្ភារបរិក្ខារទំនើប និងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន អាចទទួលបាននូវផលចំណេញ។ ជាការពិតណាស់ កង្វះសម្ភារបរិក្ខារសាលារៀន និងគុណវុឌ្ឍិគ្រូបង្រៀនជាបញ្ហាសាមញ្ញមួយដែលប្រទេសកំពុងអភិវឌ្ឍ បានកំពុងប្រឈមជាច្រើនទសវត្សរ៍មកហើយ (សូមមើល Akey, 2006a; Kimani, Kara, & Njagi, 2013; Rockoff, 2004)។ ខណៈ ប្រទេសកំពុងអភិវឌ្ឍ រួមទាំងប្រទេសកម្ពុជា ក៏កំពុងតែស្វះស្វែងក្នុងការពង្រឹងប្រព័ន្ធអប់រំតាមរយៈធនធានដែលមានស្រាប់របស់ខ្លួន។ ប្រទេសទាំងនេះ ក៏ខិតខំតាមឱ្យទាន់និន្នាការអប់រំ ការរីកចម្រើននៃការអប់រំក្នុងតំបន់ និងពិភពលោកកំពុងវិវត្តដំណើរការទៅមុខ។ ដូច្នេះ ការបែងចែកធនធានដោយខិតខំប្រឹងប្រែង ដើម្បីបំពេញតម្រូវការចាំបាច់ពិសេសចំពោះប្រទេសជាតិ និងគោលបំណងរយៈពេលវែងក្នុងវិស័យអប់រំ និងការអភិវឌ្ឍជាសកល។

## ៦. ផលប៉ះពាល់

ការសិក្សាស្រាវជ្រាវនេះ បានផ្តល់នូវការយល់ដឹងទាក់ទងនឹងការផ្សារភ្ជាប់រវាងការបែងចែកធនធាន និងលទ្ធផលការសិក្សារបស់សិស្សនៅសាលាមធ្យមសិក្សាធនធាន អស់រយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ ការសិក្សាមួយនេះ ផ្តល់លទ្ធផលពាក់ព័ន្ធសំខាន់សម្រាប់ការអនុវត្ត និងគោលនយោបាយ។ លទ្ធផលបានបង្ហាញថា សម្ភារបរិក្ខារសាលារៀននិងគុណវុឌ្ឍិគ្រូបង្រៀនដើរតួយ៉ាងសំខាន់ក្នុងការកំណត់លទ្ធផលការសិក្សារបស់សិស្ស។ ដូច្នេះ លទ្ធផលពាក់ព័ន្ធមួយចំនួនអាចយកមកពិចារណាបាន។ ទីមួយ ការបន្តសាងសង់អគារសិក្សាដោយសំណង់ពីបេតុង និងកាត់បន្ថយអគារឈើជាចាំបាច់។ ថ្នាក់រៀននីមួយៗត្រូវតែបំពាក់ដោយសម្ភារបរិក្ខាររៀន និងបង្រៀនឱ្យបានគ្រប់គ្រាន់សម្រាប់មុខវិជ្ជាផ្សេងៗ ក្នុងកម្មវិធីសិក្សា ជាពិសេស មុខវិជ្ជាវិទ្យាសាស្ត្រ ដែលទាមទារសម្ភារៈរៀន និងបង្រៀនឱ្យច្រើនបែប។ ទីពីរ កម្មវិធីលើកកម្ពស់គ្រូបង្រៀន បណ្តុះបណ្តាលគ្រូបង្រៀន អភិវឌ្ឍគុណវុឌ្ឍិ

គ្រូបង្រៀន ត្រូវតែពង្រឹង និងជម្រុញបន្ថែម។ យើងមានកម្មវិធីពង្រឹងគ្រូបង្រៀនជាច្រើនរួចមកហើយ (កម្មវិធីអភិវឌ្ឍសមត្ថភាព និងអភិវឌ្ឍអាជីពជាគ្រូបង្រៀន) ដូចជា កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (TUP) នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងអាហារូបករណ៍សម្រាប់គ្រូបង្រៀន។ សាលារៀនទាំងអស់គួរតែជំរុញលើកទឹកចិត្តគ្រូបង្រៀន ឱ្យចេះចាប់យកឱកាសក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីបង្កើនផលប្រយោជន៍សម្រាប់ខ្លួនឯងផង មិនត្រឹមតែប៉ុណ្ណោះ ដើម្បីបង្កើនផលជះទៅលើលទ្ធផលសិក្សារបស់សិស្សទាំងអស់ផងដែរ។ ចំណុចចុងក្រោយ សាលាមធ្យមសិក្សាធនធានគួរតែបន្តពង្រឹង និងលើកកម្ពស់ការអនុវត្ត ដោយស្វ័យភាព គណនេយ្យភាព និងការវាយតម្លៃ។ ការអនុវត្តនេះ អាចធ្វើឱ្យសាលាមធ្យមសិក្សាធនធានខុសពីសាលាមធ្យមសិក្សាដទៃទៀត ដោយសារតែប្រសិទ្ធភាពក្នុងការជំរុញឱ្យមានតម្លាភាព និងយុត្តិធម៌ នៅសាលារៀនសម្រាប់លទ្ធផលសិក្សារបស់សិស្សឱ្យបានកាន់តែប្រសើរ។ លទ្ធផលនៃសិក្សាស្រាវជ្រាវនេះ បានបង្ហាញនូវសន្ទស្សន៍ល្អជាជំហានៗបន្តសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹង និងអភិវឌ្ឍប្រព័ន្ធសាលារៀន និងគ្រូបង្រៀន ដើម្បីពង្រឹងសមិទ្ធផលរបស់សាលារៀនតទៅទៀត។

## ៧. សរុបសេចក្តី

ការសិក្សាស្រាវជ្រាវនេះ បានចូលរួមស្វែករកការចែករំលែកក្នុងការវាយតម្លៃលើការរីកចម្រើននិងប្រសិទ្ធភាពនៃការបែងចែកធនធានទៅកាន់សាលាមធ្យមសិក្សាធនធានក្នុងប្រទេសកម្ពុជា។ ក្នុងចំណោម ៣២ អថេរនៃបួនកត្តាធំៗ មានអថេរជាច្រើនទាក់ទងនឹងកត្តាហេដ្ឋារចនាសម្ព័ន្ធ និងកត្តាធនធានមនុស្ស ត្រូវបានគេរកឃើញថាមានទំនាក់ទំនងអវិជ្ជមានជាមួយអថេរលទ្ធផលការសិក្សារបស់សិស្ស។ការកាត់បន្ថយអគារឈើ តែងផ្សារភ្ជាប់ទៅនឹងកំណើននៃលទ្ធផលការសិក្សារបស់សិស្ស ដូចជា៖ អត្រារៀនត្រួតថ្នាក់ អត្រាចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ក៏ដូចជាភាពជោគជ័យរបស់សិស្សដែលបញ្ចប់ថ្នាក់ទី៩ និងអត្រាបញ្ចប់ទាំងកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។ ការបង្កើនសាលារៀនពីបេតុង មានទំនាក់ទំនងអវិជ្ជមានទៅនឹងចំនួនសិស្សត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ភាពជោគជ័យនៃបេក្ខជនថ្នាក់ទី៩ អត្រាបញ្ចប់ការសិក្សា និងអត្រាចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ស្របពេលជាមួយគ្នានេះដែរ វាមានទំនាក់ទំនងអវិជ្ជមានជាមួយអត្រាត្រួតថ្នាក់នៅកម្រិតធម្យមសិក្សាទុតិយភូមិ កាលដែលសាលារៀនបង្កើនការិយាល័យដាច់ដោយឡែក មានទំនាក់ទំនងវិជ្ជមានទៅនឹងអត្រាចុះឈ្មោះចូលរៀននៅក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ។ គ្រូបង្រៀន ដែលមានកម្រិតវប្បធម៌ត្រឹមមធ្យមសិក្សាបឋមភូមិមានទំនាក់ទំនងវិជ្ជមានខ្លាំងទៅនឹងចំនួនសិស្សត្រួតថ្នាក់ និងអត្រាចុះឈ្មោះចូលរៀនក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ អត្រាចុះឈ្មោះចូលរៀនក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ នៅកម្រិតទុតិយភូមិ។ គ្រូបង្រៀនដែលមានចំណេះដឹងត្រឹមមធ្យមសិក្សាបឋមភូមិ មានទំនាក់ទំនងអវិជ្ជមាននឹងអត្រារៀនត្រួតថ្នាក់ក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ អត្រាចុះឈ្មោះចូលរៀន និងអត្រាសិស្សបោះបង់ការសិក្សាក្នុងកម្រិតបឋម និងមធ្យមសិក្សាទុតិយភូមិ។ គ្រូបង្រៀនដែលមានកម្រិតវប្បធម៌ត្រឹមមធ្យម

សិក្សាទុតិយភូមិ ត្រូវបានគេរកឃើញថា មានទំនាក់ទំនងអវិជ្ជមានទៅនឹងចំនួនសិស្ស និងអត្រាចុះឈ្មោះចូលរៀនក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ អត្រាចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ភាពជោគជ័យនៃបេក្ខជនថ្នាក់ទី៩ អត្រាបញ្ចប់ការសិក្សាកម្រិតបឋមភូមិនិងអត្រាបញ្ចប់ការសិក្សាកម្រិតទុតិយភូមិ។ វាក៏បានបង្ហាញផងដែរថាមានទំនាក់ទំនងអវិជ្ជមានទៅនឹងអត្រារៀនត្រួតថ្នាក់នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ជាចុងក្រោយ គ្រូដែលមានកម្រិតវប្បធម៌ក្រោយឧត្តម ត្រូវបានគេរកឃើញថា មានទំនាក់ទំនងវិជ្ជមានទៅនឹងចំនួនសិស្ស និងអត្រាចុះឈ្មោះចូលរៀនក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ ភាពជោគជ័យរបស់បេក្ខជនថ្នាក់ទី៩ និងអត្រាបញ្ចប់ការសិក្សាកម្រិតបឋមភូមិ។ ការមានគ្រូបង្រៀន ដែលមានកម្រិតវប្បធម៌ក្រោយឧត្តម ត្រូវបានគេរកឃើញថា មានទំនាក់ទំនងអវិជ្ជមានទៅនឹងអត្រាសិស្សរៀនត្រួតថ្នាក់ក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ។

## ឯកសារយោង


Aaronson, D., Barrow, L., & Sander, W.(2007). Teachers and student achievement in the Chicago public high schools. *25*(1), 95-135.

Abrami, P. C., Cohen, P. A., & d'Apollonia, S.(1988). Implementation problems in meta-analysis. *58*(2), 151-179.

Akey, T. M. (2006a). School Context, Student Attitudes and Behavior and Academic Achievement: An Exploratory Analysis. *MDRC*.

Akey, T. M. (2006b). School Context, Student Attitudes and Behavior, and Academic Achievement: An Exploratory Analysis. *MDRC*.

Christle, C. A., Jolivette, K., Nelson,, C.M. (2007). School characteristics related to high school dropout rates. *28*(6), 325-339.

Coleman, J. S. (1966). Equality of educational opportunity. US Department of Health, Education, and Welfare, Office of Education.

Hanushek, E. A. (1981). Throwing money at schools. *Journal of Policy Analysis and Management, 1*(1), 19-41.

Hanushek, E. A. (1986). The economics of schooling: Production and efficiency in public schools. *Journal of economic literature, 24*(3), 1141-1177.

Hanushek, E. A. (1989). The impact of differential expenditures on school performance. *Educational researcher, 18*(4), 45-62.

Hanushek, E. A. (1991). When school finance reform may not be good policy. *Harv. J. on Legis., 28*, 423-423.

Hoy, W. K., & Sabo, D. J. (1998). *Quality middle schools: Open and healthy*: ERIC.

Kimani, G. N., Kara, A. M., & Njagi, L. W. (2013). Teacher Factors Influencing Students' Academic Achievement in Secondary Schools in Nyandarua county, Kenya.

Leithwood, K., Louis, K. S., Anderson, S., & Wahlstrom, K. (2004). How Leadership Influences Student Learning. Review of Research. The *Wallace Foundation*.

Ma, X., & Klinger, D. A. (2000). Hierarchical linear modelling of student and school effects on academic achievement. *Canadian Journal of Education/Revue canadienne de l'education*, 41-55.

MacNeil, A. J., Prater, D. L., & Busch, S. (2009). The effects of school culture and climate on student achievement. *International Journal of Leadership in Education, 12*(1), 73-84.

MoEYS. (2008). *Secondary Resource School Policy*. Phnom Penh, Cambodia

MoEYS. (2018a). *Education in Cambodia: Findings from Cambodia's experience in PISA for Development*.

MoEYS. (2018b). *Secondary Resource Schools Policy.* Phnom Pehn, Cambodia.

Mortimore, P. (2001). Globalisation, effectiveness and improvement. *School Effectiveness and School Improvement, 12*(2), 229-249.

Pov, S., Kawai, N., & Matsumiya, N. (2020). Determinants of student achievement at lower secondary schools in rural Cambodia. *Educational Research for Policy and Practice*, 1-16.

Quinn, J. (2013). Drop-out and completion in higher education in Europe among students from under-represented groups.

Rockoff, J. E. 2004). The impact of individual teachers on student achievement: Evidence from panel data. *94*(2), 247-252.

Schreiber, J. B. (2002). Institutional and student factors and their influence on advanced mathematics achievement. *The Journal of Educational Research, 95*(5), 274-286.

Stewart, E. B. (2007). Individual and school structural effects on African American high school students' academic achievement. *The High School Journal, 91*(2), 16-34.

Uline, C., & Tschannen-Moran, M. (2008). The walls speak: The interplay of quality facilities, school climate, and student achievement. *Journal of Educational Administration, 46*(1), 55-73.

World Bank. (2005). *Quality Basic Education For All*.

**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវ

# ការសិក្សាពីឥរិយាបថនៃចំណេះដឹង និងការប្រើប្រាស់កុំព្យូទ័របន្ទះ សម្រាប់ការរៀន និងបង្រៀននៅសាលាមធ្យមសិក្សាធនធាន

ឈិញ នីដា [*១] អ៊ីវ ច័ន្ទណារ៉ា [២] ឈឹម ឫទ្ធិវង្ស [៣]

[*១] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រទេសកម្ពុជា អ៊ីមែលរបស់អ្នកនិពន្ធ៖ *chhinh.nyda@rupp.edu.kh*

[២ ៣] នាយកដ្ឋានគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា

បានទទួល៖ ខែមេសា ២០២១ សម្រេចយក៖ ខែមិថុនា ២០២១

## សង្ខិត្តន័យ

ការរៀន និងបង្រៀន ជាដំណើរការអន្តរកម្មរវាងកត្តាបីធំៗគឺ គ្រូបង្រៀន សិស្ស និងសម្ភារៈសិក្សា។ កត្តាទាំងបីនេះ មានសារៈសំខាន់សម្រាប់គុណភាពរៀន និងបង្រៀននៅគ្រប់កម្រិតមធ្យមសិក្សា។ នៅដើមឆ្នាំ ២០២០ ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងអប់រំ យុវជន និងកីឡាបានប្រគល់ទូដែលមានកុំព្យូទ័របន្ទះដល់សាលាមធ្យមសិក្សាធនធាន ហើយបានអញ្ជើញគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ មកចូលរួមវគ្គបណ្តុះបណ្តាលពីការប្រើប្រាស់កុំព្យូទ័របន្ទះ និងអែប (Apps)។ ការសិក្សានេះ ផ្តោតលើបួនចំណុចធំៗគឺ ១) ការវាស់ពីចំណេះដឹងលើទិដ្ឋភាពទូទៅរបស់សិស្សនិងគ្រូ ដែលទាក់ទងនឹងការសិក្សាដោយមានជំនួយពីប្រព័ន្ធព័ត៌មាន និងសារគមនាគមន៍ ២) ការវាស់ពីចំណេះដឹងលើការប្រើប្រាស់កម្មវិធីសិក្សា ក្រោយពីការចូលរួមបណ្តុះបណ្តាល ដោយនាយកដ្ឋានព័ត៌មានវិទ្យានៃក្រសួងអប់រំ យុវជន និងកីឡា ៣) ការវាស់លើឥរិយាបថរបស់គ្រូ និងសិស្សក្នុងការប្រើប្រាស់អែប ដូចជា កម្រិតនៃការទទួលស្គាល់គុណតម្លៃលើការប្រើប្រាស់អែបសម្រាប់ការរៀន

និងបង្រៀន និង ៤) ការវាស់លើការអនុវត្តលើការប្រើប្រាស់កុំព្យូទ័របន្ទះ តាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។ យោងតាមលទ្ធផលស្រាវជ្រាវបង្ហាញថា គ្រូនៅតាមសាលាធនធាន នៅមិនទាន់បានត្រៀមខ្លួនរួចរាល់ក្នុងការបង្រៀនតាមអែប និងតាមតាំផែលនៅឡើយទេ(បំណែកនៃគ្រឿងអេឡិចត្រូនិចដើម្បីរក្សាទុកមាតិកា និងចែករំលែកមាតិកាទៅកាន់កុំព្យូទ័របន្ទះ ឬទូរសព្ទឆ្លាតវៃ)។ មានឧបសគ្គមួយចំនួនដែលរារាំងដំណើរការបង្រៀន រួមមាន ជំនាញបច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពភាសាអង់គ្លេសនៅមានកម្រិត។ ចំណែក ឯតាំផែលវិញ គ្រូមួយចំនួនធំយល់ថា វាមានភាពប្រសើរណាស់សម្រាប់ការបង្រៀនរបស់ខ្លួន ពីព្រោះគ្រូអាចបង្ហាញសិស្សពីទ្រឹស្តីបានងាយជាងការពន្យល់ធម្មតា។ ដោយសារតែតាំផែលទើបតែបានដាក់ឱ្យប្រើប្រាស់នៅតាមវិទ្យាល័យធនធាន ការសិក្សានេះមិនទាន់អាចសន្និដ្ឋានបានថា គ្រូបង្រៀននិងសិស្សមិនចូលចិត្តប្រើប្រាស់តាំផែល ឬអែបសម្រាប់ការរៀននិងបង្រៀនទេ។ នៅក្នុងការបន្ថែមទៅលើការបង្រៀន គ្រូបង្រៀនប្រើប្រាស់តាំផែល ដើម្បីពន្យល់គំនិតយោបល់បានកាន់តែប្រសើរ។ ក្រៅតែពីការបង្រៀន គ្រូអាចប្រើវាដើម្បីពន្យល់មេរៀន ហើយសិស្សក៏អាចផ្ទៀងផ្ទាត់ចម្លើយបានព្រមគ្នា។ ម្យ៉ាងទៀត គ្រូបង្រៀនអះអាងថា ការប្រើប្រាស់អែបគឺងាយស្រួលណាស់ ដោយសារពួកគាត់អាចប្រើប្រាស់បានគ្រប់ពេល និងគ្រប់ទីកន្លែង បើទោះបី គ្មានអ៊ីនធឺណិតក៏ដោយ។

**ពាក្យគន្លឹះ៖** កុំព្យូទ័របន្ទះ ការសិក្សាវិទ្យាសាស្ត្រ អ៊ីនធឺណិត ការអប់រំពីចម្ងាយ អែប (App)។

**អាគតដ្ឋាន:** ឈិញ, ន., អ៊ីវ, ច., & ឈឹម, រ. (២០២១). ការសិក្សាពីឥរិយាបថនៃចំណេះដឹង និងការប្រើប្រាស់កុំព្យូទ័របន្ទះសម្រាប់ការរៀន និងបង្រៀននៅសាលាមធ្យមសិក្សាធនធាន. *កាលិកបត្រអប់រំកម្ពុជា,* ៤(១),១៥-៤១។

## ១. សេចក្តីផ្តើម

ការរៀន និងបង្រៀន ជាដំណើរការអន្តរកម្មរវាងកត្តាបីធំៗគឺ៖ គ្រូបង្រៀន សិស្ស និងសម្ភារៈសិក្សា។ កត្តាទាំងបីនេះ មិនអាចញែកឱ្យដាច់ពីគ្នាបានទេ នៅពេលយើងនិយាយពីគុណភាពនៃការរៀន និងបង្រៀននៅគ្រប់កម្រិតមធ្យមសិក្សា។ ក្នុងក្របខណ្ឌវាយតម្លៃរបស់ PISA (Programme for International Student Assessment) វាអាចបង្ហាញថា មានសូចនាករជាច្រើនដែលក្តោបកត្តាបីខាងលើ ជាឧទាហរណ៍ OECD, (2010)។ ដោយឈរលើភាពចាំបាច់នៃកត្តាទាំងបីនេះ យើងសង្កេតឃើញថា កម្ពុជាបាននឹងកំពុងពង្រឹងនិងពង្រីកកត្តាទាំងបីនេះព្រមៗគ្នា ជាពិសេស ក្នុងអាណត្តិនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំចុងក្រោយនេះ (MoEYS, 2019)។ ដើម្បីបញ្ជាក់ថា តើគុណភាពអប់រំមានការប្រែប្រួល ឬមិនប្រែប្រួលយ៉ាងណា គេត្រូវតែពិនិត្យមើលលើតុល្យភាពនៃកត្តាទាំងបីនេះ។ តែដោយសារ

វិសាលភាពនៃការពង្រឹង និងពង្រីកលើគុណភាពគ្រូ និងសិស្សមានភាពធំទូលាយពេកសម្រាប់ការស្រាវជ្រាវមួយនេះក៏ដោយ ក៏ការសិក្សានេះផ្ដោតលើតែកត្តាសម្ភារៈសិក្សា ពោលគឺសិក្សាពីផលជះនៃការប្រើជាប្រយោជន៍លើកុំព្យូទ័របន្ទះ ដែលក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យប្រើប្រាស់ ជាផ្នែកនៃគម្រោងអភិវឌ្ឍន៍ វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP)។

កន្លងមក ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើទំនើបកម្មជាច្រើនដំណាក់កាល រួមមាន ការបំពាក់សម្ភារៈសិក្សាដល់សាលារៀន ជាពិសេសការបង្កើននូវសាលាមធ្យមសិក្សាធនធាន ដោយរួមមាន អគារធំទូលាយសម្រាប់ការអប់រំស្ពែម និងសម្ភារៈសម្រាប់ពិសោធន៍។

ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡាក៏បានចាប់ផ្ដើមបំពាក់ឧបករណ៍ទំនើបមួយទៀតសម្រាប់សម្រួលដល់ការរៀននិងបង្រៀនថ្នាក់វិទ្យាសាស្ត្រនិងគណិតវិទ្យា។ ទូកុំព្យូទ័របន្ទះចល័ត (ToW) តូចល្មម ដែលអាចឱ្យគេយកពីថ្នាក់មួយទៅថ្នាក់មួយទៀតបាន។ ទូកុំព្យូទ័របន្ទះចល័តមានកម្មវិធីស្រាប់ (ToW) មានចំនួន៣០ គ្រឿង និងដុំស្តុកទិន្នន័យមេរៀនមួយគ្រឿងដែលអាចបញ្ជូនទិន្នន័យ ឬមេរៀនទៅក្នុងកុំព្យូទ័របន្ទះតាមរយៈបណ្ដាញវ៉ាយហ្វាយ (WiFi) ក្រៅពីវ៉ាផែល។ កុំព្យូទ័របន្ទះនីមួយៗមានអែបជាច្រើន ដែលផ្ទុកកម្មវិធីសិក្សាតាមមុខវិជ្ជាផ្សេងៗ និងច្រើនកម្រិតសិក្សា ជាពិសេស ថ្នាក់មធ្យមសិក្សាទុតិយភូមិ។

នៅដើមឆ្នាំ ២០២០ ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី បានប្រគល់ទូមានកុំព្យូទ័របន្ទះជូនវិទ្យាល័យធនធាន ហើយបានអញ្ជើញគ្រូៗទទួលបន្ទុកបង្រៀនវិទ្យាសាស្ត្រនៅតាមវិទ្យាល័យធនធាន មកចូលរួមវគ្គបណ្ដុះបណ្ដាលពីការប្រើប្រាស់កុំព្យូទ័របន្ទះ និងការបង្រៀនដោយប្រើអែបនេះ ដោយមានគ្រូឧទ្ទេសមកពីនាយកដ្ឋានព័ត៌មានវិទ្យានៃក្រសួងអប់រំ យុវជន និងកីឡា និងគ្រូឧទ្ទេសជំនាញថ្នាក់ជាតិតាមមុខវិជ្ជា។ ក្រោយពីវគ្គបណ្ដុះបណ្ដាលនេះ គ្រូវិទ្យាសាស្ត្រ និងគណិតវិទ្យាទាំងនេះនឹងបង្រៀនមុខវិជ្ជារបស់ខ្លួនដោយប្រើប្រាស់អែប នៅក្នុងថ្នាក់រៀនតាមការចាំបាច់។

## ១.១ សនិទាន

ដើម្បីឈានទៅរកភាពជឿនលឿននិងជោគជ័យក្នុងដំណើរការបច្ចេកវិទ្យា និងការរីកចម្រើនផ្នែកសេដ្ឋកិច្ច ប្រទេសនីមួយៗបាននឹងកំពុងប្រណាំងប្រជែងគ្នាលើគ្រប់វិស័យ ដោយវិស័យអប់រំ ស្ថិតនៅជួរមុខគេក្នុងការប្រណាំងប្រជែងនេះ។ ប្រទេសខ្លះ បានកែប្រែកម្មវិធីសិក្សា និងប្ដូរវិធីសាស្ត្របង្រៀន ដោយបញ្ចូលបច្ចេកវិទ្យាប្រព័ន្ធព័ត៌មានវិទ្យាក្នុងកម្មវិធីសិក្សា។ ការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញថា កុំព្យូទ័របន្ទះបានជួយពង្រឹងការអាន ជាពិសេសសម្រាប់សិស្សរៀនយឺត (Berson, Berson, & McGlinn Manfra, 2012; Thoermer & Williams, 2012) និងជួយសម្រួលដល់ការបង្រៀន (Berson et al., 2012)។ ការអនុវត្តសាកល្បងមួយនៅសហរដ្ឋអាមេរិកបង្ហាញថា ការរៀន និង

បង្រៀនមុខវិជ្ជាគណិតវិទ្យា វាមានឥទ្ធិពលក្នុងការប្រើប្រាស់កុំព្យូទ័របន្ទះក្នុងចំណោមសិស្សជាច្រើន ដោយសារសិស្សអាចសរសេរកត់ត្រាមេរៀនក្នុងកុំព្យូទ័របន្ទះ ដែលមានពណ៌គ្រប់គ្រាន់ (Fister & McCarthy, 2008)។

ក្នុងយុគសម័យឧស្សាហកម្ម ៤.០ និងភាពសម្បូរបែបនៃបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(អាយស៊ីធី) ការសិក្សាមួយចំនួនមើលទៅលើបច្ចេកវិទ្យា ដើម្បីជំនួយដល់ការសិក្សាសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ។ តាមការពិសោធរបស់ Finkelstein, Adams, Keller, Perkins, and Wieman (2006) បានបង្ហាញថា លទ្ធផលសិក្សារូបវិទ្យា គឺបានលទ្ធផលខ្ពស់ ប្រសិនបើ បានប្រើប្រាស់កុំព្យូទ័របន្ទះ ជំនួសការបង្រៀនបែបប្រពៃណី។ ការរៀន និងបង្រៀននូវមុខវិជ្ជាវិទ្យាសាស្ត្រគឺមានប្រសិទ្ធភាពខ្ពស់ នៅពេលគាំទ្រដោយប្រព័ន្ធព័ត៌មាន ហើយជាពិសេស វាទទួលបានចំណាប់អារម្មណ៍ជាខ្លាំងសម្រាប់សិស្ស អ្នកដែលបានអះអាងស្រដៀងគ្នានេះដែរ រួមមាន Doering, Koseoglu, Scharber, Henrickson, ហើយ Lanegran (2014) សម្រាប់មុខវិជ្ជាភូមិវិទ្យា Shim et al. (2003) ជីវវិទ្យា និង Huang (2015) សម្រាប់គីមីវិទ្យា។

បើតាម Hu and Garimella (2014) បានអះអាងថា ចំណេះដឹងនៃកុំព្យូទ័របន្ទះពីវគ្គបណ្តុះបណ្តាលដែលបានបន្ថែមសមត្ថភាពគ្រូស្តែមដើម្បីបង្រៀន និងវាយតម្លៃលើការសិក្សារបស់សិស្ស។ ក្នុងការសិក្សាលម្អិតលើរបាយការណ៍ស្រាវជ្រាវចំនួន ៣៣ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់កុំព្យូទ័របន្ទះក្នុងថ្នាក់រៀនរបស់ Major, Haßler, and Hennessy (2017) បង្ហាញថា ជាទូទៅ ការប្រើប្រាស់កុំព្យូទ័របន្ទះមានភាពពាក់ព័ន្ធទៅនឹងសកម្មភាពសិក្សារបស់សិស្សឱ្យបានល្អប្រសើរ។ ខណៈពេល ប្រទេសអភិវឌ្ឍន៍បានទទួលជោគជ័យក្នុងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យអប់រំ សំនួរនៅតែមានសួរថា តើកម្ពុជាស្ថិតក្នុងដំណាក់កាលណា ក្នុងការប្រើប្រាស់អាយស៊ីធី? ហើយយើងគួរប្រើវាក្នុងវិស័យអប់រំបានយ៉ាងដូចម្តេច? ស្របពេលគ្នានៃការពង្រាងអត្ថបទស្រាវជ្រាវ ប្រព័ន្ធអ៊ិនធឺណិត នៅកម្ពុជាបានគ្របដណ្តប់ស្ទើរពេញផ្ទៃប្រទេសតាមរយៈក្រុមហ៊ុនទូរស័ព្ទចល័ត ដូចជា សែលកាត ឬតាមបណ្តាញខ្សែកាបដូចជា EZECOM។ នៅត្រឹមឆ្នាំ ២០១៨ កម្ពុជាមានអ្នកចុះឈ្មោះប្រើប្រាស់អ៊ិនធឺណិតចំនួន ១២ លាននាក់។ ចំនួននៃអ្នកប្រើប្រាស់អ៊ិនធឺណិតមិនផ្តល់ព័ត៌មានលម្អិតឱ្យយើងដឹងថា ពួកគេប្រើប្រាស់សម្រាប់ហេតុផលអ្វីនោះទេ ប៉ុន្តែវាឱ្យយើងដឹងច្បាស់ថា អ្នកអប់រំមួយចំនួនបានបង្កើត និងបង្កើនការអប់រំតាមមេរៀនសម្រាប់ឱ្យសិស្ស តាមរយៈការបង្រៀនអនឡាញ ដូចជា E-School Cambodia ឬ Sangapac.com ក្រសួងអប់រំ យុវជន និងកីឡាក៏បានបង្កើតអែប និងវេបសាយសម្រាប់ការរៀន និងបង្រៀន រួមមាន MoEYS App Scan ឬ http://www.krou.moeys.gov.kh/kh/។

### ១.២ សំណួរ និងវត្ថុបំណងស្រាវជ្រាវ

ការសិក្សានេះ ផ្ដើមដោយសំណួរថា តើការប្រើប្រាស់កុំព្យូទ័របន្ទះសម្រាប់ការបង្រៀន និងរៀនមានវិសាលភាពកម្រិតណា នៅក្នុងប្រទេសកម្ពុជា? ហើយត្រូវប្រើប្រាស់កុំព្យូទ័របន្ទះ ដើម្បីអនុវត្តឱ្យបានទទួលជោគជ័យ យ៉ាងដូចម្ដេច?

ក្នុងការសិក្សានេះ យើងនឹងសិក្សាពិសោធលើចំណេះដឹង ទម្លាប់ និងការអនុវត្តការប្រើប្រាស់កុំព្យូទ័របន្ទះក្នុងការបង្រៀន និងរៀនរបស់គ្រូ និងសិស្សនៅតាមសាលាវិទ្យាល័យធនធាន ពាក់ព័ន្ធនឹងមុខវិជ្ជា STEM ។ ការសិក្សានេះនឹងផ្ដោតលើបួនចំណុចធំៗគឺ៖ ១) ការវាស់ពីចំណេះដឹងលើទិដ្ឋភាពទូទៅរបស់សិស្ស និងគ្រូទាក់ទងនឹងការសិក្សាដោយមានជំនួយពីប្រព័ន្ធបច្ចេកវិទ្យា និងសារគមនាគមន៍ ២) ការវាស់ពីចំណេះដឹងលើការប្រើប្រាស់កម្មវិធីសិក្សា ក្រោយពីការបណ្ដុះបណ្ដាលរបស់នាយកដ្ឋានព័ត៌មាន នៃក្រសួងអប់រំ ៣) ការវាស់លើឥរិយាបថរបស់គ្រូនិងសិស្សក្នុងការប្រើប្រាស់អែប ឬកម្រិតនៃការទទួលស្គាល់គុណតម្លៃនៃការប្រើប្រាស់អែបសម្រាប់ការរៀននិងបង្រៀន និង ៤) ការវាស់លើការអនុវត្តការប្រើប្រាស់កុំព្យូទ័របន្ទះចល័ត។ ក្រៅពីទិដ្ឋភាពទាំងបួនខាងលើ ការសិក្សាស្រាវជ្រាវនឹងសិក្សាទៅលើបញ្ហាប្រឈម និងឱកាសដោយប្រើប្រាស់ការវិភាគតាម SWOT[1] ទាក់ទងនឹងការពង្រឹង និងពង្រីកសកម្មភាពប្រើប្រាស់អែបនោះផងដែរ ជាពិសេស គឺផ្ដោតលើការធ្វើស្វ័យសិក្សារបស់សិស្ស ដោយមានការសម្របសម្រួលការសិក្សាតាមអនឡាញ។

## ២. ទំព្ទកទ្រឹស្ដី

ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៨០ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (អាយស៊ីធី) បានដាក់បញ្ចូលក្នុងវិស័យអប់រំនៃប្រទេសជឿនលឿនមួយចំនួនដូចជា អ៊ីតាលី និងសហរដ្ឋអាមេរិក (Sharples, Taylor, & Vavoula, 2010)។ ក្រាហ្វក្រោមនេះបង្ហាញពីការវិវត្តនៃការប្រើប្រាស់អាយស៊ីធី នៅក្នុងថ្នាក់រៀន ដែលអាចចែកចេញទៅជាបួនដំណាក់កាលធំៗ មុនពេលមានបច្ចេកវិទ្យាកុំព្យូទ័របន្ទះ។ ដំណាក់កាលទីមួយ ការរៀនតាមរយៈសារសម្លេង ដូចជាវិទ្យុ ខ្សែភាពយន្ត និងម៉ាស៊ីនបញ្ចាំងស្លាយ (ដូចបង្ហាញក្នុងក្រាហ្វ ១)។ ដំណាក់កាលទីពីរ ការបង្រៀនតាមវីដេអូក្នុង

[1] ការវិភាគ SWOT គឺជាការចងក្រងនូវចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងលើការរៀននិងបង្រៀន ដោយប្រើប្រាស់ Tablets on Wheel (ToW)។ គោលបំណងចម្បងនៃការវិភាគ SWOT គឺដើម្បីជួយឱ្យការប្រើប្រាស់ ToW អភិវឌ្ឍការយល់ដឹងពេញលេញអំពីកត្តាទាំងអស់ដែលរួមចំណែកដល់ការបង្កើតលទ្ធផលរបស់ USESDP។

ទម្រង់ជា ដុំកាសែតវីដេអូ និងទូរទស្សន៍។ ដំណាក់កាលបន្ទាប់ពីរទៀត ពាក់ព័ន្ធខ្លាំងនឹងការប្រើកុំព្យូទ័រ (ជាពិសេស កុំព្យូទ័រយួរដៃ) សម្រាប់ការរៀន និងការបង្រៀន។




**ក្រាហ្វ ១៖** ពេលវេលានៃការវិវត្តបច្ចេកវិទ្យានៅក្នុងថ្នាក់រៀន

គេបានព្យាករថា សិស្សម្នាក់ៗនៅសហរដ្ឋអាមេរិកនឹងមានកុំព្យូទ័របន្ទះគ្រប់គ្នានៅឆ្នាំ ២០២០ នេះ (Norris & Soloway, 2015)។ ការដាក់បញ្ចូលបច្ចេកវិទ្យាក្នុងវិស័យអប់រំរីកចម្រើនកាន់តែច្រើនឡើង ដោយណែនាំនូវកុំព្យូទ័របន្ទះដំបូងៗ និងអែបដែលអាចរកបានយ៉ាងទូលំទូលាយតាមរយៈអនឡាញ ដូចជា Google Play store និង Apple Apps ជាដើម។ បើតាមការសិក្សាដោយ Clayton and Murphy (2016) ការប្រើប្រាស់អែបបានបើកសេរីភាពសម្រាប់សិស្សដើម្បីទទួលបានចំណេះដឹងបន្ថែម និងអភិវឌ្ឍអ្វីដែលបានរៀនក្នុងថ្នាក់រៀន ឧទាហរណ៍ Khan Academy។ នៅក្នុង Apple Store មានអែប យ៉ាងហោចណាស់ ១០០០ សម្រាប់ការអប់រំ ដោយមិនបាច់បង់ថ្លៃ (Watlington, 2011)។ ក្នុងគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP) នាយកដ្ឋានព័ត៌មានវិទ្យាបានដាក់អែបក្នុងមុខវិជ្ជាគណិតវិទ្យា ៩ រូបវិទ្យា ១ គីមី ៤ ជីវវិទ្យា ១០ និងផែនដី ៤ ដែលបញ្ចូលក្នុងសាលាមធ្យមសិក្សាធនធាន។

ដោយសារមានជំនួយពីកុំព្យូទ័របន្ទះនិងអែបលើមុខវិជ្ជាផ្សេងៗ ថ្នាក់រៀនបច្ចុប្បន្ននេះ មិនដូចពីមុនទេ ពោលគឺ សិស្សភាគច្រើនអ្នកស្វែងរកចំណេះដឹងដោយខ្លួនឯង ជាមួយនឹងការណែនាំពីគ្រូបង្រៀន។ ការសិក្សារបស់

Hagevik and Cherner (2016) លើការបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ តាមសាលារៀននៅជនបទបង្ហាញថា បច្ចេកវិទ្យាបច្ចុប្បន្ន និងការរៀនដោយប្រើអែបអាចឱ្យសិស្សអនុវត្តបុច្ឆនសិក្សាបាន (Inquiries Based Learning) ហើយលទ្ធផលសិក្សារបស់សិស្សគឺសម្រេចបានប្រកបដោយប្រសិទ្ធភាព នៅពេលដែលគ្រូបញ្ចូលប្លង់បង្រៀន (Lesson Study) ទៅក្នុងអែប។

## ៣. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងប្រើទិន្នន័យបែបគុណវិស័យ និងបរិមាណវិស័យ (សិស្ស និងគ្រូត្រូវដាក់ពិន្ទុដោយប្រើរង្វាស់ Likert Scale) សំណួរបើក សំណួរបាទ/ចាស៎ និងបែបគុណវិស័យ លើទិដ្ឋភាពការយល់ឃើញរបស់សិស្ស និងគ្រូទៅលើការប្រើប្រាស់កុំព្យូទ័របន្ទះ ព្រមទាំងការរៀននិងបង្រៀនតាមអនឡាញ។ យើងនឹងប្រើប្រាស់កម្រងសំនួរស្រាវជ្រាវនៅសាលាធនធាន និងសាលាធម្មតាតាមទីប្រជុំជន និងតាមជនបទ ពីអំឡុងខែឧសភា ដល់ខែសីហា ឆ្នាំ២០២០។ ក្រោយពីវិភាគទិន្នន័យ និងបញ្ចប់សេចក្តីព្រាងរបាយការណ៍ស្រាវជ្រាវ យើងបានអញ្ជើញនាយកសាលា និងគ្រូឧទ្ទេស ឱ្យមកចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីធ្វើសុពលភាពលើលទ្ធផលស្រាវជ្រាវ ប្រកបដោយផលប្រយោជន៍ដល់ក្រុមគោលដៅ។

ក្រោយពីការវាស់វែងលើទិដ្ឋភាពទាំងបួនខាងលើ និងវិសាលភាពនៃការរៀនតាមអនឡាញរបស់គ្រូ និងសិស្ស ការសិក្សានឹងផ្តល់បទសរុបដើម្បីធ្វើយ៉ាងណាឱ្យការអនុវត្តគម្រោងទទួលបានជោគជ័យ។ ជាងនេះទៅទៀត វាជាផែនទីគូសបង្ហាញផ្លូវ ដើម្បីផ្តល់សេវាអប់រំតាមការសិក្សាតាមអនឡាញ ជាពិសេស ក្នុងអំឡុងពេលនៃការបិទសាលាដោយប្រធានសក្តិណាមួយ ដូចជា ករណីជំងឺឆ្លងកូវីដ-១៩ ឬក្នុងពេលវិស្សមកាល។

យើងនឹងសុំឱ្យសិស្ស គ្រូ ជួយបំពេញកម្រងសំណួរ ដើម្បីឈ្វេងយល់ពី ១) ចំណេះដឹងទូទៅទាក់ទងនឹងការសិក្សាដោយមានជំនួយពីអាយស៊ីធី ២) សមត្ថភាពដើម្បីប្រើប្រាស់អែប ក្រោយការបណ្តុះបណ្តាលពីនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានវិទ្យា នៃក្រសួងអប់រំ យុវជន និងកីឡា ៣) ឥរិយាបថរបស់គ្រូ និងសិស្សតាមរយៈការប្រើប្រាស់អែបក្នុងកម្រិតនៃការទទួលស្គាល់តម្លៃនៃការប្រើប្រាស់អែប សម្រាប់ការរៀននិងបង្រៀន និង ៤) ការអនុវត្តនូវការប្រើប្រាស់កុំព្យូទ័របន្ទះ សម្រាប់ដាក់កម្មវិធីសិក្សាដែលបានបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។ ជាមួយគ្នានេះដែរ យើងបានអញ្ជើញគ្រូឧទ្ទេស និងអ្នកធ្វើគោលនយោបាយទាក់ទងនឹងប្រព័ន្ធអាយស៊ីធី ដើម្បីចែករំលែកបទពិសោធ និងការយល់ឃើញពីការពង្រឹង និងពង្រីកលើការសិក្សាដោយមានជំនួយនៃបច្ចេកវិទ្យាកុំព្យូទ័របន្ទះ។

# ៤. លទ្ធផលស្រាវជ្រាវ

សាលាមធ្យមសិក្សាធនធាន ក្រោមគម្រោងឧបត្ថម្ភ ដោយធនាគារអភិវឌ្ឍន៍អាស៊ី (កម្ចី) ក្នុងគម្រោង USESD បានទទួលកុំព្យូទ័របន្ទះ ៣០ គ្រឿងក្នុងសាលានីមួយៗ។ កុំព្យូទ័របន្ទះទាំងនោះ រក្សាទុកក្នុងទូមានកង់ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចចល័តកុំព្យូទ័របន្ទះ ពីបន្ទប់មួយទៅបន្ទប់មួយទៀតដោយងាយស្រួល។ គម្រោង USESDP ក៏បានបំពាក់ជុំវាំផែលមួយ និងម៉ាស៊ីន LCD បញ្ចាំងស្លាយមួយគ្រឿង។ ជុំវាំផែល អាចដាក់ឯកសារមេរៀន ដែលស្របនឹងកម្មវិធីសិក្សារបស់ក្រសួង (ដោយឧបករណ៍មួយចំនួនសរសេរជាភាសាខ្មែរ និងអង់គ្លេស)។ ឯកសារ ដែលទម្រង់ដូចគ្នា ដូចគេហទំព័រអប់រំទូទៅដែរ ដែលគេអាចមើលវាបាន ដោយមិនត្រូវការភ្ជាប់ជាមួយអ៊ីនធឺណិត។ តាមធម្មតា អ្នកប្រើប្រាស់អាចចូលប្រើវាំផែលម្តង បាន ៥០ នាក់ ក្នុងពេលដំណាលគ្នា ហើយប្រសិនបើចាំបាច់ អ្នកជំនាញ IT អាចបំបែក Intranet ឱ្យសិស្សប្រើបានតាមតម្រូវការពេញមួយសាលារៀនតែម្តង។

ដើម្បីចូលក្នុងជុំវាំផែល អ្នកប្រើប្រាស់ត្រូវមានចំណេះដឹងមូលដ្ឋានអាយស៊ីធី ដូចជា ការចុះឈ្មោះក្នុងកុំព្យូទ័របន្ទះនិងវាយអាសយដ្ឋានវេបសាយ (លេខកូដ) ដូចជា www.krou.moeys.gov.kh:8090 និង www.krou.moeys.gov.kh: 9090។ អាស័យដ្ឋានទាំងពីរអាចដំណើរការបានលុះត្រាតែកុំព្យូទ័របន្ទះភ្ជាប់ WiFi ដែលផ្សាយចេញពីជុំវាំផែល (ជុំនេះមានតួនាទីដូច Router ដែលគេប្រើប្រាស់នៅផ្ទះដែរ)។ មន្ត្រីនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានវិទ្យា នៃក្រសួងអប់រំ យុវជន និងកីឡា បានបណ្តុះបណ្តាលគ្រូបង្គោល(ToT) ដែលមកពីសាលាមធ្យមសិក្សាធនធានទាំង ១០ផ្សេងៗគ្នា។

លទ្ធផលការស្រាវជ្រាវ ត្រូវបានបែងចែកជាប្រាំផ្នែកធំៗ គឺ ១) សមត្ថភាព អាយស៊ីធី របស់គ្រូនិងសិស្ស ២) ចំណេះដឹងពីការប្រើប្រាស់កុំព្យូទ័របន្ទះ ៣) ឥរិយាបថចំពោះការប្រើប្រាស់កុំព្យូទ័របន្ទះ ៤)ការអនុវត្តលើការប្រើប្រាស់កុំព្យូទ័របន្ទះ និង ៥)ការដាក់បញ្ចូលកុំព្យូទ័របន្ទះ ឬឧបករណ៍ផ្សេងទៀតក្នុងការរៀន និងបង្រៀនក្នុងអំឡុងពេលជំងឺកូវីដ-១៩។

## ៤.១ ទិដ្ឋភាពនៃសំណាក

អ្នកចូលរួមឆ្លើយសំណួរក្នុងការស្រាវជ្រាវនេះមានចំនួន ១៤៥ នាក់ (គ្រូបង្រៀន ៤៨ នាក់) មកពី៩ខេត្ត (សាលាធនធានមួយនៅខេត្តកំពត ត្រូវបានជ្រើសរើសសម្រាប់សាកល្បងឧបករណ៍ស្រាវជ្រាវ) ដែលមានសាលាធនធានបានទទួលកុំព្យូទ័របន្ទះ (រួមមាន គ្រូវិទ្យាសាស្ត្រដែលបានទទួលវគ្គបណ្តុះបណ្តាលពីការប្រើប្រាស់ឧបករណ៍ទាំងនោះ)។ សិស្សមានអាយុពី ១៥ ដល់ ២២ ឆ្នាំ និងគ្រូមានដែលអាយុពី២៤ ដល់ ៥០ ឆ្នាំ បានបញ្ចូលក្នុងការសិក្សាស្រាវជ្រាវ។ ក្នុងចំណោមអ្នកឆ្លើយសំណួរ មានស្រីប្រមាណជាង ៥២ ភាគរយ នៃអ្នកឆ្លើយសំណួរទាំងអស់។ សិស្សទាំងអស់កំពុងរៀនពីថ្នាក់ទី៩ ដល់ ១២ ហើយគ្រូភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រ និងកម្រិតខ្ពស់បំផុតគឺ

បរិញ្ញាបត្រជាន់ខ្ពស់ ដែលមានគ្រូ ៧ នាក់។ ខេត្តក្រចេះ និងត្បូងឃ្មុំពុំមានសិស្សចូលរួមឆ្លើយសំណួរទេ ពីព្រោះសិស្សមិនទាន់បានរៀនតាមរយៈកុំព្យូទ័របន្ទះនៅឡើយ។ អ្នកឆ្លើយសំណួរជាងពាក់កណ្ដាល មិនទាន់មានអ៊ីមែលទេ ជាពិសេសសិស្ស ចំណែកគ្រូភាគច្រើនបានឆ្លើយ។ ចំនួនអ្នកមានចំណេះដឹងភាសាអង់គ្លេសកម្រិតល្អ មានប្រហែល ២០ភាគរយ ហើយមានប្រហែល២០ភាគរយដែលមិនអាចប្រើប្រាស់ភាសាអង់គ្លេសបាន។ ក្នុងចំណោមសំណាក មានអ្នកមិនចេះប្រើកុំព្យូទ័រសោះប្រហែល២៥ភាគរយ ទន្ទឹមនឹងនេះ យើងមានអ្នកចេះប្រើកម្មវិធី MS Excel ប្រមាណ ៣០ ភាគរយ។




**ក្រាហ្វ ២៖** អ្នកផ្ដល់សម្ភាសន៍តាមខេត្ត

សំណាកសរុបមានក្នុងតារាង១ សិស្ស និងគ្រូមួយចំនួនត្រូវបានស្នើសុំសម្ភាសន៍ជាច់ដោយឡែក ដើម្បីទទួលបានព័ត៌មានលម្អិតពីចម្លើយដែលមានក្នុងកម្រងសំណួរ ដូចជា «តើហេតុអ្វីបានជាយល់ថា រៀនតាមអែបស្រួលរៀន ប៉ុន្តែបែរជាចង់ឱ្យគ្រូបង្រៀនដោយផ្ទាល់? (សំណួរសម្រាប់សិស្ស)។ សម្រាប់គ្រូ យើងអាចសួរថា ហេតុអ្វីលោកគ្រូ ឬអ្នកគ្រូចង់ឱ្យសាលារៀនផ្សេងទទួលបានសំណុំកុំព្យូទ័របន្ទះនេះ?»។

**តារាង ១**

របាយសំណាកអ្នកដែលបានឆ្លើយតបនឹងកម្រងសំណួរ

| បរិយាយ | ស្រី | ប្រុស | សរុប |
|---|---|---|---|
| គ្រូបង្រៀន | ១៧ | ៣១ | ៤៨ |

| | | | |
|---|---|---|---|
| សិស្ស | ៥៩ | ៣៨ | ៩៧ |
| សរុប | ៧៦ | ៦៨ | ១៤៥ |

## ៤.២ ព័ត៌មានអំពីកុំព្យូទ័របន្ទះ

បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ ពោលគឺជាកុំព្យូទ័រលើតុដែលត្រូវបានដាក់ក្នុងបន្ទប់ធនធានក្នុងអគារសិក្សា។ បន្ទាប់ពីបញ្ចប់គម្រោង EEQP គម្រោង USESDP ក៏បានបំពាក់កុំព្យូទ័របន្ទះប្រមាណ ៣០ គ្រឿង ឱ្យសាលាធនធានក្នុងខេត្តទូទាំងប្រទេស ដែលជាផ្នែកនៃគម្រោងលើកកម្ពស់គុណភាពអប់រំ (EEQP 2008-2014)។ បន្ថែមពីលើកុំព្យូទ័របន្ទះ ម៉ាស៊ីនបញ្ចាំងស្លាយ និងជុំវ៉ាឆែលក៏ត្រូវបានបំពាក់នៅក្នុងសាលានីមួយៗផងដែរ។

ដើម្បីបង្រៀនដោយប្រើប្រាស់កុំព្យូទ័របន្ទះ សាលារៀនត្រូវការសំណុំឧបករណ៍ ដូចជា ជុំវ៉ាឆែល កុំព្យូទ័របន្ទះ និងម៉ាស៊ីនបញ្ចាំងស្លាយជាដើម។ ក្រៅពីជុំវ៉ាឆែល កម្មវិធី និងអែបផ្សេងៗ ដូចជា រូបភាពគណិតវិទ្យា ឬ E-School Cambodia ដែលបានបញ្ចូលទៅក្នុងកុំព្យូទ័របន្ទះ។ អែបទាំងនេះ អាចប្រើប្រាស់បានដាច់ដោយឡែកពីជុំវ៉ាឆែល និងអាចដំឡើងក្នុងទូរស័ព្ទស្មាតហ្វូនបានផងដែរ។ ទាំងវ៉ាឆែល ទាំងអែបគឺជារបស់ថ្មីសម្រាប់សិស្ស និងគ្រូបង្រៀននៅកម្ពុជា ជាពិសេស សម្រាប់នៅកន្លែងផ្សេងៗ ក្រៅពីទីក្រុងភ្នំពេញ។ តាមការអង្កេតទូទៅ សិស្សនៅភ្នំពេញ មានដំឡើងអែបច្រើនជាងសិស្សនៅជនបទ។

សាលារៀនដែលទទួលបានការបណ្តុះបណ្តាលពីរបៀបប្រើប្រាស់កុំព្យូទ័របន្ទះគឺនៅមិនទាន់បានយកទៅអនុវត្ត ឬយកទៅបង្រៀនសិស្សនៅឡើយទេ។ ទោះបីសាលារៀនមួយចំនួន បានបង្រៀនហើយក្តី ក៏ទើបតែអនុវត្តបានតែពីរ ឬបីដងប៉ុណ្ណោះ។ ភាគច្រើននៃការបង្រៀនសិស្ស គឺពីរបៀបចូលប្រើ និងការចុះឈ្មោះក្នុងឧបករណ៍ដែលបានកំណត់។ អ្នកទទួលខុសត្រូវបង្រៀននូវការប្រើប្រាស់អែបក្នុងសាលារៀនទាំងនោះ គឺជាគ្រូឧទ្ទេស (ជាគ្រូទទួលបន្ទុកផ្នែកគណិតវិទ្យា/វិទ្យាសាស្ត្រ)ក្នុងកម្មវិធី ដែលទទួលបានការបណ្តុះបណ្តាលពីក្រសួងអប់រំ យុវជន និងកីឡា។ គ្រូទាំងនេះអាចប្រើប្រាស់កុំព្យូទ័របន្ទះបាននោះ គឺដោយសារគាត់មានមូលដ្ឋានភាសាអង់គ្លេសមធ្យម ឬអាចនិយាយបានថា មេរៀនរបស់គាត់មានភាពងាយស្រួល។

## ៤.៣ ចំណេះដឹងមូលដ្ឋានពីអាយស៊ីធី របស់សំណាកនៃអ្នកបានផ្តល់ចម្លើយ

ជាទូទៅ សមត្ថភាពរបស់គ្រូ និងសិស្សពាក់ព័ន្ធនឹងអាយស៊ីធីគឺនៅមានកម្រិត។ គ្រូ និងសិស្សភាគច្រើនគ្មានឧបករណ៍អាយស៊ីធី ដូចជាកុំព្យូទ័រយួរដៃ កុំព្យូទ័របន្ទះ ឬ សេវាកម្មអ៊ីនធឺណិតល្អនៅឡើយទេ។ អ្វីដែលល្អនោះគឺថា

សិស្ស និងគ្រូមានស្មាតហ្វូនគ្រប់គ្នា។ បើតាម **តារាង២** យើងអង្កេតឃើញថា គ្រូមានឧបករណ៍ អាយស៊ីធីគ្រាន់ជាង សិស្ស ក្នុងតម្លៃសន្ទស្សន៍ ២,៣៥ ធៀបនឹង១,៦៦។ ក្នុងក្រាហ្វនេះមានន័យថា គ្រូភាគច្រើនមានឧបករណ៍ពីរមុខ (ស្មាតហ្វូន និងកុំព្យូទ័រយួរដៃ ឬមាន WiFi នៅផ្ទះ) ចំណែកសិស្សភាគច្រើនមានតែស្មាតហ្វូនទេ។ ក្រាហ្វដទៃទៀតបញ្ជាក់បានដូចគ្នាថា មានបំណិនល្អជាងសិស្ស ជាពិសេសបំណិនអាយស៊ីធី ឬកុំព្យូទ័រ។ សម្រាប់ភាសាអង់គ្លេស គ្រូ និងសិស្ស គឺមានកម្រិតភាសាអង់គ្លេសប្រហាក់ប្រហែលគ្នា។ នាយកសាលាមធ្យមសិក្សាធនធានមួយចំនួនអះអាងថា «មានតែកូនគេក្នុងទីប្រជុំជនទេដែលមានសមត្ថភាពគ្រាន់ បើកូនអ្នកជនបទ គឺពិបាកហើយ»។ ការចំណាយលើសេវាអ៊ិនធឺណិត គឺជាបញ្ហាប្រឈមមួយផងដែរ។ ទោះបីសិស្ស និងគ្រូមួយចំនួនមានឧបករណ៍ទំនើប ពួកគេមកជិតៗអគារធនធានដើម្បីមកប្រើសេវាអ៊ិនធឺណិត។ ម្យ៉ាងទៀត ភាសាអង់គ្លេសរបស់សិស្សគឺនៅមានកម្រិតខ្លាំង (ជាពិសេសភាសាអង់គ្លេសដែលគេប្រើក្នុងមេរៀន) ធ្វើឱ្យសិស្សពិបាកប្រើប្រាស់អាយស៊ីធី ដើម្បីសិក្សា (នេះបើតាមការអះអាងរបស់គ្រូមួយចំនួន)។

គួរកត់សម្គាល់ផងដែរថា ស្មាតហ្វូនដែលសិស្សនិងគ្រូមាន គឺមិនអាចដាក់បញ្ចូលកម្មវិធីច្រើនទេ ជាពិសេសស្មាតហ្វូតរបស់សិស្សមានទំហំផ្ទុកតូច។ បំណិនអាយស៊ីធីរបស់សិស្ស គឺបានបង្ហាញថា សិស្សបានប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចតិចបំផុត។ គ្រូ សិស្ស និងនាយកសាលាអះអាងថា សាលានៅមានការខ្វះខាតឧបករណ៍ទាំងនេះណាស់ ជាពិសេស កុំព្យូទ័របន្ទះ។ តាមការគណនាសមាមាត្ររវាងចំនួនកុំព្យូទ័របន្ទះធៀបនឹងចំនួនសិស្សដែលកំពុងរៀនពីថ្នាក់ទី១០ដល់ទី ១២ គឺប្រែប្រួលពីសាលាវិទ្យាល័យមួយទៅមួយ។ សមាមាត្រកុំព្យូទ័របន្ទះទៅនឹងចំនួនសិស្សដែលទាបបំផុតគឺ ១:២៦ (សិស្ស ២៦នាក់ មានកុំព្យូទ័របន្ទះ១សម្រាប់វិទ្យាល័យក្រចេះក្រុង) និងខ្ពស់បំផុតគឺ ១ : ៧៤ (សម្រាប់វិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម)។ នៅមានខេត្តបីទៀតដែលសិស្សច្រើនជាង ៥០ នាក់ មានកុំព្យូទ័របន្ទះមួយប្រើ គឺបាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំង។ តាមរយៈសមាមាត្រនេះ គ្រូ និងសិស្សអះអាងថា គេគួរបន្ថែមកុំព្យូទ័របន្ទះឱ្យសាលាទៀត ដើម្បីធានាថា សិស្សបានប្រើប្រាស់ញឹកញាប់។

**តារាង ២**

តម្លៃមធ្យមនៃមូលដ្ឋានអាយស៊ីធីរបស់សំណាក

| សូចនាករ | គ្រូបង្រៀន | សិស្ស | សរុប |
|---|---|---|---|
| មានឧបករណ៍ (អតិបរមា៥) | ២,៣៥ | ១,៦៦ | ១,៨៩ |

| | | | |
|---|---|---|---|
| មានបំណិនភាសាអង់គ្លេស (អតិបរមា ៤) | ២,១ | ២,០២ | ២,០៥ |
| កម្រិតបំណិន អាយស៊ីធី (អតិបរមា ២) | ១,៤២ | ០,៨៩ | ១,០៧ |
| សរុប | ២,៧១ | ២,២៤ | ១,៦៧* |

*សំគាល់៖ តម្លៃអតិបរមាគិតជាមធ្យមនៃមូលដ្ឋានអាយស៊ីធីក្នុងម៉ូឌែលនេះគឺ ៣,៦៦

## ៤.៤ ចំណេះដឹងលើកុំព្យូទ័របន្ទះ

ចំណេះដឹងនៃការសិក្សាស្រាវជ្រាវនេះ គឺសំដៅដល់ការយល់ដឹងរបស់អ្នកឆ្លើយសំណួរពីទិដ្ឋភាពទូទៅនៃផលប្រយោជន៍របស់អែប និងវ៉ាំផែល ដូចជា តើអ្វីជាសារៈប្រយោជន៍នៃការប្រើប្រាស់អែប និងវ៉ាំផែល? តើសម្ភារៈអ្វីខ្លះដើម្បីប្រើឧបករណ៍ទាំងនោះបាន និងតើគេអាចប្រើអែប និងវ៉ាំផែលនៅទីណាបានខ្លះ? ការវាស់វែងពីចំណេះដឹងនេះគឺផ្អែកតាមសូចនាករធំៗបីគឺ ១) ចំនួនអែបរបស់ខ្មែរ (ឱ្យប្រើដោយក្រសួង និងមានក្នុងសៀវភៅណែនាំរបស់នាយកដ្ឋានព័ត៌មាន) ដែលគ្រូនិងសិស្សប្រើ ដូចជា Khmer Academy ២) ចំនួនមេរៀនដែលអាចប្រើវ៉ាំផែល ៣) ចំនួនមនុស្សដែលឆ្លើយសំណួរបានចែករំលែកចំណេះដឹងពីអែប។

ជារឿយៗ ការប្រើប្រាស់កុំព្យូទ័រ និងអែប ក្រាហ្វ ៤ មិនបានបញ្ជាក់ពីភាពខុសគ្នារវាងគ្រូ និងសិស្សទេ។ លើសពីនេះ អ្នកឆ្លើយសំណួរច្រើនជាងពាក់កណ្ដាលមិនទាន់បានប្រើ ឬបានប្រើតិចតួចនូវប្រព័ន្ធដែលបានតំឡើងនៅតាមវិទ្យាល័យធនធាន។ ការមិនបានប្រើប្រាស់ឧបករណ៍នេះ គឺដោយសារមានបញ្ហាជំងឺឆ្លងកូវីដ-១៩ នាំឱ្យមានការបិទសាលារៀន បន្ទាប់ពីទទួលបានការបណ្ដុះបណ្ដាល។

សម្រាប់អ្នកដែលបានប្រើប្រាស់កន្លងមកបានអះអាងថា អត្ថប្រយោជន៍អែប ឬវ៉ាំផែលមានលក្ខណៈប្រកតបើកចំហ និងអាចប្រើបានក្នុងទូរស័ព្ទ ដែលសិស្សអាចប្រើបានរៀនគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ សិស្សអាចមើលវីដេអូមេរៀន ឬដំណើរនៃការពិសោធម្ដងហើយម្ដងទៀតដោយខ្លួនឯងបាន។ លើសពីនេះទៀត សិស្សអាចផ្ទៀងផ្ទាត់ចម្លើយលំហាត់របស់ខ្លួនជាមួយអែប នៅពេលគេបានធ្វើលំហាត់ណាមួយរួចហើយ។ ទាំងនេះ បានប្រគល់ឱ្យសិស្សនូវការសិក្សាឯករាជ្យ និងបង្កើនភាពបត់បែនក្នុងការសិក្សាបច្ចុប្បន្ន។

បន្ទាប់ពីកូវីដ-១៩ បានស្ងាត់បន្តិច តាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា យើងបានចាប់ផ្ដើមបើកសាលារៀននៅដើមខែកញ្ញា សម្រាប់ថ្នាក់ទី១២ និងទី៩ ដើម្បីត្រៀមប្រឡងបញ្ចប់ ឬបាក់ឌុប។ ការបង្រៀនទៀតសោតគឺផ្ដោតតែលើមេរៀននៃមុខវិជ្ជាដែលត្រូវប្រឡងតែប៉ុណ្ណោះ។ ការបង្រៀនតាមកុំព្យូទ័របន្ទះដោយគ្រូបង្រៀនគឺជាការបង្ហាញបន្ថែម ដើម្បីពង្រឹងការយល់ដឹងរបស់សិស្ស ដូចនេះ យើងមិនមានពេលគ្រប់គ្រាន់ក្នុងការយកបច្ចេកវិទ្យានេះមកប្រើសម្រាប់បង្រៀន នៅពេលនេះទេ។




**ក្រាហ្វ ៣៖** របាយមេរៀនដែលអាចប្រើប្រាស់ក៉ាផែលសម្រាប់រៀន ឬបង្រៀន

ផ្អែកលើអ្នកផ្តល់ចម្លើយមួយចំនួន ពួកគេបានលើកឡើងថា «អែបដែលបានប្រើកន្លងមកនេះគឺពិបាកប្រើណាស់ ដោយសារវាជាភាសាអង់គ្លេស យើងមិនអាចយល់ដឹងពីអែបស៊ីជម្រៅបានទេ ដោយសមត្ថភាពភាសាអង់គ្លេសនៅមានកម្រិត។ គ្រូបង្រៀនក៏បានបង្ហាញផងដែរថា ការដាក់ឧបករណ៍ជាភាសាខ្មែរបន្ថែមគឺជាផែនទីដ៏សំខាន់ ដើម្បីធ្វើឱ្យសិស្សរឹតតែមានចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងក្នុងការសិក្សារបស់ពួកគេ។

បើយោងតាមគ្រូបង្រៀនម្នាក់បានអះអាងថា បញ្ហាប្រឈមធំមួយសម្រាប់ការសិក្សាតាមអែបគឺសេវាអ៊ិនធឺណិតគឺវានៅមានការកំណត់នៅទីជនបទដែលធ្វើឱ្យមានការលំបាកមើលវីដេអូ ឬទាញយកឯកសារដែលមានទំហំធំបាន។ ពេលខ្លះ ឧបករណ៍មិនអាចដំណើរការ Software ពិសេសៗបានទេ។ ឧទាហរណ៍ នៅពេលចង់ឱ្យអែប បង្ហាញពីប្រមាណវិធី ឬដំណោះស្រាយសមីការលម្អិត ទូរស័ព្ទតែងតែរលត់»។

តាមការអង្កេតរបស់អ្នកស្រាវជ្រាវឃើញថា គ្រូបង្រៀនដែលមានកម្រិតភាសាអង់គ្លេសល្អ និងមានបំណិនកុំព្យូទ័រមធ្យម (ភាគច្រើនវ័យក្មេង) គឺចូលចិត្តប្រើ អាយស៊ីធី សម្រាប់បង្រៀន។ ទោះបីជាយ៉ាងណា សម្រាប់គ្រូដែលមានវ័យចំណាស់ ភាគច្រើនប្រើអែប និងក៉ាផែលជាភាសាខ្មែរ វាគឺជារឿងចាំបាច់ ដោយត្រូវមានការបង្រៀនពីវិធីប្រើប្រាស់បន្ថែមទៀត។ លើសពីនេះទៀត វាត្រូវបានគេរកឃើញថា គួរតែមានសៀវភៅណែនាំលម្អិតជាងនេះស្តីពី ការបន្សុីគ្នារវាងមេរៀនក្នុងក៉ាផែល និងមេរៀនក្នុងសៀវភៅ។ សិស្សនិងគ្រូភាគច្រើនចូលចិត្ត e-School (សូមមើលក្រាហ្វ

៥ អ្នកឆ្លើយអាចជ្រើសចម្លើយបានច្រើន) ដោយហេតុថា អែបនេះជាភាសាខ្មែរ ហើយមានមេរៀនស្របតាមកម្មវិធីសិក្សារបស់ក្រសួង។




**ក្រាហ្វ ៤៖** របាយអែបដែលសិស្ស និងគ្រូប្រើសម្រាប់រៀន ឬបង្រៀន

យើងក៏អង្កេតឃើញផងដែរថា គ្រប់សាលាធនធានតែងមានគ្រូឧទ្ទេសដែលអាចបន្តបណ្តុះបណ្តាលដល់គ្រូក្នុងសាលាមធ្យមសិក្សាធនធានលើការប្រើប្រាស់ប៉ាធែល និងការបង្រៀនដោយប្រើអែប និងប៉ាធែល។ ប៉ុន្តែការបណ្តុះបណ្តាលភាគច្រើនគឺ ធ្វើក្នុងរូបភាពក្រៅផ្លូវការ ពេលការបង្រៀនពីមួយទៅមួយ លុះត្រាតែទទួលបានការណែនាំពីនាយកសាលា។ ក្រាហ្វ ៦ បង្ហាញពីរបាយគិតជាភាគរយ អ្នកដែលបានចែករំលែកចំណេះដឹងក្នុងចំណោមគ្រូ និងសិស្ស។ តាមរយៈពត៌មានបង្ហាញក្នុងក្រាហ្វ គ្រូនិងសិស្សចង់ចែករំលែកចំណេះដឹងជាមួយអ្នកផ្សេងប្រហាក់ប្រហែលគ្នា។ គ្មានភាពខុសប្លែកគ្នាក្នុងកម្រិតស្ថិតិណាមួយរវាងភេទ ភាពជាសិស្ស ឬភាពជាគ្រូទេ នេះបើតាម Chi-quare test។



**ក្រាហ្វ ៥៖** របាយអ្នកដែលបានចែករំលែកចំណេះដឹងពីការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័របន្ទះ/អែប

គ្រូមួយចំនួននៅមានការភាន់ច្រឡំរវាងការប្រើប្រាស់ ៉ាឆែល និងអែបនៅក្នុងកុំព្យូទ័របន្ទះ។ ពេលខ្លះពួកគេគិតថា ៉ាឆែលគឺជាអែប ហើយគេអះអាងផងដែរថា ក្រសួងគួរដាក់អែបឱ្យច្រើនក្នុង៉ាឆែល ដូចនេះ ពួកគេមិនចាំបាច់ស្រាវជ្រាវឯកសារបន្ថែមពីប្រភពផ្សេងៗនោះទេ។ យ៉ាងណាក៏ដោយ គ្រូៗដែលធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាលបានយល់ដឹងច្រើនពីអែប ដែលបានដំឡើងក្នុងកុំព្យូទ័របន្ទះ។ តាមការស្ទង់មតិ គ្រូបង្រៀនមានដំឡើងអែបផ្សេងៗក្នុងទូរស័ព្ទដៃសម្រាប់សិក្សាបន្ថែម។ ទោះក្នុងអំឡុងពេលជំងឺឆ្លងកូវីដ-១៩ គ្រូមួយចំនួនបានណែនាំសិស្សឱ្យចេះប្រើប្រាស់អែប ជាពិសេស គណិតវិទ្យា ដូចជា PhotoMaths។ អែបនេះ គឺងាយស្រួលទាំងគ្រូទាំងសិស្ស ដើម្បីផ្ទៀតផ្ទាត់ចម្លើយ។ សិស្សម្នាក់នៅវិទ្យាល័យធនជានបានអះអាងថា *«ខ្ញុំបានធ្វើលំហាត់បានច្រើន ដោយសារមានអែបនេះជំនួយខ្ញុំធ្វើលំហាត់ហើយ ខ្ញុំអាចផ្ទៀងផ្ទាត់បានភ្លាមដោយមិនចាំបាច់គ្រូផ្តល់កំណែឱ្យទេ»*។ ស្របពេលនៃការសិក្សានេះ *«ចំណេះដឹងពីការប្រើប្រាស់កុំព្យូទ័របន្ទះក្នុងចំណោមគ្រូបង្គោល គឺនៅពិបាកប៉ានស្មានណាស់ ដោយហេតុថាយើងទើបទទួលបានការបណ្តុះបណ្តាលថ្មីៗ»* នេះបើតាមការអះអាងរបស់គ្រូបង្គោលម្នាក់។ ការបណ្តុះបណ្តាលគ្រូលើកុំព្យូទ័របន្ទះគឺធ្វើឡើងមុនពេលជំងឺកូវីដ-១៩ បន្តិច ហើយសាលារៀនទាំងអស់បានបិទទ្វារ ប៉ុន្តែបង្រៀនតាមប្រព័ន្ធសិក្សាពីចម្ងាយ។

## ៤.៥ ឥរិយាបថលើការប្រើប្រាស់កុំព្យូទ័របន្ទះ

ចំណែកឥរិយាបថចំពោះកុំព្យូទ័របន្ទះនេះ គឺសំដៅលើការកោតសរសើរ ឬមានភាពពេញចិត្តចំពោះអែប និង៉ាឆែល ដូចជា តើចំនួនអែបដែលបានទាញយកទុកប្រើប្រាស់ ការយល់ឃើញពីភាពងាយស្រួលពីការបង្រៀន និងការរៀន ដោយប្រើអែប និង៉ាឆែល បើប្រៀបធៀបនឹងការបង្រៀន ដោយគ្មានឧបករណ៍ទាំងនោះ ឬថាតើគ្រូ ឬសិស្សបានណែនាំគ្រូឬសិស្សផ្សេងទៀតឱ្យបានប្រើប្រាស់ឧបករណ៍ទាំងនេះដែរឬទេ?។ បើតាមតារាង ៣ យើងឃើញថាអ្នកឆ្លើយសំណួរប្រមាណជាង៥០ភាគរយ អះអាងថា ៉ាឆែល ឬអែបមានភាពងាយស្រួលប្រើ យ៉ាងណាក៏ដោយសិស្សភាគច្រើនឆ្លើយថា គាត់មិនពេញចិត្តរៀនដោយប្រើប្រាស់អែបទេ ដែលផ្ទុយពីគ្រូបង្រៀនត្រូវបានគេរកឃើញថាគ្រូបង្រៀនភាគច្រើនចង់បង្រៀនតាមអែប។ (តាមរយៈ Chi-Square Test បង្ហាញថា $\chi2$ (1, N=145) = 16.178, p=0.000)។ សម្រាប់ការណែនាំឱ្យសាលារៀនផ្សេង និងសិស្សឱ្យទទួលបានសំណុំ៉ាឆែល សិស្សនិងគ្រូមិនសូវខុសគ្នាពេកទេ ប៉ុន្តែទិន្នន័យនេះបង្ហាញថា សិស្សហាក់មានភាពស្ទាក់ស្ទើរក្នុងការបង្រៀន៉ាឆែល និងអែប។ ខាងក្រោមនេះ ជាទិន្នន័យគុណវិស័យទាក់ទងនឹងតារាង ៣។

**តារាង ៣**

ចំនួននៃអ្នកផ្តល់ចម្លើយលើការប្រើប្រាស់អែប និងវ៉ាធែល

| សំនួរ | គ្រូបង្រៀន | | សិស្ស | |
|---|---|---|---|---|
| | ស្រី | ប្រុស | ស្រី | ប្រុស |
| តើអែបមានភាពងាយស្រួលប្រើប្រាស់ឬទេ? | ១៥ | ១៩ | ២២ | ១៣ |
| តើពេញចិត្តនឹងការប្រើប្រាស់អែបឬទេ? | ១៣ | ១៧ | ៦ | ៤ |
| តើចង់ឱ្យសាលាផ្សេងមានសំណុំវ៉ាធែលនិងអែបដែរឬទេ? | ១៧ | ២៦ | ៣៧ | ២៧ |

សិស្សដែលមិនបានចូលរួមការបណ្តុះបណ្តាលពីការប្រើវ៉ាធែល និងអែបផ្តល់ការផ្តល់ជាមតិថា វ៉ាធែលជួយឱ្យរៀនបានលឿន ការបង្រៀនតាមវ៉ាធែល មានភាពរស់រវើក និងរៀនឆាប់ចេះ។ ម្នាក់ៗអាចរកមេរៀនដោយមិនចាំបាច់ចំណាយថវិកាដូចការរៀនតាមអនឡាញ ហើយវាអាចឱ្យយើងរៀនដោយមានការជួយពីគ្រូបង្រៀនបាន។ ប៉ុន្តែទន្ទឹមនឹងនេះពួកគេក៏មានទស្សនៈមួយចំនួនដែលយល់ថាកុំព្យូទ័របន្ទះនៅមានចំណុចខ្វះខាត ដូចជាវ៉ាធែលមានប្រសិទ្ធភាពតិចជាងការបង្រៀនតាមក្តារខៀន ខ្លឹមសារក្នុងវ៉ាធែលជាភាសាបរទេសគឺវាពិបាកយល់។

ជាក់ស្តែង សិស្សដែលធ្លាប់បានចូលរៀនដោយប្រើវ៉ាធែលវិញ ត្រូវបានគេរកឃើញថា សម្រាប់សិស្សចេះភាសាអង់គ្លេសមានភាពច្បាស់លាស់ ការប្រើវ៉ាធែលមានភាពងាយស្រួល និងប្រសិទ្ធភាពជាងការបង្រៀនតាមក្តារខៀន។ វ៉ាធែលបង្ហាញពីការពិសោធបានច្បាស់លាស់ ហើយវាធ្វើឱ្យមានគំនិតកំណត់ចំណាំមេរៀនដោយខ្លួនឯង។ លើសពីនេះ វ៉ាធែលសម្រួលដល់ការរៀនមុខវិជ្ជាវិទ្យាសាស្ត្រ។ ទន្ទឹមនឹងនេះ អ្នកផ្តល់ចម្លើយក៏មានមតិដែលយល់ឃើញពីផលអវិជ្ជមាននៃការប្រើវ៉ាធែលដែរ ដូចជា ចំណាយពេលវេលាច្រើនក្នុងការរៀបចំវ៉ាធែល និងការបើកបិទកុំព្យូទ័របន្ទះដែលនាំឱ្យខ្វះខ្ជាយម៉ោងសិក្សា។ វ៉ាធែលតែងតែលោតកម្មវិធី ឬអែបផ្សេងៗដែលខុសពីមេរៀនដែលនាំឱ្យបែកអារម្មណ៍សិស្ស(ការផ្សាយពាណិជ្ជកម្ម)។ លើសពីនោះ ម៉ោងសិក្សាខ្លីពេកសម្រាប់ការបង្រៀនតាមវ៉ាធែល។ ការបង្រៀនតាមវ៉ាធែលគឺត្រូវការម៉ោងច្រើនជាងការបង្រៀនលើក្តារខៀន និងបើកកុំព្យូទ័របន្ទះមានដែនកំណត់។

បច្ចុប្បន្ន យើងមានអែបជាភាសាខ្មែរ មានសម្រាប់គ្រប់កម្រិតថ្នាក់រៀន និងគ្រប់មុខវិជ្ជា។ ជាភព្វសំណាងអែបទាំងនេះមិនត្រូវការទទួលសេវាអ៊ិនធឺណិតគ្រប់ពេលទេ ហើយពួកវាអាចដំណើរការដោយមិនភ្ជាប់អ៊ិនធឺណិតបានបន្ទាប់ពីអែបបានបញ្ចូលក្នុងកុំព្យូទ័របន្ទះ ឬក្នុងស្មាតហ្វូន។ ដោយយោងលើអែបរបស់ក្រសួងអប់រំ យុវជន និងកីឡា សេវាកម្មរៀនពីចម្ងាយ តាមរយៈគេហទំព័រសម្រាប់គ្រប់កម្រិត និងគ្រប់ថ្នាក់។ វាគួរកត់សម្គាល់ផងដែរថា រាល់

YouTube Channels អែប និងគេហទំព័ររបស់ក្រសួងអប់រំមានតិចតួចណាស់ត្រូវបានបញ្ចូលក្នុងរ៉ាឆែល។ នេះឆ្លុះបញ្ចាំងលើជម្រើសគោលនយោបាយ មិនគួរបញ្ចូលខ្លឹមសារជាសាធារណៈ ដែលមិនទាន់បានពិនិត្យ និងបញ្ជាក់ដោយក្រសួងដើម្បីធានាទទួលបាននូវស្តង់ដាប្រកបដោយគុណភាព។

ជាលទ្ធផលនៃការរីកចម្រើននៃអាយស៊ីធី ដោយសារការផ្អាកសាលារៀន ការរៀនពីចម្ងាយគឺអាចធ្វើទៅបានដោយរលូន ជាពិសេស នៅកន្លែងណាដែលអាចទទួលសេវាអ៊ិនធឺណិតបានល្អ ក្នុងនោះយើងមាន YouTube Channelsអែប និងការបង្រៀនឡាយតាមហ្វេសប៊ុកផេកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។ តាមការអង្កេតអ្នកផ្តល់ចម្លើយយល់ឃើញថា មានYouTube Channelsមិនតិចជាង១០០ទេ ដែលបង្ហោះលើអ៊ិនធឺណិត ដោយផ្តល់ខ្លឹមសារទៅតាមកម្រិតថ្នាក់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។ សាលារដ្ឋ និងសាលាឯកជនមួយចំនួនបានផលិតខ្លឹមសារមេរៀន រួចបង្ហោះជាសាធារណៈ ខណៈសាលាខ្លះទៀតបានបង្ហោះវីដេអូដែលគ្រូបង្រៀនបង្ហោះតាមអនឡាន។

សរុបមក គ្រូបង្រៀននិងសិស្សបានបង្ហាញពីឥរិយាបថវិជ្ជមានខ្លាំងចំពោះកុំព្យូទ័របន្ទះជាវិជ្ជមានយ៉ាងខ្លាំង។ បើទោះបីជាគ្រូបង្រៀននិងសិស្សនៅមិនទាន់បានប្រើប្រាស់កុំព្យូទ័របន្ទះចល័តឱ្យអស់លទ្ធភាពក៏ដោយ ក៏ពួកគេកត់សម្គាល់ថា ការប្រើប្រាស់កុំព្យូទ័របន្ទះមានសារៈប្រយោជន៍សំខាន់ក្នុងបរិបទនៃជំងឺកូវីដ-១៩ខ្លាំង។ គ្រូបង្រៀន និងសិស្សមួយចំនួនបានទិញស្មាតហ្វូនដើម្បីដំឡើងអែបដូចក្នុងកុំព្យូទ័របន្ទះ ដើម្បីជំនួយកិច្ចការសាលា និងការសិក្សាដោយឯករាជ្យ។ យោងតាមការអះអាងរបស់គ្រូនិងសិស្សមួយចំនួនថា ពួកគេបានណែនាំអ្នកផ្សេងឱ្យប្រើកុំព្យូទ័របន្ទះ ឬស្មាតហ្វូនដែរ ពីព្រោះថា ពួកគេអាចប្រើប្រាស់ប្រចាំថ្ងៃផង ហើយអាចដំឡើងអែបសម្រាប់សិក្សា ក៏ដូចជាជំនួយក្នុងការបង្រៀនផងដែរ។ គ្រូរូបវិទ្យាម្នាក់អះអាងថា *«មានអែបនេះ ខ្ញុំអាចបង្រៀនបានដោយស្រួល ហើយខ្ញុំអាចចំណេញពេលពាក់កណ្តាល បើធៀបនឹងការបង្រៀនតាមទម្លាប់»*។ គ្រូវិទ្យាសាស្ត្រភាគច្រើនចូលចិត្តអែបសម្រាប់បង្រៀនណាស់ ព្រោះថាអែបបានបង្កលក្ខណៈងាយស្រួលក្នុងការបង្រៀន។

## ៤.៦ ការអនុវត្តការប្រើប្រាស់កុំព្យូទ័របន្ទះ

ការវាស់ពីការអនុវត្តកុំព្យូទ័របន្ទះ សំដៅដល់ការប្រើប្រាស់**អែប** និង**រ៉ាឆែល**របស់សិស្សនិងគ្រូបង្រៀន។ ពត៌មានពីចំនួនអែបដែលបានប្រើប្រាស់សព្វថ្ងៃ ចំនួនម៉ោងដែលបានប្រើប្រាស់ និងតម្រូវការប្រើប្រាស់អែប ឬរ៉ាឆែលក្នុងការរៀបចំប្លង់មេរៀនសម្រាប់ការសិក្សា។ យើងក៏បានរៀនសូត្រពីបញ្ហាប្រឈមនានា នៅពេលដែលគ្រូនឹងសិស្សបានចាប់ផ្តើមប្រើប្រាស់អែបទាំងនេះ។ តារាង ៤ បង្ហាញថា យោងតាមប្រភពបឋមនៃជំងឺឆ្លងកូវីដ-១៩ និងការបិទសាលារៀន

គ្រូបង្រៀននិងសិស្សភាគច្រើន(៥៧%) មិនទាន់បានប្រើប្រាស់សំណុំកុំព្យូទ័របន្ទះទេ បន្ទាប់ពីការបណ្តុះបណ្តាលមក។ យ៉ាងណាក៏ដោយ គ្រូបង្រៀនមួយចំនួនដែលមានសមត្ថភាពខ្លាំង ដូចជាគ្រូឧទ្ទេសដែលបានប្រើប្រាស់ឧបករណ៍ទាំងនោះ។

**តារាង ៤**

សំណុំកុំព្យូទ័របន្ទះ ប្រើប្រាស់ក្នុងថ្នាក់រៀន

| | មិនទាន់បានអនុវត្ត | តិចតួចបំផុត | មធ្យម | ញឹកញាប់ | ញឹកញាប់បំផុត |
|---|---|---|---|---|---|
| សិស្ស | ២២ | ៣៥ | ៣៦ | ៣ | |
| គ្រូបង្រៀន | ១៥ | ៩ | ១៩ | ៣ | ១ |
| សរុប | ៣៧ | ៤៤ | ៥៥ | ៦ | ១ |

គ្រូរូបវិទ្យាមួយចំនួនអះអាងថា មានមេរៀនខ្លះត្រូវចំណាយពេល ៦ ម៉ោងដើម្បីបង្រៀន ប៉ុន្តែការប្រើប្រាស់ ៉ាឆែល អាចចំណេញពេលប្រហែលជា ៣ ម៉ោង ដោយមិនបានបន្ថយគុណភាពបង្រៀននោះទេ។ ពួកគេតែងផ្តល់យោបល់ឱ្យសិស្សចូលចិត្តវិធីសាស្ត្របង្រៀនបែបទំនើបនេះផងដែរ ដោយផ្តើមពីឱ្យសិស្សអាចផ្លាស់ប្តូរ ដើម្បីការពិសោធ និងបង្វិលមើល 3D។ ដោយមើលឃើញពីអត្ថប្រយោជន៍របស់៉ាឆែលនេះ គ្រូបង្រៀនចង់ទាញយកមេរៀនពី៉ាឆែលបញ្ចូលក្នុងទូរស័ព្ទដៃ តែមិនទាន់អាចធ្វើទៅបាននៅឡើយ។

គ្រូវិទ្យាសាស្ត្រមួយចំនួនអះអាងថា ៉ាឆែលមានផ្ទុកមេរៀនស្របតាមកម្មវិធីសិក្សា ប្រហែល ៥០ ភាគរយ ដែលអាចឱ្យគាត់ចំណេញពេលវេលារបស់ខ្លួន បានប្រហែល ៣០ ភាគរយ ប្រសិនបើ ពួកគេបង្រៀនតាម៉ាឆែល ព្រោះថា សិស្សអាចយល់មេរៀនបានលឿនជាងគ្រូពន្យល់សារចុះសារឡើងតាមទម្លាប់។ គ្រូក៏បានអះអាងផងដែរថា៉ាឆែលគឺជួយបំពេញដំណើរការបង្រៀនរបស់គាត់បានយ៉ាងល្អ ជាពិសេស នៅក្នុងជំហានទី ៣។ ពួកគាត់បានអះអាងទៀតថា ប្រសិនបើសិស្សទាំងអស់ត្រូវរៀនដោយប្រើកុំព្យូទ័របន្ទះ ចំនួនកុំព្យូទ័របន្ទះគឺនៅមានការខ្វះខាតខ្លាំងណាស់។

បើទោះបី ការអះអាងនេះហាក់ដូចជាបញ្ជាក់ពីការអះអាងរបស់សិស្សមួយចំនួនថា ការរៀនតាមកុំព្យូទ័របន្ទះគឺពិបាកណាស់ ពីព្រោះចំណាយពេលច្រើនដើម្បីដំណើរការវាបាន។ ការអះអាងរបស់ពួកគេគឺអាចឆ្លុះបញ្ចាំងពីបទពិសោធនៅមានកម្រិតពីការប្រើអែប និងរ៉ាឆែល។ ការរកឃើញប្រចក្សបង្ហាញថា ការយល់ដឹងពីភាសាអង់គ្លេសរបស់ពួកគេនៅមានកម្រិតដែលជាឧបសគ្គចម្បងដើម្បីប្រើប្រាស់ឧបករណ៍ទាំងនោះ។ ខាងក្រោមនេះជាឧបសគ្គដែលអ្នកឆ្លើយសំណួរបានអះអាង (តារាង ៥)។

**តារាង ៥៖**

ឧបសគ្គដែលបានជួបប្រទះដោយអ្នកផ្តល់ចម្លើយ បានរាយការណ៍

| ឧបសគ្គក្នុងការរៀន ឬបង្រៀនដោយប្រើសំណុំកុំព្យូទ័របន្ទះ | គ្រូបង្រៀន | សិស្ស | សរុប |
|---|---|---|---|
| មិនដឹងមេរៀនពាក់ព័ន្ធនៅឯណា | ១៨ | ២៤ | ៤២ |
| សិស្សមិនចេះភាសាអង់គ្លេស | ៣០ | ៤៦ | **៧៦** |
| ពិបាកភ្ជាប់កុំព្យូទ័របន្ទះជាមួយម៉ាស៊ីនបញ្ចាំងស្លាយ | ១៤ | ១៨ | ៣២ |
| ម៉ោងរៀនតិចពេក | ៣០ | ៤៥ | **៧៥** |
| មិនអាចរៀបចំមេរៀនបានដោយសាររ៉ាឆែលនៅសាលារៀន | ២១ | ៣៨ | ៥៩ |
| ផ្នែកខ្លះជាប់សោរមិនអាចប្រើបាន (ត្រូវទិញ) | ២២ | ៤៩ | ៧១ |

ចំណាំ៖ ចំនួនសំណាកដែលឆ្លើយសំណួរនេះមាន១២៤នាក់ (សំណួរទាំងនេះមិនបានសួរនៅខេត្តកំពង់ឆ្នាំងទេ)

តាមតារាង ៥ បង្ហាញថា ចំណេះដឹងភាសាអង់គ្លេសរបស់សិស្សមិនគ្រប់គ្រាន់ (អ្នកផ្តល់ចំលើយ ៧៦ ក្នុង ១២៤ នាក់ នៃពួកគេថា ភាសាអង់គ្លេសគឺជាឧបសគ្គ) ហើយម៉ោងសិក្សាក៏តិចគឺជាឧបសគ្គចម្បងសម្រាប់ការរៀន ឬបង្រៀនតាមកុំព្យូទ័របន្ទះ។ ទាំងគ្រូបង្រៀន និងសិស្សគឺបានអះអាងថា ភាពប៉ិនប្រសប់ក្នុងអង់គ្លេសគឺជាកត្តាចម្បងក្នុងការរៀននិងបង្រៀនឱ្យបានល្អ។ តេស្ត Chi-Square test រវាងអថេរដែលមានក្នុងតារាង ៥ (រួមទាំងភេទរបស់អ្នកឆ្លើយសំណួរ) មិនបង្ហាញពីភាពខុសគ្នារវាងគ្រូ និងសិស្ស ឬប្រុស និងស្រីទេ ដោយផ្តល់បទសរុបថា បញ្ហាទាំងអស់នេះគឺមានទូទៅក្នុងចំណោមអ្នកឆ្លើយសំណួរ។

យោងតាមសិស្សមួយចំនួនឱ្យដឹងថា អ្វីដែលជាជំនួយសំខាន់នោះគឺអែបដែលចេញពីក្រសួងអប់រំ យុវជន និងកីឡាផ្ទាល់ សម្រាប់ប្រឡងថ្នាក់ទី ១២ ដែលអនុញ្ញាតឱ្យពួកគេរៀនដោយខ្លួនឯងបាន បើទោះជាមានការបិទសាលារៀនក៏ដោយ។ សិស្សមួយចំនួនអះអាងថា ពួកគេមិនទាន់មានទំនុកចិត្តលើអែបដែលចេញដោយគ្រូ ឬក្រុមហ៊ុនផ្សេងៗនោះទេ បើទោះបី អែបទាំងនោះជាភាសាខ្មែរក៏ដោយ។ លើសពីនេះ អ្នកផ្តល់ចំលើយអះអាងនូវការយល់ថា អែបដែលដាក់ឱ្យប្រើប្រាស់នៅសាលារៀនត្រូវតែអនុវត្តតាមកម្មវិធីសិក្សារបស់ក្រសួង ដើម្បីងាយស្រួលពង្រឹងគុណភាពការរៀននិងបង្រៀន។ តារាង ៦ ក្រៅពីឧបសគ្គខាងលើ យើងត្រូវជានាថា មានអែបជាភាសាខ្មែរ ថែមម៉ោងបង្រៀន និងថែមកុំព្យូទ័របន្ទះទៀត។

**តារាង ៦៖**

របាយការណ៍នៃអ្នកឆ្លើយតបពីការអភិវឌ្ឍអែប

| សំណុំកុំព្យូទ័របន្ទះ | គ្រូបង្រៀន | សិស្ស | សរុប |
|---|---|---|---|
| អែបជាភាសាខ្មែរ | ៤១ | ៧៧ | ១១៨ |
| ថែមម៉ោងបង្រៀន | ៣០ | ៥២ | **៨២** |
| ថែមកុំព្យូទ័របន្ទះ | ៣២ | ៤៧ | ៧៩ |

ចំណាំ៖ ចំនួនសំណាកដែលឆ្លើយសំណួរនេះមាន ១៤២ នាក់ (សំណួរទាំងនេះមិនបានសួរនៅខេត្តកំពង់ឆ្នាំងទេ)

តាមការអង្កេតជារួម តាមរយៈចំណេះដឹងលើការប្រើប្រាស់កុំព្យូទ័របន្ទះ ទម្លាប់និងការអនុវត្តរបស់គ្រូនិងសិស្ស យើងអាចនិយាយជាទូទៅបានថា ការអនុវត្តរបស់គ្រូបង្រៀនគឺរង់ចាំតែពេលវេលាសមស្របទេ ដោយមកពីការបិទសាលាដែលពាក់ព័ន្ធនឹងជំងឺឆ្លងកូវីដ-១៩ ។

ការចង្អុលដំបូងបញ្ជាក់ថា នឹងមានការប្រើប្រាស់យ៉ាងទូលំទូលាយក្នុងចំណោមគ្រូបង្រៀននិងសិស្សនោះគឺថា វិធីសាស្ត្របង្រៀនបែបទំនើបដែលបានផ្តល់ការបង្រៀនយ៉ាងច្បាស់តាមរយៈគំនិតយោបល់ទៅកាន់សិស្ស ដោយការមើលវីដេអូបង្ហាញក្នុងរ៉ាឆែល។ តាមការសាកសួរសិស្សស្រីម្នាក់ឱ្យដឹងថា *«រៀនបែបនេះគឺធ្វើឱ្យខ្ញុំចាប់អារម្មណ៍ខ្លាំងណាស់ ហើយខ្ញុំចង់រៀនពេទ្យកាន់តែខ្លាំង ព្រោះវាធ្វើឱ្យខ្ញុំកាន់តែមានទំនុកចិត្ត»*។ មានគ្រូបង្រៀនម្នាក់អះអាងថា គាត់ចង់បង្រៀនដោយប្រើអែបដែរ តែមិនទាន់មានឱកាសល្អ។

គ្រូបង្រៀន និងសិស្សមួយចំនួនទទួចថា ចំនួនកុំព្យូទ័របន្ទះមិនគ្រប់គ្រន់ ហើយថា សាលាគួរមានច្រើនជាងនេះដើម្បីឱ្យសិស្ស និងគ្រូបានអនុវត្តញឹកញាប់។ លោកនាយកខ្លះបានលើកឡើងថា ការលើកកម្ពស់គុណភាពសិក្សា

តាមអែប មានដែនកំណត់ដោយរឹតបណ្តឹងម៉ោងសិក្សាគឺថា សិស្សម្នាក់អាចចូលក្នុងបន្ទប់កុំព្យូទ័របានយ៉ាងច្រើនពីរដងក្នុងមួយឆ្នាំ។

**៤.៧ ឱកាសនៃការអប់រំឌីជីថល**

ការសិក្សានេះ ក៏បានឈ្វេងយល់បន្ថែមពីការសិក្សាពីចម្ងាយ ដែលគ្រូបង្រៀននិងសិស្សនៅសាលាមធ្យមសិក្សាធនធានអនុវត្តបាន ក្នុងអំឡុងពេលមានជំងឺឆ្លងកូវីដ-១៩។ គោលបំណងគឺដើម្បីការស្រាវជ្រាវនេះ ដោយមានសំណួរមួយចំនួនទាក់ទងនឹងការប្រើប្រាស់សេវាអ៊ិនធឺណិត អាយស៊ីធី ដោយគ្រូបង្រៀន និងសិស្សបានប្រើប្រាស់ជាដើម។

នាយកសាលាភាគច្រើនបានអះអាងថា កុំព្យូទ័របន្ទះល្អណាស់សម្រាប់ការបង្រៀនសិស្សពីមេរៀនដែលមានពិសោធន៍ ដូចជា ពួកគាត់ឱ្យសិស្សមើលឃើញពីសកម្មភាពធ្វើពិសោធន៍ជាក់ស្តែង។ កន្លងមក ការរៀន និងបង្រៀនមានភាពអរូបិយច្រើន។ ដូចនេះ នៅពេលមានកុំព្យូទ័របន្ទះធ្វើឱ្យសិស្សមានចំណាប់អារម្មណ៍ក្នុងការរៀន ហើយមានភាពងាយស្រួលក្នុងការទទួល និងយល់ដឹងនូវទិដ្ឋភាពការសិក្សាជាក់ស្តែង។ ឧទាហរណ៍ ការធ្វើពិសោធន៍ប្រតិកម្មគីមី ជាធម្មតាគឺពិបាកធ្វើឡើងដោយផ្ទាល់ណាស់ ដោយសារខ្វះសម្ភារៈ ហើយក៏នឹងអាចជួបគ្រោះថ្នាក់។ ការបង្រៀនតាមអែប ជាពិសេស ការប្រើវ៉ាធែលអាចឱ្យសិស្សយល់ខ្លឹមសារនៃប្រតិកម្មគីមី ដោយមើលវីដេអូពិសោធន៍។ ប្រសិនបើមានលទ្ធភាព បន្ទាប់មក គ្រូបង្រៀនអាចធ្វើពិសោធន៍នេះដោយផ្ទាល់ម្តងទៀត។ ជាងនេះទៅទៀត ដំណើរការពិសោធមួយចំនួន ជាពិសេសក្នុងមេរៀនជីវវិទ្យា គឺត្រូវការពេលវេលា និងចំណាយថវិកាច្រើន ដូចនេះវ៉ាធែល គឺអាចជួយយើងបានច្រើនណាស់ទាក់ទង នឹងពេលវេលានិងការចំណាយនេះ។ ការរៀនដោយសៀវភៅពុម្ពគឺមិនអាចធ្វើឱ្យមានការទាក់ទាញចំណាប់អារម្មណ៍របស់សិស្ស និងធ្វើឱ្យសិស្សយកចិត្តទុកដាក់មេរៀនបានទេ។ ប៉ុន្តែបើតាមអែប សិស្សអាចមើលរូបភាព 3D ដែលធ្វើឱ្យសិស្សហាក់ដូចជាចាប់អារម្មណ៍ខ្លាំង និងមានទំនុកចិត្តក្នុងការសិក្សាខ្លាំងជាងមុន។

ការសិក្សានេះបង្ហាញថា ការរៀននិងបង្រៀនដោយប្រើ អាយស៊ីធី តាមរយៈអែបនិងវ៉ាធែលគឺនៅមានកម្រិត ប៉ុន្តែសិស្សនិងគ្រូបង្រៀនជាច្រើនបានយល់ដឹងពីអាយស៊ីធី នេះផងដែរ ដែលនេះក៏មានន័យថា ជាពេលវេលាដ៏សមស្របក្នុងការបញ្ចូលអាយស៊ីធី ទៅក្នុងការរៀននិងបង្រៀន (ដូចដែលមានបង្ហាញក្នុងតារាង ៧)។ អាយស៊ីធីគឺជាឧបករណ៍សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់សិស្ស និងគ្រូបង្រៀន ដែលមានន័យថា ការប្រើប្រាស់អាយស៊ីធីនេះគឺមានន័យថា យើងបាននឹងកំពុងធ្វើបច្ចុប្បន្នភាពក្នុងវិស័យអប់រំផងដែរ។

**តារាង ៤៖**

តារាងវិភាគ SWOT នៃការប្រើប្រាស់កុំព្យូទ័របន្ទះ

| | **ភាពខ្លាំង** | **ភាពខ្សោយ** |
|---|---|---|
| **កត្តាខាងក្នុង** | ១. គ្រូបង្រៀន និងសិស្សប្រើកុំព្យូទ័របន្ទះបានគ្រប់ពេល<br>២. មានកាលវិភាគបង្រៀនតាមកុំព្យូទ័របន្ទះ តាមតម្រូវការ<br>៣. បើកវគ្គបណ្តុះបណ្តាលពីការប្រើប្រាស់កុំព្យូទ័របន្ទះ | ១. គ្រូចេះ IT មានតិច<br>២. ត្រូវការកុំព្យូទ័របន្ទះបន្ថែម<br>៣. ការថែទាំកុំព្យូទ័របន្ទះ (ធ្វើបច្ចុប្បន្នភាពលើកម្មវិធីផ្នែកទន់) |
| | **ឱកាស** | **ការគំរាមកំហែង** |
| **កត្តាខាងក្រៅ** | ១. រៀនតាមអែប ឬការសិក្សាពីចម្ងាយកំពុងពេញនិយម<br>២. សិស្សស្ទើរគ្រប់គ្នាមានស្មាតហ្វូន<br>៣. បង្កើនជំនាញភាសាអង់គ្លេស និងអាយស៊ីធី | ១. អែបជាភាសាអង់គ្លេស<br>២. អែបមិនស៊ីគ្នាជាមួយមេរៀនតាមក្រសួង<br>៣. នៅផ្ទះសិស្ស និងគ្រូមិនអាចចូលក្នុងវ៉ាឆែលបាន |

ជាទូទៅ ការសិក្សាបង្ហាញថា សិស្សមានចំណាប់អារម្មណ៍ច្រើនក្នុងការសិក្សា នៅពេលដែលប្រើប្រាស់អាយស៊ីធីពេលគឺ ទូរស័ព្ទស្មាតហ្វូន និងកុំព្យូទ័របន្ទះ ដោយមានកម្មវិធីអែបដែលឆ្លើយតបដោយថាមវន្ត។ ការសិក្សានេះ ក៏រកឃើញផងដែរថា សិស្សចូលចិត្តរៀនតាមអែប និងវ៉ាឆែល ជាពិសេស ក្នុងមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ។

ជាការពិតណាស់ថា អាយស៊ីធី គឺស្ថិតនៅដំណាក់កាលដំបូងៗនៅឡើយ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជានៅកម្ពុជា។ ជាងនេះទៅទៀត នៅគ្រប់កម្រិតសិក្សា ពុំមានវិធីសាស្ត្របង្រៀនដោយប្រើអាយស៊ីធីនោះទេ សូម្បីតែនៅសាលាគរុកោសល្យ ។

មានការពិភាក្សាជាច្រើនពីអែបដែលប្រើក្នុងស្មាតហ្វូននិងកុំព្យូទ័របន្ទះ។ ជាទូទៅ គេមានអែបសម្រាប់ការអប់រំ ប៉ុន្តែ មិនប្រាកដថា គ្រប់អែបទាំងអស់មានប្រសិទ្ធភាពសម្រាប់គ្រូបង្រៀន និងសិស្សនោះទេ។ អែបមួយចំនួនគឺមិនខុសពី E-Book ឬ YouTube ទេ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃអែប ក្រសួងអប់រំ យុវជន និងកីឡា គួរធ្វើការវាយតម្លៃមុនដាក់បញ្ចូលក្នុងកម្មវិធីសិក្សា។ កន្លងមក ក្រសួងមិនទាន់មានគោលនយោបាយ ដើម្បីគ្រប់គ្រង និងវាយតម្លៃអែបទាំងនេះនៅឡើយទេ។

ជាទូទៅ ការបណ្តុះបណ្តាលលើការប្រើប្រាស់កុំព្យូទ័របន្ទះ គឺជាភាពចាំបាច់ឱ្យសាលាអាចដំណើរការទៅបាន បើទោះជាក្នុងបរិបទជំងឺឆ្លងកូវីដ-១៩ ក៏ដោយ ព្រោះថា គ្រូបង្រៀន និងសិស្សមានចំណេះដឹងមូលដ្ឋានក្នុងការប្រើប្រាស់អែប។ នាយកសាលាធនធានមធ្យមសិក្សាមួយចំនួនបានអះអាងថា យើងដឹងជាមុនថាមានតម្រូវការសម្រាប់ការសិក្សាពីចម្ងាយ ហើយស្របពេលដែលយើងមានកុំព្យូទ័របន្ទះភ្ជាប់កម្មវិធីសម្រាប់រៀនស្រាប់ ដូច្នេះ វាចាំបាច់ណាស់ក្នុងការដែលយើងត្រូវអភិវឌ្ឍសមត្ថភាពថ្មីៗបន្ថែមទៀត ដូចជា ការប្រើប្រាស់កម្មវិធី Zoom ឬ Google Meet ជាដើម។ អ្វីដែលសំខាន់ គ្រូបង្រៀនមួយចំនួនក៏យល់ថា នេះជាបុរេជំហាន ដើម្បីឈានដល់ការសម្រេចបាននូវការអប់រំបែបឌីជីថលដែរ។

## ៥. សន្និដ្ឋាន

លទ្ធផលការស្រាវជ្រាវ បែងចែកជាប្រាំផ្នែកធំៗគឺ (១) សមត្ថភាពអាយស៊ីធីរបស់គ្រូនិងសិស្ស (២) ចំណេះដឹងពីការប្រើប្រាស់កុំព្យូទ័របន្ទះ (៣) ឥរិយាបថចំពោះកុំព្យូទ័របន្ទះ (៤)ការអនុវត្តកុំព្យូទ័របន្ទះ និង (៥) ការដាក់បញ្ចូលកុំព្យូទ័របន្ទះ ឬឧបករណ៍ផ្សេងទៀតក្នុងការរៀន និងបង្រៀនក្នុងអំឡុងពេលជំងឺឆ្លងកូវីដ-១៩។

ជាទូទៅ សមត្ថភាពរបស់គ្រូ និងសិស្សពាក់ព័ន្ធនឹងអាយស៊ីធីគឺនៅមានកម្រិតនៅឡើយ។ គ្រូបង្រៀន និងសិស្សភាគច្រើនគ្មានឧបករណ៍អាយស៊ីធី ដូចជា ទូរស័ព្ទស្មាតហ្វូន កុំព្យូទ័របន្ទះ ឬសេវាអ៊ីនធឺណិតល្អនោះទេ។ លោកនាយកសាលាធនធានមួយចំនួនអះអាងថា «*មានតែកូនគេក្នុងទីប្រជុំជនទេ ដែលមានសមត្ថភាព ប៉ុន្តែបើកូនអ្នកជនបទគឺជួបការលំបាកហើយ*»។ ការចំណាយលើសេវាអ៊ីនធឺណិតគឺជាបញ្ហាប្រឈមមួយផងដែរ។ ទោះបីសិស្ស និងគ្រូបង្រៀនមួយចំនួនមានឧបករណ៍ទំនើបក៏ដោយ ពួកគេក៏នៅតែទៅប្រើអ៊ីនធឺណែតនៅអគារធនធាន។ ម្យ៉ាងវិញទៀត ភាសាអង់គ្លេសរបស់សិស្សគឺនៅមានកម្រិតនៅឡើយ ដែលពិបាកប្រើប្រាស់អាយស៊ីធី ។

«*ចំណេះដឹងពីការប្រើប្រាស់កុំព្យូទ័របន្ទះក្នុងចំណោមគ្រូបង្គោលគឺនៅពិបាកដែរ ដោយហេតុថា យើងទើបទទួលបានការបណ្តុះបណ្តាលថ្មីៗ*» នេះបើតាមការអះអាងរបស់គ្រូបង្គោលម្នាក់។ ការបណ្តុះបណ្តាលគ្រូលើការប្រើប្រាស់កុំព្យូទ័របន្ទះគឺធ្វើឡើងមុនពេលជំងឺឆ្លងកូវីដ-១៩ បន្តិច ហើយសាលាទាំងអស់ត្រូវបានបិទទ្វារដោយបង្រៀនតាមប្រព័ន្ធសិក្សាពីចម្ងាយ។ យ៉ាងណាក៏ដោយ គ្រូបង្រៀនដែលធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាល គឺយល់ដឹងច្រើនពីអែបដែលបានដំឡើងក្នុងកុំព្យូទ័របន្ទះ។ តាមការអង្កេត យើងឃើញថា គ្រូៗមានដំឡើងអែបផ្សេងៗចូលក្នុងទូរស័ព្ទដៃសម្រាប់សិក្សាបន្ថែម។ ទោះក្នុងអំឡុងពេលជំងឺកូវីដ-១៩ គ្រូមួយចំនួនបានណែនាំសិស្សឱ្យចេះប្រើប្រាស់អែបជាពិសេស គណិតវិទ្យា ដូចជា PhotoMaths។ អែបនេះគឺងាយស្រួលទាំងគ្រូទាំងសិស្ស ដើម្បីផ្ទៀងផ្ទាត់ចម្លើយ។

សិស្សម្នាក់នៅសាលាធម្យមសិក្សាធនធានបានអះអាងថា «ខ្ញុំបានអនុវត្តលំហាត់បានច្រើន ដោយសារមានអែបនេះជំនួយ ខ្ញុំធ្វើលំហាត់ហើយ ខ្ញុំអាចផ្ទៀងផ្ទាត់បានភ្លាមដោយមិនចាំបាច់គ្រូធ្វើកំណែឱ្យទេ»។

គ្រូបង្រៀន និងសិស្សបានបង្ហាញនូវឥរិយាបថវិជ្ជមានខ្លាំងចំពោះកុំព្យូទ័របន្ទះ។ បើទោះជា គ្រូបង្រៀន និងសិស្សទាំងនោះមិនទាន់បានប្រើប្រាស់វាឱ្យអស់លទ្ធភាព ដោយសារមានជំងឺឆ្លងកូវីដ-១៩ក៏ដោយ ក៏មានសញ្ញាបញ្ជាក់ថា ឧបករណ៍គឺជាអ្វីដែលគេត្រូវការសម្រាប់ការលើកកម្ពស់ការអប់រំ។ សិស្ស និងគ្រូបង្រៀនមួយចំនួនបានទិញស្មាតហ្វូនរួចជាស្រេច ដើម្បីដំឡើងអែបជាជំនួយដល់ការរៀន និងបង្រៀន ជាពិសេស ការរៀនសូត្រដោយឯករាជ្យ។ តាមការអះអាងរបស់អ្នកឆ្លើយតបមួយចំនួនថា ពួកគាត់បានណែនាំអ្នកផ្សេងឱ្យប្រើកុំព្យូទ័របន្ទះ ឬស្មាតហ្វូនដែរ ពីព្រោះថា ពួកគេអាចប្រើប្រាស់ប្រចាំថ្ងៃផង ហើយអាចដំឡើងអែបសម្រាប់សិក្សា ក៏ដូចការបង្រៀនផង។ គ្រូរូបវិទ្យាម្នាក់អះអាងថា *«មានអែបនេះ ខ្ញុំស្រួលបង្រៀនណាស់ ហើយខ្ញុំអាចចំណេញពេលពាក់កណ្ដាលបើធៀបនឹងការបង្រៀនធម្មតា»*។ គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រភាគច្រើនចូលចិត្តអែបសម្រាប់បង្រៀន ដោយសារវាបានបង្កលក្ខណៈងាយស្រួលក្នុងការបង្ហាញការអនុវត្តផ្ទាល់ និងការពិសោធដែលអាចទទួលយកបាន។

ការអនុវត្តលើការប្រើប្រាស់កុំព្យូទ័របន្ទះរបស់គ្រូនិងសិស្ស គឺរង់ចាំតែពេលវេលា ពីព្រោះថា កន្លងមកគឺមានជំងឺកូវីដ-១៩ ហើយសាលាទាំងអស់ត្រូវបិទទ្វារ។ សញ្ញាណដំបូងដែលថា នឹងមានការប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងចំណោមគ្រូបង្រៀន និងសិស្សនោះគឺថា ការបង្រៀនមានលក្ខណៈទំនើប ហើយសិស្សទទួលបានបញ្ញត្តិច្បាស់លាស់ដោយការមើលវីដេអូបង្ហាញក្នុងរ៉ាផែល។ តាមការសាកសួរសិស្សស្រីម្នាក់ឱ្យដឹងថា *«រៀនបែបនេះគឺធ្វើឱ្យខ្ញុំចាប់អារម្មណ៍ខ្លាំងណាស់ ហើយចង់រៀនពេទ្យកាន់តែខ្លាំង ព្រោះវាធ្វើឱ្យខ្ញុំកាន់តែមានទំនុកចិត្ត»*។ មានគ្រូបង្រៀនម្នាក់អះអាងថា គាត់ចង់បង្រៀនដោយប្រើអែបដែរ តែមិនទាន់មានឱកាស។ គ្រូនិងសិស្សមួយចំនួនទទូចថា ចំនួនកុំព្យូទ័របន្ទះមានតិចណាស់ហើយថា សាលាគួរមានច្រើនជាងនេះដើម្បីឱ្យសិស្ស និងគ្រូបានអនុវត្តញឹកញាប់។ លោកនាយកខ្លះបានលើកឡើងថា យើងពិបាកនិយាយថា កុំព្យូទ័របន្ទះនេះនឹងលើកកម្ពស់គុណភាពរៀន និងបង្រៀនណាស់ ព្រោះវាតិចពេកក្នុងមួយឆ្នាំ សិស្សម្នាក់អាចចូលក្នុងបន្ទប់កុំព្យូទ័របានយ៉ាងច្រើនពីរដងក្នុងមួយឆ្នាំ។

និយាយជារួម ការបណ្ដុះបណ្ដាលលើការប្រើប្រាស់កុំព្យូទ័របន្ទះគឺជាកត្តាចាំបាច់នាំឱ្យសាលាអាចដំណើរការបាន បើទោះជាក្នុងបរិបទកូវីដ-១៩ ពីព្រោះគ្រូបង្រៀន និងសិស្សមានចំណេះដឹងជាមូលដ្ឋានក្នុងការប្រើប្រាស់អែបសម្រាប់ការរៀន និងបង្រៀន។ នាយកសាលាធនធានមធ្យមសិក្សាមួយចំនួនបានអះអាងថា យើងដឹងជាមុនថាមានតម្រូវការសម្រាប់ការសិក្សាពីចម្ងាយ ហើយស្របពេលដែលយើងមានកុំព្យូទ័របន្ទះភ្ជាប់កម្មវិធីសម្រាប់រៀនស្រាប់ ដូច្នេះ វាចាំបាច់ណាស់ក្នុងការដែលយើងត្រូវអភិវឌ្ឍសមត្ថភាពថ្មីៗបន្ថែមទៀត ដូចជា ការប្រើប្រាស់កម្មវិធី Zoom ឬ

Google Meet ជាដើម។ អ្វីដែលសំខាន់ គ្រូបង្រៀនមួយចំនួនក៏យល់ថា នេះជាបុរេជំហាន ដើម្បីឈានដល់ការសម្រេចបាននូវការអប់រំបែបឌីជីថលដែរ។

## ៦. អនុសាសន៍

**ក្រសួងអប់រំ យុវជន និងកីឡា៖** សិស្ស និងគ្រូអះអាងថា ម៉ោងមានតិចពេកក្នុងការចូលទៅប្រើប្រាស់កុំព្យូទ័របន្ទះ ហើយពួកគេអាចប្រើបានតែនៅក្នុងបន្ទប់ធនធានប៉ុណ្ណោះ។ ប្រសិនបើអាចធ្វើបាន សិស្ស និងគ្រូគួរមានរ៉ាផែលនៅក្នុងបន្ទប់រៀនរៀងៗខ្លួន ដែលនឹងអាចអនុញ្ញាតឱ្យពួកគេប្រើប្រាស់បានគ្រប់ពេល អំឡុងពេលបង្រៀន។

មានអែប និងវីដេអូជាច្រើន មិនមានគិតថ្លៃសម្រាប់ការអប់រំតាមអនឡាញ។ ប្រសិនបើ ក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យ និងដាក់ចូលអែបនិងវីដេអូក្នុងរ៉ាផែល វានឹងជួយពង្រឹងនូវឧបករណ៍ការរៀន និងការបង្រៀនដែលអាចរកបាន និងជួយអភិវឌ្ឍការពិសោធរបស់អ្នកប្រើប្រាស់បាន។

ប្រសិនបើអាច ក្រសួងគួរបកប្រែខ្លឹមសារភាសាអង់គ្លេសដែលមានក្នុងរ៉ាផែលទៅជាភាសាខ្មែរ ដោយហេតុថា គ្រូបង្រៀន និងសិស្សនៅជនបទគឺមិនទាន់មានបំណិនភាសាបានទូលំទូលាយនៅឡើយ។ វាគួរកត់សំគាល់ថា ឯកសារដែលមានក្នុងរ៉ាផែល គឺមានទាំងភាសាខ្មែរ និងអង់គ្លេស ប៉ុន្តែ ឯកសារជាភាសាអង់គ្លេស គឺមានភាពទាក់ទាញ និងគុណភាពល្អជាង។

ការបង្រៀនដោយប្រើអាយស៊ីធីគឺមិនទាន់បានផ្សព្វផ្សាយទូលំទូលាយទេ ដូច្នេះក្រសួងអប់រំ យុវជន និងកីឡា គួរបន្ថែមអាយស៊ីធីទៅក្នុងគ្រប់មុខវិជ្ជានៅកម្រិតសិក្សាទូទៅ និងក្នុងការអភិវឌ្ឍវិជ្ជាជីវៈនៅតាមសាលាគរុកោសល្យគ្រប់កម្រិត។ លើសពីនេះទៀត កម្មវិធីសិក្សាគួរតែមានបញ្ចូលអាយស៊ីធី ដូចនេះ គ្រូទាំងអស់ត្រូវតែបង្រៀនដោយប្រើអាយស៊ីធី។ គ្រូបង្រៀន និងនាយកយល់ថា ការបង្រៀនដោយប្រើ អាយស៊ីធីគ្រាន់តែជាកម្មវិធីជម្រើសបន្ថែមទេ។

វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ អាយស៊ីធី គឺនៅមានការខ្វះចន្លោះច្រើន ជាពិសេស គ្រូបង្រៀនដែលមានអាយុចាប់ពី៤៥ឡើង ដែលគាត់ហាក់មានការស្ទាក់ស្ទើរក្នុងការប្រើប្រាស់អាយស៊ីធី សម្រាប់ការបង្រៀន ដោយហេតុថា គាត់ហាក់មិនទុកចិត្តលើប្រព័ន្ធនេះទេ។ ដូច្នេះ ដើម្បីឱ្យមានការប្រើប្រាស់បានទូលំទូលាយ វគ្គបណ្តុះបណ្តាលអាយស៊ីធី គួរធ្វើឡើងឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបានក្នុងចំណោមគ្រូៗទូទៅ។ ម្យ៉ាងទៀត ក្រសួងគួរធ្វើសៀវភៅមគ្គុទេសក៍ ស្តីពីការប្រើប្រាស់កុំព្យូទ័របន្ទះ ដើម្បីជំនួយដល់ការបង្រៀនប្រើប្រាស់ឱ្យបានលម្អិតជាងនេះ ឬបើអាចដាក់បញ្ចូលសកម្មភាពក្នុងសៀវភៅគោលរបស់ក្រសួង។

**គ្រូបង្រៀន៖** គួរពង្រឹងបំណិន អាយស៊ីធី និង ភាសាអង់គ្លេសឱ្យបានច្រើន ព្រោះថា វានឹងជួយពង្រឹងការរៀន និងបង្រៀនបានច្រើន ពីព្រោះឯកសារក្នុងវ៉ាធែលគឺភាគច្រើនជាភាសាអង់គ្លេស ហើយមានគុណភាពល្អបើប្រៀបនឹងឯកសារផលិតក្នុងស្រុក។

គ្រូបង្រៀនគ្រប់មុខវិជ្ជានៅសាលាមធ្យមសិក្សាធនធាន គួរតែទទួលបានការបណ្តុះបណ្តាលជាគ្រូឧទ្ទេស ហើយពួកគាត់នឹងក្លាយជាគ្រូបង្គោលនៅតាមសាលាមធ្យមសិក្សាធនធាន សាលាបណ្តាញ និងសាលាកម្រង។ ប្រសិនបើអាច គ្រូបង្គោលទាំងនោះគួរមានប្រាក់ឧបត្ថម្ភសម្រាប់ការងារបន្ថែមនេះ ដើម្បីលើកទឹកចិត្តក្នុងការពង្រឹង និងពង្រីកចំណេះដឹង អាយស៊ីធី សម្រាប់ការរៀន និងបង្រៀន។

កន្លងមក គ្រូតាមមុខវិជ្ជានីមួយៗ តែងពឹងអាស្រ័យគ្រូ IT ដើម្បីដំណើរការកុំព្យូទ័របន្ទះនៅក្នុងបន្ទប់អគារធនធាន ហើយប្រសិនបើគ្រូ IT អវត្តមាន គឺពិបាកក្នុងការដំណើការកុំព្យូទ័របន្ទះណាស់។ ដូចនេះ យើងគួរមានឯកសារណែនាំស្តីពីការប្រើប្រាស់កុំព្យូទ័របន្ទះ សម្រាប់គ្រូបង្រៀន និងសិស្ស។ គ្រូបង្រៀន និងសិស្សទាំងអស់គួរតែមានសមត្ថភាពប្រើប្រាស់ឧបករណ៍ទាំងនេះបានដោយឯករាជ្យ តាមឯកសារណែនាំនេះជាគោល។

## ឯកសារពិគ្រោះ


Berson, I., Berson, M., & McGlinn Manfra, M. (2012). Touch, type, and transform: iPads in the social studies classroom. *Social Education, 76*(2), 88-91.

Clayton, K., & Murphy, A. (2016). Smartphone Apps in Education: Students Create Videos to Teach Smartphone Use as Tool for Learning. *Journal of Media Literacy Education, 8*(2), 99-109.

Doering, A., Koseoglu, S., Scharber, C., Henrickson, J., & Lanegran, D. (2014). Technology Integration in K–12 Geography Education Using TPACK as a Conceptual Model. *Journal of Geography, 113*(6), 223-237. doi:10.1080/00221341.2014.896393

Finkelstein, N., Adams, W., Keller, C., Perkins, K., & Wieman, C. (2006). Hightech tools for teaching physics: The physics education technology project. *Journal of Online Learning and Teaching, 2*(3), 110-121.

Fister, K. R., & McCarthy, M. L. (2008). Mathematics instruction and the tablet PC. *International Journal of Mathematical Education in Science and Technology, 39*(3), 285-292.

Hagevik, R., & Cherner, T. (2016). *Discipline Literacy in Science and Math Education: Utilizing Mobile Technologies and Educational Apps in an Inquiry-based Learning Environment*. Paper presented

at the Society for Information Technology & Teacher Education International Conference 2016, Savannah, GA, United States. https://www.learntechlib.org/p/171975

Hu, H., & Garimella, U. (2014). iPads for STEM teachers: A case study on perceived usefulness, perceived proficiency, intention to adopt, and integration in K-12 instruction. *Journal of Educational Technology Development and Exchange (JETDE), 7*(1), 4.

Huang, L. (2015). Chemistry apps on smartphones and tablets. *Chemistry Education: Best Practices, Innovative Strategies and New Technologies, Wiley*.

Major, L., Haßler, B., & Hennessy, S. (2017). Tablet use in schools: impact, affordances and considerations *Handbook on digital learning for K-12 schools* (pp. 115-128): Springer.

MoEYS. (2019). *Education Strategic Plan 2018-2023*. Phnom Penh.

Norris, C. A., & Soloway, E. (2015). Mobile technology in 2020: Predictions and implications for K–12 education. *Educational Technology*, 12-19.

OECD. (2010). *PISA 2009 Results: What Makes a School Successful?* Vol. XII. Retrieved from https://www.oecd-ilibrary.org/content/publication/9789264091559-en doi:doi:https://doi.org/10.1787/9789264091559-en

Sharples, M., Taylor, J., & Vavoula, G. (2010). A theory of learning for the mobile age *Medienbildung in neuen Kulturräumen* (pp. 87-99): Springer.

Shim, K.-C., Park, J.-S., Kim, H.-S., Kim, J.-H., Park, Y.-C., & Ryu, H.-I. (2003). Application of virtual reality technology in biology education. *Journal of Biological Education, 37*(2), 71-74.

Thoermer, A., & Williams, L. (2012). Using digital texts to promote fluent reading. *The Reading Teacher, 65*(7), 441-445.

Watlington, D. (2011). *Using iPod touch and ipad educational apps in the classroom.* Paper presented at the Society for Information Technology & Teacher Education International Conference.

**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវ

# បទពិសោធល្អ និងឧត្តមានុវត្តន៍នៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្ពុជា

**ឡាយ សុវិជ្ជា *[១] ស៊ុក សុផល [២] ស៊ិន ណារី [៣]**

*[១ ២ ៣] នាយកដ្ឋានគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា ប្រទេសកម្ពុជា អ៊ីមែលរបស់អ្នកនិពន្ធ៖ *sovichea_lay@yahoo.com*

បានទទួល៖ មេសា ២០២១ សម្រេចយក៖ មិថុនា ២០២១

## សង្ខិត្តន័យ

ការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) ត្រូវបានចាត់ទុកថា ជាសកម្មភាពស្នូលនៃកំណែទម្រង់សាលារៀន ដើម្បីលើកកម្ពស់លទ្ធផល និងការនាំមកនូវសេវាអប់រំប្រកបដោយប្រសិទ្ធភាព។ SBM គឺជាយន្តការថ្មីមួយដែលធ្វើឱ្យសាលារៀនក្លាយជាទ្រព្យសម្បត្តិរបស់សហគមន៍មូលដ្ឋាន ហើយវានឹងក្លាយជាដំណើរដ៏វែងឆ្ងាយថ្មីមួយក្នុងការជំរុញកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា(អយក) ដើម្បីពង្រឹងសមត្ថភាព ក្នុងការគ្រប់គ្រងធនធានមនុស្ស និងអនុវត្តផែនការផ្តោតលើលទ្ធផល ថវិកា និងការប្រតិបត្តិ ក្រោមការចូលរួមត្រួតពិនិត្យដោយផ្ទាល់របស់សហគមន៍ នៅកម្រិតសាលារៀន។ ការលើកកម្ពស់ស្វ័យភាព និងការផ្ទេរទំនួលខុសត្រូវទៅកម្រិតសាលារៀន តាមរយៈការឆ្លើយតបបែបលើកទឹកចិត្តស្របទៅនឹងតម្រូវការក្នុងស្រុកបានក្លាយជាអាទិភាពគោលនយោបាយថ្មីសម្រាប់ ការអភិវឌ្ឍសាលារៀន សមត្ថភាពគ្រូបង្រៀន និងការចូលរួមពីក្រុមគ្រួសារ។ ការសិក្សានេះប្រើវិធីសាស្ត្របរិមាណវិស័យ ហើយសំណាកសាលារៀនត្រូវបានជ្រើសរើសដោយចៃដន្យពីខេត្តចំនួនប្រាំបីសម្រាប់ការប្រមូលទិន្នន័យ។ ស្ថានភាពបច្ចុប្បន្ននៃការអនុវត្តរបស់ SBM ត្រូវបានពិនិត្យរួមមាន៖ ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងសាលារៀន ការគ្រប់គ្រងថវិកា កម្មវិធីសិក្សានិងការបង្រៀន ការ

គ្រប់គ្រងធនធាន និងការគ្រប់គ្រងបុគ្គលិក។ យោងតាមទិន្នន័យ ការអនុវត្តនាពេលបច្ចុប្បន្នរបស់ SBM នៅក្នុងសាលារៀនគឺស្ថិតនៅលើគន្លងដ៏ត្រឹមត្រូវ ពីព្រោះនាយកសាលា គ្រូបង្រៀន និងសមាជិកនៃគណៈកម្មការគ្រប់គ្រងសាលារៀនធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាដើម្បីអភិវឌ្ឍសមត្ថភាពសាលារៀន និងជំរុញលទ្ធផលអប់រំ។ នេះគឺជាសញ្ញាវិជ្ជមាននៃកំណើន ដើម្បីបន្តពង្រីក និងពង្រឹងវេទិកា SBM នៅក្នុងប្រព័ន្ធអប់រំកម្ពុជា។ លទ្ធផលនៃការសិក្សានេះ SBM អាចផ្តល់ព័ត៌មានអំពីការអនុវត្តបច្ចុប្បន្ន និងរួមចំណែកដល់ការដាក់ចេញអន្តរាគមន៍ គោលនយោបាយ និងការដាក់បញ្ចូលការអនុវត្ត នាពេលអនាគត។

**ពាក្យគន្លឹះ៖** ការគ្រប់គ្រងតាមសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន ស្វ័យភាព វិមជ្ឈការ ការចូលរួមពីសហគមន៍

**អាគតដ្ឋាន:** ឡាយ, ស., ស៊ុក, ស., & ស៊ិន, ណ. (២០២១). បទពិសោធ និងឧត្តមានុវត្តន៍នៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្ពុជា. *កាលិកបត្រអប់រំកម្ពុជា, ៤*(១),៤២-៥៩។

## ១. សេចក្តីផ្តើម

កំណែទម្រង់ការគ្រប់គ្រងតាមសាលារៀន (SBM) ត្រូវបានគេមើលឃើញថា ជាយុទ្ធសាស្រ្តដ៏មានប្រសិទ្ធភាពមួយ ដើម្បីការលើកកម្ពស់គុណភាពអប់រំ ដោយផ្តល់សិទ្ធិអំណាចលើការធ្វើសេចក្តីសម្រេចចិត្តឱ្យចូលកាន់តែជិត ទៅរកសហគមន៍មូលដ្ឋាន និងការពង្រឹងគណនេយ្យភាពរវាងសាលារៀន ឪពុកម្តាយ និងសិស្ស។ កំណែទម្រង់ SBM ផ្តល់សិទ្ធិអំណាចដល់នាយកសាលានិងគ្រូបង្រៀន និងបង្កើនការលើកទឹកចិត្តវិជ្ជាជីវៈរបស់ពួកគេ ដោយបង្កើនស្មារតីនៃភាពជាម្ចាស់របស់សាលារៀន ហើយ SBM ត្រូវបានប្រើដើម្បីធ្វើវិមជ្ឈការអំណាចពីរាជរដ្ឋាភិបាលថ្នាក់កណ្តាលដល់កម្រិតសាលារៀន (Caldwell, 2005)។ គោលការណ៍នៃក្របខ័ណ្ឌការគ្រប់គ្រងតាមសាលារៀនរួមមាន៖ វិមជ្ឈការ ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀនដែលមានការចូលរួម ការអភិវឌ្ឍសមត្ថភាពបុគ្គលិកនៃការគ្រប់គ្រងដោយស្វ័យភាព និងការពិនិត្យតាមដាននិងវាយតម្លៃ យោងតាមអ្នកស្រាវជ្រាវមួយចំនួន (Lunenburg & Ornstein, 2011; Cheong & Mo, 2007)។ តាមរយៈ SBM ការធ្វើសេចក្តីសម្រេចចិត្តត្រូវបានធ្វើវិមជ្ឈការដល់ថ្នាក់ស្រុក និងសាលារៀន ដើម្បីអភិវឌ្ឍការធ្វើគោលនយោបាយប្រកបដោយបរិយាបន្ន និងការគ្រប់គ្រងដោយមានការចូលរួម។ SBM គឺជាដំណើរការដាក់លាក់មួយ ដែលគ្រូបង្រៀនអាចចូលរួមក្នុងការសម្រេចចិត្ត ការរៀបចំរចនាសម្ព័ន្ធឡើងវិញ និងការគ្រប់គ្រង (Goldman et al. 1993)។

នៅទូទាំងពិភពលោក ការបញ្ចូល SBM ត្រូវបានដាក់អនុវត្តយ៉ាងទូលំទូលាយ ដែលដូចជា មធ្យោបាយនៃការធ្វើវិមជ្ឈការអំណាចសម្រាប់កំណែទម្រង់សាលារៀន (Ai Shoraku, 2016) គឺជាប្រព័ន្ធជួយអ្នកដឹកនាំគ្រប់គ្រងសាលារៀនឱ្យកាន់តែមានតម្លាភាព និងមិនសូវពុករលួយ ព្រមទាំងផ្តល់ឱកាសដល់ឪពុកម្តាយ និងអ្នកពាក់ព័ន្ធ ដើម្បីបង្កើនវិសាលភាព និងគុណភាពនៃការចូលរួមរបស់ពួកគេ។ ការរៀបចំប្រកបដោយប្រសិទ្ធភាពនៃការបណ្តុះបណ្តាលក្នុងការសម្រេចចិត្តរួមគ្នា ជំនាញអន្តរបុគ្គល និងជំនាញគ្រប់គ្រងសម្រាប់សមាជិកក្រុមប្រឹក្សាសាលា ធ្វើឱ្យពួកគេកាន់តែមានសមត្ថភាពតាមរយៈការចូលរួមក្នុងដំណើរការ SBM ក្នុងពេលតែមួយ ក៏ផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ទាំងមូល (Briggs & Wohlstetter, 1999)។ ឧទាហរណ៍ របាយការណ៍សិក្សានៅប្រទេសហ្វីលីពីនបានរកឃើញថា មានការលើកកម្ពស់លទ្ធផលការសិក្សា បន្ទាប់ពីសាលាអនុវត្តការគ្រប់គ្រងតាមសាលារៀន។ ជាលទ្ធផល សិស្សដែលបានចូលរួមក្នុងសាលាដែលអនុវត្ត SBM មានពិន្ទុខ្ពស់ជាងសិស្សនៅក្នុងសាលាដែលមិនបានអនុវត្ត SBM (Nidhi Khattri et al., 2012)។ ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនរួមមាន នាយក គ្រូបង្រៀន មាតាបិតា និងអាជ្ញាធរមូលដ្ឋាន បានផ្តល់ការគាំទ្រយ៉ាងរឹងមាំក្នុងការគ្រប់គ្រងសាលារៀនមូលដ្ឋានរបស់ពួកគេ ស្របតាមគោលនយោបាយជាតិ និងបំពេញតម្រូវការជាក់ស្តែងនៃបរិបទមូលដ្ឋានរបស់ខ្លួន។

ដើម្បីបង្កើនការចូលរួម និងផលជះរបស់អ្នកពាក់ព័ន្ធទាំងអស់ (ដូចជា សមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងក្រុមប្រឹក្សាសាលារៀន) ក្នុងការផ្តល់អាទិភាពដល់ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីប្រកបដោយប្រសិទ្ធភាពនៅក្នុងសាលារៀន ចាប់តាំងពីឆ្នាំ២០០១ មក ក្រសួងអប់រំ យុវជន និងកីឡាបានណែនាំ គោលគំនិតនៃវិមជ្ឈការក្នុងផែនការយុទ្ធសាស្ត្រអប់រំរបស់ខ្លួន (២០០១-២០០៥)។ SBM គឺជាផ្នែកមួយនៃដំណើរការវិមជ្ឈការ ដែលក្រសួងអប់រំបានអនុញ្ញាតឱ្យមានស្វ័យភាពនៃភាពជាអ្នកដឹកនាំ ការគ្រប់គ្រង និងការសម្រេចចិត្តទាក់ទងនឹងការអភិវឌ្ឍសាលារៀន និងសមិទ្ធផលការសិក្សារបស់សិស្ស នៅកម្រិតមូលដ្ឋាន (ស្រុក សហគមន៍ និងសាលារៀន) [MoEYS, 2018]។ SBM គឺជាយន្តការដែលអាចទៅរួចសម្រាប់ការលើកកម្ពស់នូវការប្រើប្រាស់ធនធានក្នុងស្រុក តាមរយៈការរៀបចំរចនាសម្ព័ន្ធអភិបាលកិច្ចសាលាឡើងវិញ ដោយផ្អែកលើការចូលរួមកាន់តែខ្លាំងរបស់សហគមន៍។ ដូច្នេះ វាមានសារៈសំខាន់ដែល SBM ត្រូវបានរចនាឡើងដោយមានគោលដៅនៃកំណែទម្រង់ការអប់រំជាប្រព័ន្ធ (Blank, 2004, Conley, 1993)។

នាពេលថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកំណែទម្រង់អប់រំដ៏ទូលំទូលាយមួយក្នុងគោលបំណងបង្កើនចំនួនយុវជន និងមនុស្សពេញវ័យ ឱ្យមានអក្ខរកម្ម លេខ និងជំនាញទន់ច្បាស់លាស់ រួមបញ្ចូលជាមួយជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឈានទៅសម្រេចគោលដៅបង្កើនការងារ និងសហគ្រិនភាព។ កំណែទម្រង់អប់រំស៊ីជម្រៅបានកំណត់ជាចម្បងនូវធាតុផ្សំសំខាន់ៗ ចំនួន ៤ សម្រាប់ការគ្រប់គ្រងតាម

សាលារៀន (SBM)៖ រដ្ឋបាលនិងការគ្រប់គ្រងទូទៅ ការគ្រប់គ្រងការបង្រៀននិងរៀន ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិក (Hang Chuon, 2017)។ នាយកសាលានៅក្នុងសាលារៀនដែលកំពុងអនុវត្ត SBM គួរតែមានចំណេះដឹងគ្រប់គ្រាន់លើការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីប្រើប្រាស់វាឱ្យមានប្រសិទ្ធភាពសម្រាប់កម្មវិធីប្រតិបត្តិការ។ វាត្រូវបានគេមើលឃើញថា នៅពេលដែល SBM ត្រូវបានអនុវត្តទៅដល់សាលារៀន យន្តការនៃការផ្ទេរថវិកាសម្រាប់ប្រតិបត្តិការត្រូវបានផ្លាស់ប្តូរ ដូចដែលបានថ្លែងដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា «កំណែទម្រង់ហិរញ្ញវត្ថុក៏អាចរួមបញ្ចូលការផ្ទេរប្រភពថវិកាដោយផ្ទាល់ពីរតនាគារជាតិ ទៅសាលារៀន ឬដើម្បីកែលម្អនីតិវិធីហិរញ្ញវត្ថុ និងអភិបាលកិច្ច ដើម្បីទទួលបានលទ្ធផលសិក្សាកាន់តែប្រសើរឡើង» (Hang-Chuon, 2016)។

ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចចិត្តសាកល្បងកម្មវិធី SBM បច្ចុប្បន្ន ក្នុងវិធីដ៏ទូលំទូលាយជាងគំនិតផ្តួចផ្តើម SBM ពីមុននៅសាលាមធ្យមសិក្សា ក្រោមគម្រោងលើកកម្ពស់ការអប់រំមធ្យមសិក្សា(SEIP)។ កម្មវិធីដែលមានស្រាប់នៅសាលារៀនពីមុន មិនមែនឈប់ប្រើទេ ប៉ុន្តែមានការសហការជាមួយកម្មវិធីសាកល្បងថ្មីនេះ។ វិទ្យាល័យចំនួន ១០០ ត្រូវបានជ្រើសរើសដើម្បីអនុវត្តកម្មវិធី SBM ដោយមានការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុពីធនាគារពិភពលោក និងក្រុមជំនួយការថ្នាក់កណ្តាលរបស់ក្រសួង ហើយគេរំពឹងថា កម្មវិធីនេះនឹងពង្រីកពី ១០០ ទៅ ៥០០ សាលារៀននៅគ្រប់កម្រិតទាំងអស់នៅឆ្នាំ ២០២៣។ ប្រព័ន្ធ «ការគ្រប់គ្រងតាមសាលារៀន» ត្រូវបានអនុម័តជាផ្លូវការ ដើម្បីណែនាំពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន ដោយក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៨។ គោលបំណងនៃការសិក្សានេះគឺដើម្បីពិនិត្យមើលស្ថានភាពការអនុវត្តបច្ចុប្បន្ននៃសកម្មភាព SBM នៅក្នុងសាលារៀន (ការចូលរួម តម្លាភាព សមត្ថភាព និងការផ្តល់ការគាំទ្រ ដោយភ្នាក់ងារពាក់ព័ន្ធសម្រាប់ការអនុវត្ត SBM)។ លទ្ធផលនៃការសិក្សានេះ ជួយផ្តល់ព័ត៌មានអំពីយុទ្ធសាស្ត្រគោលនយោបាយបឋម ដើម្បីបង្កើនប្រសិទ្ធភាពការអនុវត្ត SBM ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីជានាបាននូវការយល់ដឹងព័ត៌មានដែលបានផ្តល់ និងឱ្យបានទូលំទូលាយអំពីស្ថានភាពការអនុវត្ត SBM នាបច្ចុប្បន្ន នៅកម្រិតសាលាក្នុងប្រទេសកម្ពុជា អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ។ ដើម្បីជានាបាននូវការអនុវត្ត SBM បច្ចុប្បន្នរបស់សាលា និងទិសដៅអនាគតរបស់ SBM កម្រងសំណួរត្រូវបានបង្កើតឡើងជាពីរផ្នែកសំខាន់ៗ៖ ការអនុវត្តបច្ចុប្បន្ន និងទស្សនៈនៃ SBM នៅមូលដ្ឋានសាលារៀន នាពេលអនាគត ដោយវាយតម្លៃមាត្រដ្ឋានពី ១ (មិនយល់ស្របខ្លាំង) ដល់ ៥ (យល់ស្របខ្លាំង)។

ឧបករណ៍ស្រាវជ្រាវដែលបានរចនាឡើងជាកម្រងសំណួរបែបសម្ព័ន្ធដែលបែងចែកជាបីប្រភេទសំណាក។ ប្រភេទទី១ ផ្តោតលើនាយកសាលា ទី២ ផ្តោតលើគ្រូបង្រៀន ហើយប្រភេទទី៣ចុងក្រោយគឺផ្តោតលើគណៈកម្មការគ្រប់គ្រងសាលារៀន។ បន្ទាប់ពីបំពេញកម្រងសំណួររួច ក្រុមស្រាវជ្រាវបានស្នើឱ្យនាយកសាលា និងសហការីផ្តល់ពេលវេលាសម្រាប់ការសម្ភាស ក្នុងស្វែងរកការបង្កើនវិសាលភាពនៃព័ត៌មានដែលប្រមូលបាន ដើម្បីគាំទ្រការវិភាគ និងការបកស្រាយទិន្នន័យឱ្យកាន់តែប្រសើរឡើង។ ការស្រាវជ្រាវបានអង្កេតជាចម្បងលើការអនុវត្ត SBM នៅសាលារៀន ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០១៩ ទន្ទឹមនឹងនោះ វាបានពិនិត្យលើការអនុវត្តរបស់ប្រទេសផ្សេងទៀតនៅក្នុងការរំឭកទ្រឹស្តីចុងក្រោយ។

សម្រាប់សំណាក គឺមានអនុវិទ្យាល័យចំនួន ២៣៥ (នាយកសាលា គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន) រួមទាំង SBM និងសាលាបណ្តាញរបស់ខ្លួននៅក្នុងខេត្តចំនួន ១២ ត្រូវបានជ្រើសរើសដោយចៃដន្យដោយការចាប់ឆ្នោតពីបញ្ជីខេត្តគោលដៅ ដូចជា៖ បាត់ដំបង កំពត កំពង់ចាម កោះកុង មណ្ឌលគិរី កំពង់ឆ្នាំង ស្ទឹងត្រែង ព្រៃវែង កំពង់ស្ពឺ ប៉ៃលិន ព្រះវិហារ និងតាកែវ។

## ៣. លទ្ធផលនិងការពិភាក្សា

### ៣.១ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលា

យោងតាមបទសម្ភាស នាយកសាលាមួយចំនួនធំបានយល់ស្របថា យុទ្ធសាស្ត្រលេចធ្លោមួយក្នុងការអនុវត្ត SBM បច្ចុប្បន្ន គឺតាមរយៈយន្តការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្រិតសញ្ញាបត្រសម្រាប់នាយកសាលា និងគ្រូបង្រៀន។ សាលា SBM ទាំងអស់តម្រូវឱ្យគ្រូបង្រៀនយ៉ាងហោចណាស់មានសញ្ញាបត្របរិញ្ញាបត្រ។ ដើម្បីវាយតម្លៃកម្រិតនៃ SBM នៅក្នុងបរិបទនៃសាលារៀននីមួយៗ ប៉ារ៉ាម៉ែត្រជាច្រើនត្រូវបានបង្កើតឡើងដើម្បីវាយតម្លៃការអនុវត្តនៅក្នុងសាលារៀន រួមទាំងស្វ័យភាពគ្រប់គ្រាន់ក្នុងភាពជាអ្នកដឹកនាំ កិច្ចសហការក្នុងបរិយាកាសការងារ សមត្ថភាពត្រួតពិនិត្យ និងវាយតម្លៃសិទ្ធិអំណាចក្នុងការសម្រេចចិត្តរបស់បុគ្គលិក គឺជាសមត្ថភាពក្នុងការកសាងបណ្តាញសហគមន៍។

**ក្រាហ្វ ១** បានបង្ហាញថា នាយកសាលាភាគច្រើន ៨២.៤% យល់ស្របថា ពួកគេមានស្វ័យភាពគ្រប់គ្រាន់ក្នុងដឹកនាំការអនុវត្តដើម្បីអភិវឌ្ឍសាលារៀន ដោយបង្ហាញថា សាលារៀនក្នុងបរិបទបច្ចុប្បន្នមានស្វ័យភាពក្នុងការគ្រប់គ្រងខ្លួនឯង និងភាពជាអ្នកដឹកនាំនៅក្នុងសាលារបស់ពួកគេ។ គួរកត់សម្គាល់ថា ចំនួនអ្នកឆ្លើយសំណួរដែលរំពឹងថា នឹងបង្កើនស្វ័យភាពនាពេលអនាគតបានកើនឡើងពី ៧.៨% ទៅ ៥២.៩%។ ការកើនឡើងចំនួននេះក៏ត្រូវបានគេសន្និដ្ឋានថា មានឧបសគ្គខ្លះទៀតនៅសេសសល់ ដែលពួកគេនៅតែមិនអាចអនុវត្តសិទ្ធិ និង

មិនមានសិទ្ធិអំណាចពេញលេញរបស់ពួកគេក្នុងការគ្រប់គ្រងស្វ័យភាព។ ដោយផ្អែកលើអ្នកឆ្លើយសំណួរ វាអាចសន្និដ្ឋានបានថា បើទោះបី នាយកសាលាមានស្វ័យភាពគ្រប់គ្រាន់ក្នុងពេលបច្ចុប្បន្នក៏ដោយ ក៏ពួកគេរំពឹងយ៉ាងខ្លាំងថា នឹងទទួលបានស្វ័យភាពបន្ថែមទៀតនាពេលអនាគត។




**ក្រាហ្វ ១៖** នាយកសាលាភាគច្រើនមានស្វ័យភាពគ្រប់គ្រាន់ ដើម្បីដឹកនាំការអនុវត្តដែលត្រឹមត្រូវដើម្បីលើកកម្ពស់ការរៀនរបស់សិស្សនាពេលបច្ចុប្បន្ន ហើយមានបំណងចង់ទទួលបានស្វ័យភាពបន្ថែមទៀតនៅក្នុងតួនាទីរបស់ពួកគេនាពេលអនាគត

ការស្រាវជ្រាវបានបង្ហាញថា ទោះបីជា មានមតិខុសគ្នាខ្លះក៏ដោយ នាយកសាលាភាគច្រើនត្រូវបានលើកទឹកចិត្ត និងគាំទ្រក្នុងការកសាងបរិយាកាសសហការសម្រាប់គ្រូបង្រៀននិងសហគមន៍ជុំវិញ (**ក្រាហ្វ ២**)។ ទាំងនេះបង្ហាញពីទស្សនៈស្របនឹងគោលការណ៍ណែនាំរបស់ SBM ដែលលើកទឹកចិត្តនាយកសាលាឱ្យបង្កើតបណ្តាញដ៏ល្អជាមួយភាគីពាក់ព័ន្ធទាំងខាងក្នុង និងខាងក្រៅ។ ក្នុងន័យនេះ នាយកសាលាភាគច្រើនយល់អំពីសារៈសំខាន់នៃភាគីពាក់ព័ន្ធ និងឥទ្ធិពលវិជ្ជមានរបស់ពួកគេទៅលើការអភិវឌ្ឍសាលារៀន និងការទទួលខុសត្រូវរួម។ ដូចដែលបានបង្ហាញនៅក្នុង**ក្រាហ្វ ២** ថា នាពេលបច្ចុប្បន្ននេះ នាយកសាលាមួយចំនួនតូចមិនយល់ថាពួកគាត់មានលទ្ធភាពទទួលបានការគាំទ្រដែលត្រូវការសម្រាប់ការកសាងវប្បធម៌សហការ។ ទោះបីជាយ៉ាងណាពួកគាត់ចង់ឱ្យវាមានដំណើរការកាន់តែច្រើន នាពេលអនាគត។ លើសពីនេះទៀត ពួកគេយល់ស្របយ៉ាងមុតមាំលើសារៈសំខាន់នៃការកសាងវប្បធម៌សហការគ្នារវាងគ្រូបង្រៀន និងអ្នកពាក់ព័ន្ធនៅក្នុងសាលា ដូចចំនួនអ្នកឆ្លើយតបដែលបង្ហាញពីការយល់ស្រប ឬយល់ស្របខ្លាំង គឺប្រហែល ២៥% (សម្រាប់បច្ចុប្បន្ន) ខណៈដែល

វាមានប្រហែល ៥៥% (សម្រាប់ពេលអនាគត)។ សរុបមក នាយកសាលាភាគច្រើនយល់ឃើញថា ពួកគេមានការគាំទ្រ និងការលើកទឹកចិត្តសម្រាប់ការកសាងកិច្ចសហការ និងបណ្តាញជាមួយសហគមន៍។




**ក្រាហ្វ ២៖** នាយកសាលាត្រូវបានលើកទឹកចិត្ត និងគាំទ្រក្នុងការកសាងវប្បធម៌សហការគ្នាក្នុងចំណោមគ្រូ និងសហការជាមួយសាលារៀនជុំវិញ

ដូចគ្នានេះដែរ គ្រូបង្រៀនត្រូវបានគេសង្កេតឃើញថា ពួកគេបានចូលរួមយ៉ាងសកម្មក្នុងការទទួលខុសត្រូវរួមគ្នា ជាមួយនាយកសាលាក្នុងការកំណត់ទស្សនវិស័យ និងបេសកកម្មរបស់សាលា ការបង្កើតផែនការអភិវឌ្ឍសាលារៀន និងសម្រាប់ការលើកកម្ពស់សមិទ្ធផលការសិក្សារបស់សិស្ស។ ដូចដែលបានបង្ហាញដោយទិន្នន័យប្រហែល ៩០% នៃចំនួនគ្រូបង្រៀនសរុបយល់ស្រប និងយល់ស្របខ្លាំងថា នាពេលបច្ចុប្បន្ននេះ ពួកគេមានទំនួលខុសត្រូវរួមគ្នា ដោយបញ្ជាក់ថា នៅក្នុងការអនុវត្តជាក់ស្តែង ភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពរបស់សាលារៀនមិនមែនជាទំនួលខុសត្រូវតែមួយគត់របស់នាយកសាលានោះទេគឺទាំងគ្រូបង្រៀន និងសមាជិកសហគមន៍ក៏មានចំណែកមួយនៃការទទួលខុសត្រូវផងដែរ។ លើសពីនេះ គ្រូបង្រៀន និងសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន (SMC) រំពឹងថា នឹងមានការចូលរួមកាន់តែច្រើននៅក្នុងការទទួលខុសត្រូវទាំងនេះនាពេលអនាគត ជាមួយនឹងការយល់ស្របខ្លាំង ឬការយល់ស្របទាក់ទងនឹងការទទួលខុសត្រូវរួមគ្នា នាពេលអនាគតបានកើនឡើងពី ២០% ទៅ ៤០% និង ២២% ទៅ ៥០% រៀងគ្នា (**ក្រាហ្វ ៣ក**)។

ចំនួននាយកសាលាខ្ពស់បានចូលរួមក្នុងការកំណត់ចក្ខុវិស័យសាលារៀនសម្រាប់លទ្ធផលសិក្សា និងក្នុងការរៀបចំផែនការសាលារៀនបង្ហាញថា នាយកសាលាមើលឃើញថា ការចូលរួមយ៉ាងសកម្មដោយមិនអាចខ្វះបាន សម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាលពីសកម្មភាពកម្មវិធីអប់រំ និងផែនការអភិវឌ្ឍសាលារៀន។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកឆ្លើយសំណួរមួយចំនួននៅតែចង្អុលបង្ហាញថា ពួកគេមិនបានចូលរួមក្នុងការកំណត់

